# សំណាក់ធម៌និស្សិតទេវវិទ្យាល័យ



និពន្ធដោយលោកអភិបាល
អូលីវីយេ ឝ្មីអីស្លែរ
រៀបចំដោយ ការិយាល័យ
ផ្សព្វផ្សាយព័ត៌មានកាតូលិក

# មាតិកា

## សំខាន់ៗ

### សំណាក់ធម៌ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ (ពេលរសៀល)........................................3-8

- **ប្រស្នាអំពីគ្រាប់ពូជ** (លូកា៨, ៤-៨ ម៉ាថាយ ១៣, ១-៩ ម៉ាកុស ៤, ១-៩)
- **ព្រះយេស៊ូចាប់ផ្តើមផ្សាយដំណឹងល្អនៅស្រុកកាលីឡេ អ្នកភូមិណាសារ៉ែតបដិសេធ មិនព្រមទទួលព្រះអង្គ** (លូកា៤, ១៨-២០ មថ,៤,១២-១៧; ១៣,៥៣-៥៨ មក,១,១៤-១៥; ៦,១-៦)

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ (ពេលព្រឹក)........................................9-17

- **ពាក្យប្រស្នាអំពីអ្នកស្រុកសាម៉ារីម្នាក់មានចិត្តសប្បុរស**(លូកា១០, ៣០-៣៥)
- **សុភមង្គល និង អពមង្គល** (លូកា៦, ២០-២៣ ម៉ាថាយ ៥, ១-១២)
- **អ្នកមានម្នាក់ចង់បានជីវិតអស់កល្បជានិច្ច** (លូកា១៨,១៨-១៥ ម៉ាថាយ ១៩, ១៦-៣០ ម៉ាកុស ១០, ១៧-៣១)

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ (រសៀល)........................................18-24

- **សំណូមពររបស់ម្ដាយលោកយ៉ាកុប និងលោកយ៉ូហាន** (ម៉ាថាយ២០, ២០-២៣ កុស ១០, ៣៥-៤៥ លូកា ២២, ២៤-២៧)
- **ព្រះយេស៊ូសន្ទនាជាមួយស្ត្រីសាសន៍សាម៉ារីម្នាក់** (យ៉ូហាន៤, ៥-១៥)

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ (ពេលព្រឹក)........................................25-29

- **ព្រះយេស៊ូ និង លោកសាខេ** (លូកា១៩, ១-១០)
- **ព្រះយេស៊ូប្រទាននំប៉័ងឲ្យមនុស្សប្រាំពាន់នាក់** (លូកា៩, ១០-១៧ មថ, ១៤, ១៣-២១ មក, ៦, ៣០-៤៤ យហ, ៦, ១-១៤)

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ (រសៀល)........................................30-38

- **ប្រស្នាអំពីចៀមដែលបាត់ហើយរកឃើញវិញ** (លូកា ១៥ ម៉ាថាយ ១៨, ១២-១៤)
- **ប្រស្នាអំពីប្រាក់ដួងដែលបាត់ហើយរកឃើញវិញ**
- **ប្រស្នាអំពីកូនដែលបាត់ហើយរកឃើញវិញ**

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ (ពេលព្រឹក)........................................39-46

- **ព្រះយេស៊ូត្រាស់ហៅសាវ័កបីរូប**(លូកា ៥, ១-១១ ម៉ាថាយ ៤, ១៨-២២ ម៉ាកុស ១, ១៦-២០)
- **ព្រះយេស៊ូចាត់សាវ័ក ៧២ រូប ទៅផ្សាយដំណឹងល្អ** (លូកា ១០, ១-១៦)
- **ពួកសាវ័កវិលត្រឡប់មកវិញ** (លូកា ១០, ១៧-២០)
- **ព្រះយេស៊ូមានព្រះហឫទ័យរីករាយ** (លូកា ១០, ២១-២៤ ម៉ាថាយ ១១, ២៥-២៧ និង ១៣, ១៦-១៧)

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ (រសៀល)........................................47-50

- **ការប្រុងប្រៀបខ្លួន** (លូកា ១២, ៣៥-៤០)



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម
## កាលបរិច្ឆេទៈ១០/០៩/២០១៣ រសៀល

ជម្រាបសួរបងប្អូនជាទីស្រឡាញ់!

ព្រឹកមិញ យើងឥតមានពេលអានអត្ថបទអំពីព្រះសហគមន៍ដែលជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត។ តាមពិតអត្ថបទនេះដាស់តឿនយើងទាំងអស់គ្នា មិនមែនតែបូជាចារ្យឲ្យខិតខំឲ្យបានដូចព្រះគ្រីស្ត ឲ្យព្រះគ្រីស្តកើតជារូបរាងឡើងក្នុងយើង ណែនាំឲ្យយើងធ្វើដំណើររួមជាមួយព្រះយេស៊ូ នៅក្នុងព្រះសហគមន៍ ហើយព្រះសហគមន៍ប្រកាសដំណឹង ល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ចូរចាប់អារម្មណ៍ថាព្រះសហគមន៍មិនប្រកាសអំពីដំណឹងល្អទូទៅមួយនោះទេ ប៉ុន្តែជា ដំណឹងល្អដែលមានគោលដៅមួយយ៉ាងច្បាស់លាស់ គឺអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ នៅក្នុងអត្ថបទនេះ យើងត្រូវតែចាប់ អារម្មណ៍អំពីបុរសម្នាក់ដែលចេញទៅព្រោះគ្រាប់ពូជ។ យើងមានពាក្យមួយដ៏ សំខាន់គឺ " ចេញទៅ " ដូចខ្ញុំបាននិយាយពីព្រឹកមិញអំពីព្រះសហគមន៍ធ្វើដំណើរ។ បុរសម្នាក់នោះគាត់ចេញទៅឯវាលស្រែ របស់គាត់ ហើយគាត់សាបព្រោះគ្រប់កន្លែង ព្រោះដីស្រែនៅអ៊ីស្រាអែលគ្មានភ្លឺដូចនៅស្រុកខ្មែរទេ។ ដោយសារមានខ្យល់ នៅពេលគេសាបព្រោះនោះ បណ្តាលឲ្យគ្រាប់ខ្លះធ្លាក់លើដីមានថ្ម ខ្លះលើដីមានបន្លា ខ្លះនៅលើដីល្អ ក្រោយមកក៏ដុះឡើង។ យើងត្រូវតែចាប់អារម្មណ៍នឹងចំណុចទាំងប៉ុន្មាន ទីមួយ ពាក្យថា " ចេញទៅ" និង ទីពីរ អ្នកសាបព្រោះ " មិនរើសដីល្អដើម្បី សាបព្រោះ" ទេ គាត់មិនស្តាយគ្រាប់ពូជសោះ គាត់សុខចិត្តសាបព្រោះគ្រប់ទីកន្លែង។ ពាក្យប្រស្នានេះ គឺនិយាយសំដៅអំពីព្រះយេស៊ូ និង សំដៅដល់អស់អ្នកដែលប្រកាសដំណឹងល្អ ដល់អស់អ្នកអប់រំជំនឿ និងដល់គ្រីស្តបរិស័ទម្នាក់ៗដែលចេញទៅដើម្បីសាបព្រោះ។ពេលសាបព្រោះយើងមិនជ្រើសរើសដីល្អ ឬដីមិនល្អទេ មានន័យថា យើងមិនសំដៅថាមនុស្សនេះល្អអាចទទួលបាន ឬមនុស្សនេះមិនល្អមិន អាចទទួលបាននោះទេ ប៉ុន្តែ យើងខិតខំប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ យើងមិនជ្រើសរើសទេ។ អ្នកសាបព្រោះ គាត់សាបព្រោះឥតមានព្រំដែន ឯយើង ក៏ត្រូវតែសាបព្រោះឥតមានព្រំដែនដែរ។ នេះក៏ជានិមិត្តរូបនៃព្រះសហគមន៍ ដែលជាចម្ការមួយយ៉ាងទូលំទូលាយ ដែលគ្មានអ្វីមករារាំងយើង មិនឲ្យប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅដល់គ្រប់ទីកន្លែងបានឡើយ។





ដូច្នេះប្រស្នានេះ ណែនាំឲ្យយើងត្រូវតែនឹកឃើញ អំពីរបៀបប្រកាសដំណឹងល្អនៅក្នុងព្រះសហគមន៍។ ព្រះសហគមន៍ មិនមែនសំដៅតែលើទីតាំងរបស់យើង ទីធ្លារបស់យើងប៉ុណ្ណោះទេ ប៉ុន្តែ ព្រះសហគមន៍គឺនៅគ្រប់ទីកន្លែង។ តាមពិត បើពិនិត្យមើលច្បាប់ដែលយើងបានទទួលពីក្រសួង គឺយើងមានសិទ្ធិប្រកាសដំណឹងល្អ តែនៅក្នុងបរិវេណព្រះវិហារតែប៉ុណ្ណោះ។ ប៉ុន្តែច្បាប់នេះ មិនមែនជាអ្វីដែលយើងត្រូវតែធ្វើឲ្យដូចនោះទេ យើងមិនអាចអង្គុយរង់ចាំឲ្យគេមករកយើងដល់កន្លែងបានទេ។ នៅកំពង់សោមជាឧទាហរណ៍ស្រាប់ គឺព្រះសហគមន៍របស់យើងនៅដាច់ឡែកពីភូមិ ពីទីប្រជុំជន ពេលបងប្អូនត្រូវការមកទីនេះ គេពិបាក គេត្រូវការជិះម៉ូតូ ជិះឡានមក ទើបមកដល់។ អំពីទីកន្លែង ប្រសិនបើយើងធ្វើតាមច្បាប់ គឺយើងពិបាកទាក់ទងនឹងបងប្អូនណាស់ ប៉ុន្តែយើងចង់ធ្វើតាមរបៀបព្រះយេស៊ូដូចយើងបានស្តាប់ គឺព្រះអង្គសាបព្រោះយ៉ាងទូលំទូលាយ។ យើងត្រូវការគិតពិចារណា តើយើងត្រូវប្រកាសដំណឹងល្អ ដល់ភូមិទាំងអស់ដែលនៅជុំវិញយើងយ៉ាងដូចម្តេច?។ តើយើងធ្វើដូចម្តេច ដើម្បីឲ្យយើងទៅជាព្រះសហគមន៍ ទៅជាគ្រីស្តបរិស័ទ ទៅជាបូជាចារ្យ ដែលចេញទៅសាបព្រោះគ្រប់ទីកន្លែងបាន?។ យើងមិនគ្រាន់តែអប់រំទូទៅ ប៉ុន្តែយើងត្រូវការផ្តល់សក្ខីភាពដែរ ដ្បិតគោលដៅរបស់យើង គឺប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ដូច្នេះគ្រាប់ពូជរបស់យើង មិនមែនជាគ្រាប់ពូជអំពីការអប់រំទូទៅអំពី ការលើកទឹកចិត្តតែប៉ុណ្ណឹង ប៉ុន្តែជាគ្រាប់ពូជបង្ហាញអំពីដំណឹងល្អរបស់ព្រះជាម្ចាស់ បង្ហាញអំពីចម្ការ ដែលសព្វថ្ងៃយើងភ្ជួរ រាស់ដីហើយយើងដាំដុះ គឺយើងដាំដុះចិត្តគំនិតរបស់មនុស្ស ឲ្យទទួលគ្រាប់ពូជតូចៗឲ្យដុះឡើង ឲ្យមនុស្សម្នាក់ៗមានចិត្តគំនិត ដូចព្រះយេស៊ូ រហូតដល់ព្រះយេស៊ូកើតនៅក្នុងចិត្តគំនិតរបស់បងប្អូនម្នាក់ៗ ដើម្បីកុំឲ្យបងប្អូនរបស់យើងវង្វេងមើល ឃើញតែព្រះសហគមន៍ដែលជាអាគារ ដែលមានកន្លែងអង្គុយយ៉ាងស្រួលសម្រាប់អធិដ្ឋាន សម្រាប់សំណាក់ធម៌ សម្រាប់សូត្រធម៌ តែប៉ុណ្ណឹង។ នេះជាអត្ថន័យដ៏ពិតប្រាកដអំពីការកសាងព្រះសហគមន៍ កុំឲ្យបងប្អូនរបស់យើងយល់ច្រឡំអំពី ការកសាងព្រះសហគមន៍។ ដូច្នេះពេលយើងកសាងអាគារ ពេលយើងអប់រំជំនឿ ពេលយើងធ្វើពិធីជ្រមុជទឹក តើយើងធ្វើ ដូចអ្នកសាបព្រោះដូចយើងបានស្តាប់នៅក្នុងអត្ថបទ ឬយ៉ាងណា? តើយើង នៅក្នុងដីដែលមានបន្លាច្រើន ឬ ដីដែលមាន ថ្មច្រើន ឬ ដីដែលមានជីជាតិល្អ?។

យើងជាបូជាចារ្យ ជាអ្នកដឹកនាំ យើងត្រូវតែថែរក្សាក្រុមរបស់យើង ថែហ្វូងចៀមរបស់យើង កុំឲ្យព្រះអាទិត្យជះកម្តៅមកចំធ្វើឲ្យពន្លកនៃគ្រាប់ពូជរបស់យើងក្រៀមស្វិតទៅវិញដែលខ្លះគេបានធ្វើដំណើរ ២ ឆ្នាំហើយ ខ្លះ ៥ឆ្នាំ ខ្លះបាន ទទួលពិធីជ្រមុជទឹករួចហើយ ជាពិសេសសព្វថ្ងៃ យុវជនយុវនារីដែលបានទទួលពិធីជ្រមុជទឹករួចហើយ ក៏បានចាប់ផ្តើម បាត់ទៅដែរ។ ការកសាងព្រះសហគមន៍មិនមែនជាការងារតូចតាចមួយទេ។ នៅពេលគេទទួលពិធីជ្រមុជទឹករួចហើយ គឺជាពេលវេលាមួយដែលគេចាប់ផ្តើមចាក់ឫស ហើយត្រូវឲ្យមានឫសមួយដែលរឹងមាំ។ យើងជាបូជាចារ្យ ជាអ្នកណែនាំគេ តើយើងធ្វើដូចម្តេច ដើម្បីបន្តណែនាំឲ្យជីវិតរបស់គេ ទៅជាជីវិតគ្រីស្តបរិស័ទរឹងមាំនៅក្នុងព្រះសហគមន៍?។ ចម្លើយ គឺយើង ត្រូវនឹកឃើញដល់ព្រះសហគមន៍ដែលជាចម្ការ គឺព្រះសហគមន៍នេះហើយជាកន្លែងឲ្យយើងហាត់ហ្វឹកហ្វឺន ឲ្យយើងមាន ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ឲ្យការរស់នៅរបស់យើងផ្ទាល់ជាបូជាចារ្យ និងគ្រីស្តបរិស័ទមានព្រះបន្ទូលដឹក នាំជីវិតប្រចាំថ្ងៃ ឲ្យព្រះបន្ទូលចូលយ៉ាងជ្រៅ ដើម្បីឲ្យយើងអាចទៅមុខបាន នៅពេលព្រះអាទិត្យជះពន្លឺយ៉ាងខ្លាំងមកលើ។

សម្រាប់យើងជាបូជាចារ្យបម្រើព្រះសហគមន៍ យើងត្រូវការហាត់អំពីការអធិដ្ឋាននៅក្នុងជីវិតរបស់យើង។ពីមុនមានលោកជាជនជាតិឥណ្ឌាម្នាក់បានមកធ្វើសំណាក់ធម៌ជាមួយយើង លោកមានប្រសាសន៍ថា រាល់ថ្ងៃ បូជាចារ្យត្រូវអង្គុយយ៉ាងតិច ២ម៉ោងនៅចំពោះមុខព្រះកាយ ដើម្បីឲ្យជីវិតរបស់ខ្លួនទៅជាជីវិតដែលរួមជាមួយព្រះគ្រីស្ត។ មិនត្រូវស្តាយពេលវេលាស្តាយកម្លាំងទេ ត្រូវទុកពេលឲ្យព្រះគ្រីស្តសម្អាតយើងឲ្យជីវិតខាងក្នុងរបស់យើងទៅជាជីវិតថ្មី ឲ្យព្រះគ្រីស្តកើតជារូបរាងឡើង នៅក្នុងខ្លួនរបស់យើង គឺកើតមានពេញមួយជីវិត។ បូជាចារ្យត្រូវតែថែរក្សាអស់មួយជីវិត នូវចម្ការដែលខ្លួនបានទទួល និងថែរក្សាអស់អ្នកដែលរស់

នៅក្នុងចម្ការដែរ។ ឧទាហរណ៍នៅព្រៃកប្រស់ ចាប់ពីលោកឪពុកលីចេញទៅបារាំង នៅឆ្នាំ ២០០៧ យូរៗទើបខ្ញុំបានទៅទីនោះម្តង។ ក្នុងរយៈពេល ៦ខែ ខ្ញុំបានទៅទីនោះប្រហែលពីរបីដង។ ក្រោយមកលោកឪពុកសុនទៅទទួលខុសត្រូវទីនោះ ពេលលោកទៅដល់ ស្រាប់តែបងប្អូននៅទីនោះជាខកពេលហើយ ព្រោះមានបងប្អូនខ្លះ គេទៅវត្តខាងព្រះពុទ្ធសាសនា នេះគឺដោយសារមួយរយៈកន្លងទៅ យើងមិនមានអ្នកដែលទៅថែរក្សាគេ។

យើងបានស្តាប់ព្រះគម្ពីរជាច្រើនដង ស្តីអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ប៉ុន្តែអត្ថបទដដែលនេះពេលយើងស្តាប់ជាថ្មីម្តងទៀត នោះយើងក៏រកឃើញអត្ថន័យថ្មីទៀតជារៀងរហូត។ ដូច្នេះ ប្រសិនបើយើងគិតថា យើងស្គាល់អត្ថបទគម្ពីរអស់ហើយ យើងធ្លាប់ស្តាប់រួចហើយ យើងដឹងអស់ហើយ យើងមិនចាំបាច់អានឬស្តាប់ទៀតទេ ពេលនោះយើងមាន បញ្ហាហើយ ព្រោះនៅពេលណាយើងស្តាប់ម្តងទៀត នោះយើងមុខជាសប្បាយចិត្តនឹងអត្ថន័យថ្មីដែលយើងរកឃើញម្តង ទៀតជាមិនខាន ការណ៍នេះសំខាន់ណាស់។ ប្រសិនបើបូជាចារ្យយើង ឥតមានអារម្មណ៍ថា អត្ថបទដដែលនេះនឹងទៅ ជាអត្ថបទថ្មី ដែលផ្តល់អត្ថន័យថ្មីដល់គ្រីស្តបរិស័ទ ដែលកំពុងអង្គុយស្តាប់យើងទេ នោះយើងមិនអាចទៅមុខបានទេ។ ព្រះយេស៊ូក្រោកឡើងអានព្រះគម្ពីរ "ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ បានសណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំ ឲ្យខ្ញុំនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ ព្រះអង្គបានចាត់ឲ្យខ្ញុំមកប្រាប់ដល់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាពហើយប្រាប់មនុស្សខ្វាក់ថា គេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន ព្រមទាំងប្រកាសអំពីឆ្នាំ ដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា" រួចហើយព្រះយេស៊ូមានព្រះបន្ទូលថា៖"ថ្ងៃនេះព្រះបន្ទូលនេះបានកើតជារូបរាងហើយ"។សេចក្តីនេះណែនាំយើងឲ្យមើលឃើញអំពីគោលដៅនៃព្រះរាជ្យរបស់ ព្រះជាម្ចាស់ ដែលព្រះយេស៊ូបានប្រកាស។ អត្ថបទគម្ពីរ ដែលចែងថា មនុស្សខ្វាក់មើលឃើញវិញជនជាប់ជាឈ្លើយមាន សេរីភាព នោះនាំឲ្យយើងយល់ថា៖



ចំណុចទីមួយ ព្រះយេស៊ូយាងមក ឲ្យយើងទទួលសុភមង្គលដ៏ពេញលក្ខណៈ មានន័យថា សេចក្តីសុខនៅក្នុងដួងចិត្តរបស់មនុស្សម្នាក់ៗ នឹងនាំឲ្យមានសេចក្តីសុខនៅក្នុងពិភពលោកទាំងមូល។ ដោយសារហេតុនេះហើយ បានជាសម្តេចប៉ាប សូមអញ្ជើញគ្រីស្តបរិស័ទទូទាំងពិភពលោកទាំងមូល ឲ្យយកពេលវេលាចំនួនពីរថ្ងៃ អង្គុយអធិដ្ឋានដើម្បីសន្តិភាព និង សេចក្តីសុខ៖ ទីមួយសម្រាប់មនុស្សម្នាក់ៗផ្ទាល់ និងទីពីរសម្រាប់ពិភពលោកទាំងមូល។ ព្រះយេស៊ូមិនដែលណែនាំឲ្យ យើងធ្វើបាតុកម្មណាមួយសោះ ប៉ុន្តែសេចក្តីពិត ព្រះយេស៊ូបានសូមឲ្យយើងអធិដ្ឋាន ទូលអង្វរព្រះបិតាដើម្បីទទួលសេចក្តីសុខ។ សន្តះអូហ្គូស្តាំងមានប្រសាសន៍ថា៖ "យើងទទួលសុខសន្តិភាព នៅពេលយើងរស់នៅយ៉ាងស្រួលដោយយុត្តិធម៌ និងបន្ថែមទៀតត្រូវមានការស្រុះស្រួលរវាងគ្នានឹងគ្នា និងរវាងយើងនឹងព្រះជាម្ចាស់ "។ សុភមង្គលដ៏ពិតប្រាកដដែល ព្រះយេស៊ូចង់ឲ្យយើងមាន អាចកើតមាន នៅពេលណាយើងកសាងសុខសន្តិភាព នៅពេលណាយើងលើកលែងទោសឲ្យគ្នា ទៅវិញទៅមក និងនៅពេលយើងសម្រុះសម្រួលជាមួយព្រះជាម្ចាស់។ ការលើកលែងទោសជាអំណោយទាន ដែលព្រះជាម្ចាស់ប្រទានឲ្យមនុស្សលោក។ ក្នុងគម្ពីរលូកា មានចែងអំពីលោកសាខេ និងប្រស្នាអំពីកូនពៅវង្វេង និងពាក្យប្រស្នាផ្សេងទៀត គឺសុទ្ធតែបង្ហាញអំពីព្រះហឫ

ទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក។ អត្ថបទខ្លះក្នុងគម្ពីរលូកា គ្មានចែងក្នុងគម្ពីរផ្សេងទេ។ អត្ថបទគម្ពីបានចាប់ផ្ដើមពីព្រះយេស៊ូប្រសូត បន្ទាប់មកព្រះអង្គយាងចេញទៅប្រកាសដំណឹងល្អដោយសម្ដែងធម្មទេសនាជាលើកដំបូងដោយយោងតាមអត្ថបទគម្ពីរអេសាយ ក្រោយមក ព្រះអង្គបានប្រព្រឹត្តតាមអ្វី ដែលព្រះអង្គបានមានព្រះបន្ទូលក្នុងធម្មទេសនានោះ គឺព្រះអង្គខិតខំធ្វើឲ្យព្រះបន្ទូលដែលព្រះអង្គបានសម្ដែងនោះចេញជារូបរាង។

ប្រសិនបើយើងនិយាយសង្ខេបអំពីរបៀប ដែលព្រះយេស៊ូប្រកាសដំណឹងល្អ ទីមួយ គឺព្រះអង្គប្រកាសតាមរយៈធម្មទេសនា និងទីពីរ ព្រះអង្គប្រកាសតាមរយៈកិច្ចការ ដែលព្រះអង្គប្រព្រឹត្ត ដូចជាព្រះអង្គគង់នៅជាមួយអ្នកមានបាប និងគង់នៅជាមួយអ្នកជំងឺជាដើម ជាក្រុមដែលព្រះអង្គបានប្រកាសដំណឹងល្អ និងប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ឲ្យដល់គេ ខ្លាំងជាងគេ។ តាមពិតអំពើបាប និងជំងឺរលាយចូលគ្នានៅក្នុងខ្លួនរបស់យើង ព្រះយេស៊ូយាងមកដើម្បីព្យាបាលទាំងខាងផ្លូវចិត្ត និងផ្លូវកាយរបស់យើង។ អ្នកដែលបានអង្គុយស្ដាប់ព្រះយេស៊ូមានព្រះបន្ទូល គេភ្ញាក់ស្មារតីថា ព្រះយេស៊ូយាងមក សម្រាប់គេផ្ទាល់ ដូច្នេះគេស្ដាប់ព្រះអង្គតាមរយៈចិត្តរបស់គេ។ មានអ្នកជំងឺរាប់រយនាក់ដែលទៅជួបព្រះយេស៊ូ និងក៏មាន អ្នកដែលមានសុខភាពល្អទៅជួបព្រះអង្គដែរ គឺប្រហែល៩៩% គេមានបញ្ហាខាងផ្លូវចិត្ត ខាងផ្លូវវិញ្ញាណ មិនមែនខាងផ្លូវកាយ ខាងផ្លូវសុខភាពទេ ដូចលោកសាខេជាដើម ព្រះយេស៊ូជួយគាត់ដើម្បីឲ្យគាត់មានជីវិតវិញ។ នៅទីបញ្ចប់ ដើម្បីបង្ហាញអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ នោះព្រះយេស៊ូបានបង្ហាញតាមរយៈកិច្ចការដ៏សំខាន់មួយ គឺព្រះអង្គជប់លៀងជាមួយក្រុមសាវ័ក បន្ទាប់មកព្រះអង្គបូជាព្រះជន្ម។ ដូច្នេះតាមរយៈព្រះបន្ទូល និងតាមរយៈស្នាព្រះហស្តទាំងអស់របស់ព្រះយេស៊ូ នោះយើងអាចរកឃើញអត្ថន័យដ៏ពិតប្រាកដ គឺនៅពេលព្រះអង្គកាច់នំប៉័ង។

នៅប្រទេសអ៊ីស្រាអែល ខ្ញុំបានទៅអង្គុយនៅក្នុងបន្ទប់ ដែលព្រះយេស៊ូបានកាច់នំប៉័ងនៅពេលព្រះអង្គធ្វើពិធីជប់ លៀងពេលចុងក្រោយ។ ពេលនោះយើងអង្គុយចាប់ដៃគ្នា ហើយច្រៀង អង្វរសូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ បន្ទប់នោះ ពិសេសណាស់ ព្រោះជាបន្ទប់ដែល ព្រះយេស៊ូជប់លៀងចុងក្រោយជាមួយក្រុមសាវ័ក និងជាបន្ទប់ដែលព្រះនាងម៉ារីជា មួយក្រុមគ្រីស្តទូតជួបជុំគ្នាដើម្បីទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ពេលទៅដល់ភ្នំតាបិរ និងភ្នំនៃសុភមង្គល ពេលនោះខ្ញុំនឹកឃើញយ៉ាងខ្លាំង អំពីរបៀប ដែលព្រះយេស៊ូប្រកាសដំណឹងល្អ គឺព្រះអង្គប្រកាសដំណឹងល្អ ដោយបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គសម្រាប់យើងម្នាក់ៗ ខ្ញុំនឹកឃើញដល់គេដែលវាយដែកគោលភ្ជាប់ព្រះអង្គ នឹងឈើឆ្កាង នឹកឃើញពេលព្រះអង្គកាច់នំប៉័ង និងព្រះអង្គលើកពែងស្រាឡើង នឹកឃើញព្រះ យេស៊ូនៅលើឈើឆ្កាង និងបូជាព្រះជន្ម នឹកឃើញពិតមែនថានំទៅជាព្រះកាយស្រាទៅជាព្រះលោហិត។ នឹកឃើញដល់ពួកសាវ័កដែលរត់ចោលព្រះអង្គ ប៉ុន្តែ ព្រះអង្គនៅតែបំពេញគ្រប់កិច្ចការនៃការសង្គ្រោះ សម្រាប់ពិភពលោកយើង។



ដូច្នេះការប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ យើងមិនប្រកាសតែអំពីព្រះយេស៊ូផ្ទាល់ជាដំណឹងល្អ ប៉ុន្តែ យើងក៏គិតថាត្រូវធ្វើដូចម្ដេចដើម្បីឲ្យព្រះយេស៊ូរស់នៅក្នុងយើង? ឲ្យព្រះយេស៊ូទៅជាដំណឹងល្អផ្ទាល់ខ្លួន ដូចសន្តៈ ប៉ូលមានប្រសាសន៍ថា៖ មិនមែនខ្ញុំដែលរស់នៅ គឺព្រះយេស៊ូទេដែលរស់នៅក្នុងខ្ញុំ។ នេះជាគោលដៅនៃអ្នកប្រកាស ដំណឹងល្អដ៏ពិតប្រាកដ ដែលបន្តិចម្ដងៗធ្វើឲ្យខ្លួនចូលនៅក្នុងអាថ៌កំបាំងនៃជីវិតរួមជាមួយព្រះយេស៊ូ។ ព្រះយេស៊ូផ្ទាល់ បានរកឃើញកម្លាំងដើម្បីប្រកាសដំណឹងល្អពីក្នុងការអធិដ្ឋាន (យហ ១៧) គឺព្រះអង្គអធិដ្ឋានសម្រាប់ខ្លួនព្រះអង្គផ្ទាល់ សម្រាប់ក្រុមសាវ័ក សម្រាប់ពិភពលោក...មុនព្រះអង្គសោយទិវង្គត។ ព្រះយេស៊ូអធិដ្ឋានសម្រាប់មនុស្សលោកឲ្យទៅជាធ្លុង តែមួយ

ដូចព្រះបិតា ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះអង្គផ្ទាល់ជាធ្លុងតែមួយដែរ។ ព្រះយេស៊ូបូជាព្រះជន្ម នៅក្នុងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះបិតា នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះយេស៊ូមិនមានព្រះបន្ទូលអំពីដំណឹងល្អ ប៉ុន្តែ ព្រះអង្គ ផ្ទាល់ជាដំណឹងល្អ នេះជាមូលហេតុដែលគម្ពីររបស់យើងជាគម្ពីរដែលមានជីវិត។

ដូច្នេះ នៅពេលនេះ យើងត្រូវតែសួរខ្លួនឯងម្នាក់ៗថា តើយើងធ្វើដូចម្តេច ដើម្បីប្រកាសដំណឹងល្អនៃព្រះរាជ្យរបស់ ព្រះជាម្ចាស់នាពេលសព្វថ្ងៃ? ការពិត យើងមានកម្លាំងមួយដ៏ពិសេស គឺក្រុមយុវជនរបស់ព្រះសហគមន៍យើងដែលមាន សកម្មភាព។ ពេលខ្ញុំផ្ញើរូបភាពខ្លះៗនៃកម្មវិធីផ្សេងៗរបស់យើងទៅអឺរ៉ុបគេថា គេធ្វើមិនបានដូចយើងទេ មានខ្លះគេ ច្រណែន។ យើងជាព្រះសហគមន៍តូចមួយ តែយើងអាចប្រមូលយុវជន ៤០០ នាក់ដោយគ្មានបញ្ហាអ្វីសោះ តែគេធ្វើមិនបានទេ។ កម្លាំងយុវជនយុវនារីរបស់យើងពិសេសណាស់ យុវជនម្នាក់ជាគ្រីស្តទូតម្នាក់ ដែលប្រកាសដំណឹងល្អដល់យុវជន ម្នាក់ទៀត គឺយុវជនម្នាក់បានណែនាំឲ្យយុវជនម្នាក់ទៀតស្គាល់ព្រះសហគមន៍។ នេះជាចំណុចដែលយើងត្រូវតែថែរក្សា គឺថែរក្សាគ្រប់សកម្មភាពទាំងអស់របស់យុវជន ដោយគ្រប់គ្រង ដោយណែនាំ ដោយលើកទឹកចិត្តផ្តល់កម្លាំងដល់គេ ដើម្បីឲ្យគេកសាងព្រះសហគមន៍របស់យើងឲ្យមានជីវិតតទៅទៀត។ យើងឃើញក្នុងមហាសន្និបាតយុវជន ដែលចាត់ចែងដោយការិយាល័យយុវជនភូមិភាគភ្នំពេញ ដែលមានអ្នកស្ម័គ្រចិត្ត ៤0 នាក់មកពីភូមិភាគទាំងបី។ក្នុងរយៈពេលជិត ១0 ថ្ងៃ គេបានរស់នៅជាមួយគ្នា ហើយបានធ្វើឲ្យកម្មវិធីទៅមុខ នេះជាចំណុចមួយដែលយើងត្រូវថែរក្សា។

ចំណុចទីពីរ សព្វថ្ងៃបងប្អូននៅតាមជនបទ ក៏អាចទទួលព្រះបន្ទូលបានយ៉ាងស្រួលដែរ ដោយសារព្រះសហគមន៍ នៅទីនោះទៅជាកន្លែងមួយ ឲ្យយុវជនទំនេរពីការងារបានមកជួបជុំគ្នា ជាកន្លែងដែលយើងអាចបង្កើតសកម្មភាពផ្សេងៗ ដើម្បីណែនាំអប់រំគេ ជាកន្លែងមួយដែលយើងអាចមានទំនាក់ទំនងជាមួយពួកគេបាន ព្រោះសព្វថ្ងៃ សង្គមបានប្រែប្រួលយ៉ាងខ្លាំង។ នៅមុនសម័យប៉ុលពត ទោះបីយើងអាចធ្វើអ្វីក៏បានក៏ដោយ តែយើងក៏ពិបាកទំនាក់ទំនងជាមួយយុវជនខ្លាំង ណាស់ គ្មានយុវជនណាមកចូលរួមជាមួយយើងទេ ដោយសារនៅសម័យនោះ ពុទ្ធសាសនាមានឥទ្ធិពល យ៉ាងខ្លាំងលើក្រុមគ្រួសារនីមួយៗ ឪពុកម្តាយមិនឲ្យកូនរបស់គេ មកទាក់ទងនឹងសាសនាដទៃទេ។

ចំណុចទីបី គឺមកពីយុវជនយុវនារី និង មនុស្សទាំងអស់ មានសេចក្តីត្រូវការមួយផ្សេងពីការសិក្សា ផ្សេងពីការងារ គឺគេត្រូវការមានអ្វីមួយមកដើម្បីបំភ្លឺចិត្តគំនិត និង វិញ្ញាណរបស់គេ។ ក្នុងចិត្តរបស់គេមានវត្តមានរបស់ព្រះជាម្ចាស់ ដែល ណែនាំឲ្យគេស្រេកឃ្លានចង់ស្គាល់ព្រះអង្គ ដើម្បីឲ្យគេអាចទៅមុខបាន។ ប៉ុន្តែមនុស្សម្នាក់ៗ មិនអាចដាក់ឈ្មោះនៃសេចក្តី ត្រូវការរបស់គេនោះ ថាជាព្រះជាម្ចាស់បានភ្លាមៗទេ ហេតុដូច្នោះហើយ បានជានៅពេលណាគេបានស្តាប់ព្រះបន្ទូលរបស់ ព្រះជាម្ចាស់ម្តងៗ ណែនាំឲ្យ គេចេះតែចង់ស្តាប់ថែមទៀត រហូតដល់ពេលគេបានទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ។ ដូច្នេះ នេះជាចម្ការរបស់យើងដែលយើងត្រូវតែថែរក្សា។ ឥឡូវនេះ ខ្ញុំក៏សូមឲ្យយើងគិតអំពីវត្តមានរបស់យើងនៅទីក្រុងដែរ គឺមិន ស្រួលប៉ុន្មានទេ។ខ្ញុំបានសួរទៅលោកឪពុកស៊ុនថា៖តើយើងធ្វើដូចម្តេចដើម្បីឲ្យមានយុវជនដទៃអាចចេញចូលនៅទី នេះបានរាល់ថ្ងៃ?។ ជាទូទៅ នៅទីក្រុងមិនសូវមានយុវជនយុវនារីចេញចូលក្នុងព្រះសហគមន៍ប៉ុន្មានទេ។ ដោយសារជាតួនាទីរបស់យើង នោះ ទី១ យើងត្រូវតែប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ ដើម្បីឲ្យគេបានយល់ដឹងអំពីព្រះរាជ្យរបស់ព្រះអង្គ ដ្បិតគេក៏មានសិទ្ធិស្តាប់ព្រះបន្ទូលដែរ ដូចលោកប៉ូលបាន មានប្រសាសន៍ថា៖ ជាការអាម៉ាស់ បំផុត ប្រសិនបើខ្ញុំមិនប្រកាសដំណឹងល្អ។ ទី២ តាមអត្ថបទអេភេសូដែលយើងអាននៅថ្ងៃដែលព្រះយេស៊ូសម្តែងព្រះអង្គថា៖ មនុស្សគ្រប់ជាតិសាសន៍ មានសិទ្ធិចូលរួមទទួលកេរមរតក និងមានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ។ ដូច្នេះ យើងត្រូវតែការពារសិទ្ធិនេះ ដើម្បីឲ្យការប្រកាសដំណឹងល្អបានទៅដល់មនុស្សទាំងអស់ តាមសិទ្ធិរបស់គេ តែបើយើងមិន បើកផ្លូវឲ្យគេទេ នោះយើងពិតជាមិនបានបំពេញសិទ្ធិឲ្យគេ ក្នុងឋានៈយើងជាអ្នកបើកផ្លូវឲ្យគេទេ។

ហេតុនេះហើយ យើងត្រូវការគិតអំពីរបៀបដែលយើងត្រូវប្រកាសដំណឹងល្អ អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ដល់មនុស្សទាំងអស់ នៅក្នុងព្រះសហគមន៍យើងនាពេលបច្ចុប្បន្ននេះ។ អាម៉ែន!

## អត្ថបទព្រះគម្ពីរ
## សម្រាប់ថ្ងៃទី១០/០៩/២០១៣ពេលរសៀល

**ប្រស្នាអំពីគ្រាប់ពូជ** ( លូកា៨, ៤-៨ ម៉ាថាយ ១៣, ១-៩ ម៉ាកុស ៤, ១-៩ )

៤មានបណ្ដាជន ច្រើនកុះករចេញពីទីក្រុងនានាមករកព្រះយេស៊ូ ព្រះអង្គមាន
ព្រះបន្ទូលជាប្រស្នាដូចតទៅ៖ ៥មានបុរសម្នាក់ ចេញទៅព្រោះគ្រាប់ពូជ។
ពេលគាត់ព្រោះ មានគ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ ត្រូវគេដើរជាន់ហើយសត្វមក
ចឹកស៊ីអស់ទៅ។ ៦មានគ្រាប់ពូជខ្លះទៀតធ្លាក់ទៅលើដីមានថ្ម កាលពន្លកដុះ
ឡើង ក៏ក្រៀមស្វិតទៅវិញ ព្រោះខ្វះទឹក។ ៧មានគ្រាប់ពូជខ្លះទៀត ធ្លាក់ទៅលើ
ដីមានបន្លា។ បន្លាដុះឡើងជាមួយគ្រាប់ពូជ ហើយរួបរឹតពូជនោះមិនឲ្យដុះ
ឡើងបាន។ ៨មានគ្រាប់ពូជខ្លះទៀតធ្លាក់ទៅលើដីមានដីជាតិល្អ គ្រាប់ពូជដុះ
ឡើងឲ្យផលមួយជាមួយរយ។ ព្រះយេស៊ូបន្លឺព្រះសូរសៀងថែមទៀតថា៖
អស់អ្នកដែលឮពាក្យនេះ សូមយកទៅពិចារណាចុះ!។

### ព្រះយេស៊ូចាប់ផ្ដើមផ្សាយដំណឹងល្អនៅស្រុកកាលីឡេ អ្នកភូមិណាសារ៉ែតបដិសេធ មិនព្រមទទួលព្រះអង្គ

( លូកា៤, ១៨-២០ មថ,៤,១២-១៧; ១៣,៥៣-៥៨ មក,១,១៤-១៥; ៦,១-៦ )

១៨ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ។ ព្រះអង្គបានចាក់ប្រេងអភិ
សេកខ្ញុំឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ព្រះអង្គបានចាត់ខ្ញុំឲ្យមកប្រកាស
ប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាពហើយប្រាប់មនុស្សខ្វាក់ថាគេ
នឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមករំដោះអស់អ្នក ដែលត្រូវគេ
សង្កត់សង្កិន
១៩ព្រមទាំងប្រកាសអំពីឆ្នាំ ដែលព្រះអម្ចាស់សម្ដែងព្រះ
ហឫទ័យមេត្តាករុណា។
២០លុះអានចប់ហើយព្រះយេស៊ូបិទគម្ពីរ ប្រគល់
ទៅអ្នកបំរើក្សារួចទ្រង់គង់ចុះវិញ។មនុស្សគ្រប់ៗរូបនៅក្នុងធម្មសាលាសំឡឹង
មើលព្រះអង្គ។



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម
## ១១/០៩/២០១៣ (ព្រឹក)

ជម្រាបសួរបងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាថ្ងៃទីពីរ យើងស្គាល់ម៉ាកូបាំ ជាស្ត្រីម្នាក់ដែលរស់នៅប្រទេសបារាំងនៅសត្សវត្សទី ២០។ នៅអាយុ ២០ ឆ្នាំ គាត់មានរបួសដែលបណ្តាលឲ្យគាត់លែងដើរបាន គាត់នៅតែលើគ្រែរហូត។ ដល់អាយុ ៣០ ឆ្នាំ គាត់ហូបលែងបានទៀត។ ពីអាយុ ៣០ ដល់អាយុ ៨០ ឆ្នាំ គាត់ហូបតែព្រះកាយ មួយថ្ងៃម្តងៗ។ រាល់ថ្ងៃសុក្រមានមារសាតាំងមកវាយគាត់ និងចូល ក្នុងខ្លួនរបស់គាត់។ គាត់រស់នៅក្នុងបន្ទប់តូចមួយដែលងងឹត ហើយភ្នែករបស់គាត់ក៏មើលមិនសូវឃើញដែរ។ ប៉ុន្តែគាត់បានក្លាយទៅជាអ្នកណែនាំគេ រាល់ថ្ងៃមានលោកកាឌីណាល់ លោកអភិបាល គ្រីស្តបរិស័ទ ពី ១០ ទៅ ២០ នាក់មកសុំជួប ដើម្បីឲ្យគាត់បំភ្លឺអំពីការរស់នៅដល់គេ។ គាត់ជាអ្នកបង្កើតមណ្ឌលសំណាក់ធម៌នៅប្រទេសបារាំង ដែលទទួលបានជោគ ជ័យយ៉ាងខ្លាំងដែលសព្វថ្ងៃមានសាខា ៣០ កន្លែង ទាំងនៅក្នុងស្រុកបារាំង ស្រុកអាហ្វ្រិក និងស្រុកអាស៊ី។ ក្នុងមណ្ឌល នេះមានលោកម្នាក់ដែលទទួលអំណោយទានពិសេសដើម្បីណែនាំសំណាក់ធម៌និងលោករស់នៅជាក្រុមជាមួយគ្រីស្ត បរិស័ទដែលជាអ្នកស្ម័គ្រចិត្ត មកទទួលស្វាគមន៍ភ្ញៀវ។ លោកមានប្រសាសន៍ថា លោកបង្កើតមណ្ឌលនេះឡើង គឺដើម្បីឲ្យ គ្រីស្តបរិស័ទចូលនៅក្នុងទំនាក់ទំនងសាជាថ្មីជាមួយព្រះយេស៊ូ។ ការសំណាក់ធម៌នេះត្រូវការប្រាំថ្ងៃ។ សព្វថ្ងៃតែងតែមាន គ្រីស្តបរិស័ទមក ដើម្បីទទួលការអប់រំរយៈពេលប្រាំថ្ងៃ អំពីការរស់នៅរបស់គេក្នុងការទាក់ទងជាមួយព្រះយេស៊ូ។ នេះជា មណ្ឌលសំណាក់ធម៌ ដែលអប់រំគ្រីស្តបរិស័ទអំពីចំណេះដឹងនៃការរស់នៅផង និងអំពីខាងផ្លូវវិញ្ញាណផងដែរ។

ពេលនេះយើងមកសំណាក់ធម៌ ដូច្នេះយើង ត្រូវតែតស៊ូដើម្បីមានទំនាក់ទំនងជាមួយព្រះយេស៊ូ កុំឲ្យយើងវង្វេងអារម្មណ៍។ ថ្ងៃនេះមានប្រធានបទថ្មីគឺ ព្រះសហគមន៍ដែលគ្មានធនធាន តែបម្រើអ្នកក្រីក្រ។ ប្រធានបទនេះ ខ្ញុំបានរិះ គិតតាំងពី ១៥ឆ្នាំមកហើយ គឺតាំងពីពេលដែលខ្ញុំបានមកដល់ប្រទេសកម្ពុជា។ ពេលធ្វើសិក្ខាសាលានៅភ្នំពេញថ្មី កាលនោះខ្ញុំបានដឹកនាំផ្ទាល់ ហើយប្រធានបទក៏ស្រង់ចេញពីមហាសន្និបាតវ៉ាទីកង់ទីពីរនេះដែរ។សម្តេចប៉ាបហ្វ្រង់ស្វ័រពេលឡើងជាសម្តេចប៉ាបលោកបានប្រកាសយកប្រធានបទនេះទុកជាអាទិភាពសម្រាប់ព្រះសហគមន៍។ ជាច្រើនដង សម្តេចមានប្រសាសន៍ថា៖ ព្រះសហគមន៍ក្រីក្រ ដើម្បីបម្រើអ្នកក្រីក្រ។ សម្តេចប៉ាបបានរក្សាគំនិតនេះ នៅក្នុងការរស់នៅរបស់លោកផ្ទាល់ នៅក្នុងរបៀបដែលលោកធ្វើសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃ។



ព្រះយេស៊ូ មានព្រះបន្ទូលជាពាក្យប្រស្នា ដើម្បីណែនាំឲ្យធម្មាចារ្យដែលកំពុងស្តាប់ព្រះអង្គបានទទួលការអប់រំនិងដើម្បីគេប្រែចិត្ត។ ក្នុងពាក្យប្រស្នានេះ យើងឃើញមានបួនក្រុមគឺ៖ ទីមួយ គឺជាអ្នក ដែលវាយអ្នកដំណើរ ជានិមិត្តរូបនៃអំពើអាក្រក់ ដែលមាននៅក្នុងពិភពលោកយើង ដែលយើងរាល់គ្នាតែងតែជួប។ ច្រើនដងយើងមិនសូវចាប់អារម្មណ៍នឹង ក្រុមនេះទេ។ ដូចខ្ញុំបាននិយាយអំពីម៉ាកូប៉ាំ ទោះបីគាត់បានភ្ជាប់ខ្លួនជាមួយព្រះយេស៊ូតាមរបៀបយ៉ាងពិសេស ដោយទទួលព្រះកាយព្រះគ្រីស្តក៏ដោយ ក៏មារសាតាំង ដែលជាសភាវៈអាក្រក់បានវាយគាត់ជាច្រើនដង។សន្តៈយ៉ូហានម៉ារីវីយ៉ាណេក៏បានជួបច្រើនដងដែរ ជាមួយមារសាតាំង ដែលវាយរូបលោក។ ទីពីរ គឺជាក្រុមមេដឹកនាំសាសនា ជាអ្នកដែលដើរហួសពេលគេឃើញអ្នករបួសដេកនៅតាមផ្លូវ។ ទីបី គឺជាសាសន៍សាម៉ារីដែលគេចាត់ទុកថាជាសាសន៍ដទៃ និងទីបួន គឺជា ក្រុមជនរងគ្រោះ។ តាមពាក្យប្រស្នានេះ ព្រះយេស៊ូចង់បង្ហាញ អំពីសភាពការណ៍របស់មនុស្សយើង ដែលមានតាំងពីដើម រៀងមករហូតដល់សព្វថ្ងៃនេះ គឺនៅក្នុងសង្គមតែងមានមនុស្សចិត្តអាក្រក់ ប្រើអំណាចជិះជាន់គេ មិនរវីរវល់នឹងអ្នកតូចតាច អ្នកដែលកំពុងអស់សង្ឃឹម ជាក្រុមមនុស្សដែលបង្កបញ្ហា ធ្វើឲ្យអ្នកឯទៀតទទួលរងគ្រោះ និងក៏មានក្រុមមនុស្សដែលមាន ចិត្តអាណិតមេត្តាដែរ គឺគេចេះមើលឃើញពីទុក្ខលំបាករបស់អ្នកដទៃ។ ពាក្យប្រស្នានេះជានិមិត្តរូបយ៉ាងច្បាស់អំពីសង្គម នៅគ្រប់ទីកន្លែង តាំងពីដើមរៀងមករហូតដល់សព្វថ្ងៃ។

ចំណុចទីមួយ ពេលនេះគួរឲ្យយើងចាប់អារម្មណ៍ដល់តួអង្គពីរ គឺជនជាតិសាម៉ារី និង ជនរងគ្រោះ។ ជាច្រើនដង យើងនិយាយថា តួអង្គសាសន៍សាម៉ារីជានិមិត្តរូបអំពីព្រះយេស៊ូ ដែលអាណិតមេត្តាដល់ជនរងគ្រោះ។ ប៉ុន្តែតាមការពិត ជនរងគ្រោះ ក៏ជានិមិត្តរូបរបស់ព្រះយេស៊ូដែរ គឺវត្តមានរបស់ព្រះយេស៊ូនៅក្នុងក្រុមទាំងពីរនេះ។ សំណួរដែលយើងត្រូវតែ សួរចំពោះខ្លួនយើងម្នាក់ៗនៅក្នុងពេលអធិដ្ឋាន គឺថា៖ តើរាល់ថ្ងៃខ្លួនខ្ញុំផ្ទាល់នៅក្នុងក្រុមណា?។ កុំឲ្យគិតភ្លាមៗថា យើងគ្រាន់តែជាសាសន៍សាម៉ារីប៉ុណ្ណោះ ប៉ុន្តែ ជួនកាលយើងក៏ដូចក្រុមទី១ ដែរ គឺយើងជាអ្នកមានអំណាច ដែលគិតតែពី ធ្វើការងាររបស់ខ្លួនប៉ុណ្ណោះ យើងមិនមើលដល់ទុក្ខលំបាករបស់អ្នកដទៃដែលនៅជុំវិញយើងទេ។ជួនកាលទៀតយើងក៏ដូច ក្រុមទី ២ ជាក្រុមលេវីជាសាសន៍យូដាដែលធ្វើដំណើរទៅព្រះវិហារនៅក្រុងយេរូសាឡឹមដែរ។ ពួកគាត់រវល់នឹងកិច្ចការ របស់ពួកគាត់ខ្លាំងណាស់ និងតាមវិន័យ ពួកគាត់មិនអាចប៉ះឈាមបានទេ។ យើងជាបូជាចារ្យ ប្រហែលពេលខ្លះយើងដូចពួកគាត់ ដោយសារយើងមានគេណាត់ជួបជាច្រើន ហើយជួនកាល បណ្តាលឲ្យយើងខកខានលើកទូរស័ព្ទរបស់បងប្អូនឯទៀតៗ ដែលមានបំណងជួបនិយាយជាមួយយើងដែរ។ ក្រុមទី ៣ គឺជាសាសន៍សាម៉ារីជានិមិត្តរូបនៃព្រះសហគមន៍ ដែលចេះមើលថែជនរងគ្រោះ យកចិត្តទុកដាក់នឹងជនទាំងឡាយ ដែលអស់

សង្ឃឹម គឺជាព្រះសហគមន៍ដែលរវីរវល់នឹងអ្នកតូច តាច ដែលឱនខ្លួនទៅបម្រើអ្នកក្រីក្រដែលជាព្រះយេស៊ូតែម្តង។ ក្រុមទី ៤ គឺជាជនរងគ្រោះ ជាអ្នកដែលគ្មានទីពឹងនៅក្នុង សង្គម។ សន្តៈ អូហ្គូស្តាំង នៅពេលគាត់អានអត្ថបទនេះ គាត់មានប្រសាសន៍ថា ជនរងគ្រោះគឺជាព្រះយេស៊ូផ្ទាល់។ តាម អត្ថន័យនេះ ណែនាំឲ្យយើងនឹកឃើញដល់ព្រះយេស៊ូដែលរងទុក្ខលំបាកនៅលើឈើឆ្កាង ដោយសារអំពើបាបរបស់មនុស្ស យើង ហើយក៏រំឭកឲ្យយើងភ្ញាក់ស្មារតីថា នៅពេលណាយើងបានជួយអ្នកតូចតាចណាម្នាក់ នោះបីដូចជាយើងបានជួយព្រះយេស៊ូដែរ។ សេចក្តីនេះជួយឲ្យយើងជាព្រះសហគមន៍ មានចិត្តគំនិតថ្មីចំពោះវត្តមានរបស់អ្នកតូចតាច ដែលយើង បានជួប។យើងក៏ដូចជាសាសន៍សាម៉ារីក៏ដូចនាងវេរ៉ូនីកាដែលជូតព្រះភ័ក្ត្រព្រះយេស៊ូនៅពេលព្រះអង្គលីឈើឆ្កាងដែរ។ ព្រះយេស៊ូបានប្រមូលទុក្ខលំបាកទាំងអម្បាលម៉ាន មកនៅក្នុងព្រះភ័ក្ត្ររបស់ព្រះអង្គយើងដូចនាងវេរ៉ូនីកា ដោយសារយើងជូត ព្រះភ័ក្ត្រព្រះអង្គ នៅក្នុងចំណោមអ្នកតូចតាចឬ នៅក្នុងចំណោមអ្នកធំដែលអស់សង្ឃឹមដែរ នេះជាគ្រឹះនៃព្រះសហគមន៍ យើង។

ចំណុចទីពីរ តើធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍យើងទៅជាព្រះសហគមន៍ក្រីក្រ បម្រើអ្នកក្រីក្រយ៉ាងពិតប្រាកដ។ នៅក្នុងអត្ថបទ (លូកា ៦,២០) ព្រះយេស៊ូងើបព្រះភ័ក្ត្រទតទៅសាវ័ករបស់ព្រះអង្គ ហើយមានព្រះបន្ទូលថា ៖ អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់។ នេះជាផ្លូវ ដែលព្រះសហគមន៍អញ្ជើញយើងឲ្យដើរតាម ដើម្បីឲ្យព្រះសហគមន៍ក្រីក្របម្រើអ្នកក្រីក្រ។ នៅពេលព្រះយេស៊ូ ឃើញមហាជនកំពុងប្រព្រឹត្តគ្រប់កិច្ចការ កំពុងឈឺ កំពុងយំ ឬ កំពុងសប្បាយចិត្ត នោះព្រះអង្គបានទតទៅគេ ដោយព្រះហឫទ័យទុកដាក់ ដែលមានន័យថាព្រះអង្គចាប់អារម្មណ៍នឹងគេ ដែលប្លែកពីសង្គមដែលមិនចង់មើលគេសោះ។ ព្រះអង្គមានព្រះហឫទ័យអាណិតដល់គេ ហើយមានព្រះបន្ទូលថា៖ អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ អ្នកមានសុភមង្គល ហើយដែលណែនាំឲ្យគេឆ្ងល់ថា ហេតុអ្វីក្រខ្សត់បែរជាមានសុភមង្គលទៅវិញ? តាមពិតគេមានសុភមង្គលដោយសារគេ"បានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់"។សេចក្តីប្រកាសអំពី"លក្ខណៈរបស់អ្នកទទួលសុភមង្គល" នេះ គឺជាកូនសោនៃគម្ពីរដំណឹងល្អ ជាកិច្ចការដែលព្រះ យេស៊ូបានប្រព្រឹត្ត ជាកូនសោដើម្បីបើកជីវិតយើងទៅជាគ្រីស្តបរិស័ទ។ពាក្យក្រីក្រក្នុងសេចក្តីប្រកាសនេះមានអត្ថន័យពីរ យ៉ាងគឺ ទីមួយ ជាអ្នកក្រីក្រដែលខ្វះទីពឹងគ្មានអាហារ ប៉ុន្តែ " អ្នកនោះមានសុភមង្គលហើយ" ដោយសារព្រះយេស៊ូ បានមានព្រះបន្ទូលដំណឹងល្អដល់ពួកគេផ្ទាល់ ហើយព្រះបន្ទូលដំណឹងល្អនោះ ណែនាំឲ្យមនុស្សទាំងអស់មិនបំភ្លេចដល់ ពួកគេ និងណែនាំឲ្យគេមានសេចក្តីសង្ឃឹមថ្មី។តើអត្ថបទនេះជំរុញឲ្យយើងធ្វើដូចម្តេចដើម្បីឲ្យអ្នកក្រីក្រអ្នកគ្មានទីពឹងគ្មានអាហារបរិភោគ មានសេចក្តីសង្ឃឹមវិញ ដោយសារគេបានស្តាប់ដំណឹងល្អពីព្រះសហគមន៍?។ សម្តេចប៉ាបបេណេឌីកតូទី ១៦ បានសរសេរសារលិខិតក្នុងរង្វង់ចាំថា៖ " កិច្ចការនៃធម៌មេត្តាករុណាដ៏ខ្ពង់ខ្ពស់បំផុត ដែលគ្រីស្តបរិស័ទអាចធ្វើបានគឺប្រកាសដំណឹងល្អ"។ពេលយើងគិតអំពីកិច្ចការនៃធម៌មេត្តាករុណាជួនកាលយើងប្រទ្បំថា យើងត្រូវជួយគេតែខាងសម្ភារៈផ្សេងៗប៉ុណ្ណោះ។ ប៉ុន្តែសម្តេចប៉ាបបានមានប្រសាសន៍យ៉ាងច្បាស់ថា គឺ"ប្រកាស ដំណឹងល្អ"។"អ្នកណាជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ"ដោយសារនៅថ្ងៃនោះ អ្នកនោះបានជួបជាមួយព្រះយេស៊ូ ប៉ុន្តែនៅថ្ងៃនេះ គេបានជួបជាមួយព្រះសហគមន៍ដែលបានប្រកាសអំពីសេចក្តីសង្ឃឹមដល់គ នាំឲ្យគេលែងនៅម្នាក់ឯង គេមានកន្លែងមួយដែលស្វាគមន៍ ដែលស្រឡាញ់គេដែលលើកទឹកចិត្តដល់គេ គឺយើងដែលបានប្រកាស និងប្រព្រឹត្ត តាមព្រះបន្ទូលរបស់ព្រះយេស៊ូដល់គេ។

ក្នុងអត្ថបទដែលយើងបានស្តាប់ នៅពេលចាប់ផ្តើមអធិដ្ឋាន នោះបែងអំពីអ្នកសូមទាន កាលដែលគាត់ឃើញ លោកសិលាកំពុងសម្លឹងមើលទៅគាត់ នោះគាត់ក៏លាតដៃទាំងពីរចាំទទួល ដោយសង្ឃឹមថា លោកសិលានឹង ឲ្យលុយទៅគាត់។ ប៉ុន្តែ លោកសិលាមិនបានឲ្យលុយទៅគាត់ដូចគាត់សង្ឃឹមទេ លោកមានប្រសាសន៍ថា៖ ខ្ញុំគ្មានមាសគ្មានប្រាក់ជូន អ្នកទេ តែអ្វីដែលខ្ញុំមានដោយព្រះនាមព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត នោះ ខ្ញុំសូមជូនទៅអ្នក គឺសូមឲ្យអ្នកក្រោកឈរឡើង។ សម្តេចប៉ាបក៏មានប្រសាសន៍ដូចនេះច្រើនដងដែរ។ ពេលសម្តេចប៉ាបទៅជួបអ្នកក្រីក្រនៅទីក្រុងរីយ៉ូ ពាក្យទីមួយ ដែលសម្តេចមានប្រសាសន៍ទៅកាន់ពួកគាត់គឺ៖ ខ្ញុំគ្មានមាស គ្មានប្រាក់អ្វីទេ តែអ្វីដែលខ្ញុំមានដោយនាមព្រះយេស៊ូ ជាអ្នក ភូមិណាសារ៉ែត នោះខ្ញុំសូមជូនទៅអ្នក សូមអ្នករាល់គ្នាក្រោកឈរឡើង។

ទីពីរ " អ្នកណាជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ " សម្រាប់យើងទាំងអស់គ្នាវិញគឺ យើងត្រូវការដូរ ចិត្តគំនិតរបស់យើង ដោយលះបង់បោលអ្វី ដែលណែនាំឲ្យយើងទៅជាអ្នកមាន។ សេចក្តីនេះ មិនបានន័យថា យើងត្រូវតែជាអ្នកក្រីក្រដែលខ្វះម្ហូប អាហារឬរស់នៅក្នុងផ្ទះ ដែលគ្មានដំបូលនោះ ទេ អ្នកណាក៏ចង់មាន ដំបូលស្នាក់នៅនិង មានម្ហូបអាហារ គ្រប់គ្រាន់ដែរប៉ុន្តែ សេចក្តីនេះ មានអត្ថន័យ ខាងផ្លូវវិញ្ញាណ គឺឲ្យយើងលះបង់បោល គំនិតសម្ភារៈ និយម ឲ្យយើង លះបង់បោលចិត្តជាអ្នកមាន ដែលមិនបេះយកចិត្ត ទុកដាក់នឹង អ្នកដទៃ។ យើងធ្វើយ៉ាងម៉េច កុំឲ្យការរស់នៅយ៉ាងស្រួល របស់យើង នាំឲ្យ យើងលែ ងនឹកឃើញដល់អ្នកដទដៃលែកំពុងវេទុក្ខ ឲ្យយើងគេចមុខ មិនឲ្យគេជួប។ ប៉ុន្តែតម្រូវឲ្យយើងបើកដួងចិត្ត ឲ្យទូលាយ ស្វាគមន៍គេ ឲ្យយើងរីវរស់ជាមួយគេវិញ។ យើងមាន ឧទាហរណ៍ជាក់ស្តែង ខ្លះ ដូចជាលោកឪពុកសុន ជាគំរូមួយ ក្នុងការស្វាគមន៍ ក្នុងការទទួលភ្ញៀវគ្រប់ៗគ្នា។ នេះជា របៀបដ៏អស្ចារ្យ ដែលព្រះយេស៊ូបានណែនាំយើង ហើយសន្ត បុគ្គលខ្លះក៏បានមានប្រ សាសន៍បញ្ជាក់ថា៖ ជីវិតក្រីក្រ របស់ខ្ញុំជាទ្រព្យសម្បត្តិរបស់ខ្ញុំ។



ក្នុងអត្ថបទ (លក ១៨,២២) មានបុរសអ្នកមាន ម្នាក់ទូលសួរព្រះយេស៊ូថា តើត្រូវធ្វើដូចម្តេច ដើម្បីមានជីវិត អស់ កល្បជានិច្ច។ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់មានបីចំណុចគឺ ទីមួយ " អញ្ជើញទៅលក់អ្វីៗទាំងអស់ដែលអ្នកមាន "។ ព្រះបន្ទូលនេះមានឥទ្ធិពលក្នុងការរស់នៅរបស់យើងក្នុងព្រះសហគមន៍ គឺព្រះយេស៊ូត្រាស់ហៅយើងប្លែកពីគ្នា ឧទាហរណ៍ បូជាចារ្យបម្រើភូមិភាគ មិនដូចបូជាចារ្យសាលដឺភូកូ ដែលបូជាចារ្យម្នាក់ៗបានលះបង់បោលអ្វីៗទាំងអស់ ហើយទៅរស់នៅ យ៉ាងសាមញ្ញ ទាំងគ្មានអ្វីសោះ នៅឯវាលខ្សាច់សាហារ៉ា ដូចព្រះយេស៊ូដែលរស់នៅទីក្រុងណាសារ៉ែត យ៉ាងសាមញ្ញដ៏ កំពូលដូច្នោះដែរ។ យើងមានការត្រាស់ហៅផ្សេងៗគ្នា ហើយ យើងឆ្លើយតបដោយមានសេរីភាពពីខាងក្នុងខ្លួនយើងម្នាក់ៗ ។ ទីពីរ " សូមចែកទានដល់អ្នកក្រីក្រ " គឺព្រះអង្គសូមឲ្យយើងស្វាគមន៍ យកចិត្តទុកដាក់ស្តាប់ ដោយចូលរួម ដោយលើក ទឹកចិត្តគេជានិច្ច... និង ទីបី " រួចហើយសូមអញ្ជើញមកតាមខ្ញុំ គឺព្រះយេស៊ូ អញ្ជើញយើងឲ្យនៅជាមួយព្រះអង្គ ក្នុងនិមិត្តរូបព្រះអង្គជាជនសាម៉ារី ដែលជួយសង្គ្រោះ និង ជាជនរងគ្រោះដែលត្រូវការការសង្គ្រោះដែរ។

មូលដ្ឋានគ្រឹះដែលខ្ញុំឲ្យព្រឹកមិញនេះ ប្រហែលអាចជួយគ្រីស្តបរិស័ទយើង ឲ្យគិតអំពីរបៀបដែលយើងត្រូវបម្រើអ្នកក្រីក្រ។ ព្រះសហគមន៍កាតូលិកយើងជួបឧបសគ្គ ក្នុងការជួយអ្នកក្រីក្រក្នុងសង្គមដើម្បីបង្ហាញថាយើងជាព្រះសហ គមន៍មួយដែលក្រជួយអ្នកក្រីក្រ។ ឧបសគ្គមកពីមានវប្បធម៌ថ្មីមួយបានកើតឡើងជិត ៣០ឆ្នាំហើយ បន្ទាប់ពីសម័យ ប៉ុលពត គឺះ ទីមួយ តាំងពីឆ្នាំ ១៩៩០ មក ប្រទេសកម្ពុជាបានទីពឹងលើអង្គការមនុស្សធម៌ និងលើប្រទេសនានា ដូចជា សហរដ្ឋអាមេរិក ជប៉ុន ចិន និងសហគមន៍អឺរ៉ុបជាដើម ហើយតាំងពីនោះមក ទាំងរដ្ឋអំណាចទាំងប្រជាជន មានទម្លាប់ ទីពឹងលើគេ។ រាល់ឆ្នាំរដ្ឋាភិបាលទទួលលុយជាង ៨០% មកពីបរទេស ហើយអង្គការមនុស្សធម៌នៅស្រុកខ្មែរមានជាង ៣០០០។

ប្រទេសនេះមានអង្គការដ៏ច្រើន ដែលខុសប្លែកពីប្រទេសជប៉ុនកាលពីគេបានចាញ់សង្គ្រាមលោកលើកទីពីរ។ កាលនោះសេដ្ឋកិច្ចប្រទេសជប៉ុនបានធ្លាក់ចុះដល់សូន្យ ហើយប្រទេសនេះគ្មានទ្រព្យសម្បត្តិធម្មជាតិអ្វីទេ មានផ្ទៃដីសម្រាប់ រស់នៅតូចចង្អៀត។ ប៉ុន្តែក្រោយសង្គ្រាមពីឆ្នាំ ១៩៤៥ ដល់ ១៩៦៤ ប្រទេសនេះបានរីកចម្រើនយ៉ាងខ្លាំង ដោយសារគេ បានពឹងផ្អែកជាសំខាន់ ទៅលើធនធានមនុស្សរបស់គេ។ នៅទីនេះយើងមានអង្គការ និងអ្នកជួយមកពីខាងក្រៅច្រើន មែនទែន ដូច្នេះយើងមានទម្លាប់មួយគឺរង់ចាំឲ្យគេជួយឧបត្ថម្ភ ដែលនេះជាការលំបាកមួយដល់ព្រះសហគមន៍របស់យើង ដោយសារមានមនុស្សជាច្រើននៅតែទន្ទឹងរង់ចាំឲ្យព្រះសហគមន៍ជួយឧបត្ថម្ភដល់គេ។

ដូច្នេះ នៅតាមព្រះសហគមន៍ក្នុងភូមិនានា យើងត្រូវធ្វើយ៉ាងណាឲ្យគ្រីស្តបរិស័ទយល់ថា យើងត្រូវតែរួមគ្នាកសាង ព្រះសហគមន៍របស់យើងដែលក្រដើម្បីជួយដល់អ្នកក្រីក្រ។ ការជួយអ្នកក្រីក្រ មិនមែនជាលោកអភិបាលត្រូវទៅប្រទេស បារាំង ប្រទេសកាណាដា ឬប្រទេសនានាដើម្បីប្រមូលលុយមកជួយឧបត្ថម្ភព្រះសហគមន៍យើង ឬដើម្បីជួយអ្នកក្រីក្រនោះទេ ប៉ុន្តែត្រូវការចេញពីយើងច្រើនជាង។ យើងមានឧទាហរណ៍មួយជាក់ស្តែងដែលជាសញ្ញាមួយយ៉ាងពិសេសគឺនៅព្រៃកប្បាស់លោកឪពុកអានបានសាងសង់ព្រះវិហារមួយដោយធ្វើពីដីឥដ្ឋ។ ជាច្រើនអាទិត្យ មានយុវជនមកពីព្រៃកប្បាស់ ផ្ទាល់ មកពីស្វាយប៉ាក មកពីក្រុមបេះដូងសាវ៉ែកបានចូលរួមជួយក្នុងការសាងសង់។ ធ្វើដូចនេះ ជាការល្អមែនទែន ដោយសារព្រះវិហារនេះបានចេញពីគ្រីស្តបរិស័ទខ្លួនឯងផ្ទាល់តែម្តង។ នេះជាព្រះសហគមន៍ថ្មី ដែលពឹងលើកម្លាំង និងលើអំណារ សប្បាយរបស់ក្រុមគេផ្ទាល់ និង បានប្រែវប្បធម៌ដែលទន្ទឹងរង់ចាំជំនួយពីគេ ទីពឹងលើគេ មកទីពឹងលើគ្នាឯងវិញ។

មួយទៀតគឺវប្បធម៌ " បក្សពួកនិយម " ដែលនិយមតែបងប្អូនខ្លួនឯង ជួយតែបក្សពួកខ្លួនឯងគេមិនរវល់នឹងនរណាផ្សេងទេ។ ការណ៍នេះ ក៏កើតមានយ៉ាងច្រើននៅក្នុងសង្គមរបស់យើង។ ឧទាហរណ៍មានជនខ្លះគេមិនរវល់នឹងសង្គមទេ គេធ្វើកិច្ចការដើម្បីសងគុណដល់មេរបស់គេតែប៉ុណ្ណោះ គឺមេរបស់គេដែលធ្លាប់បានជួយគេឲ្យមានជីវភាពធូរជា។ ដើម្បីបំភ្លឺ ហេតុការណ៍នេះ ព្រះយេស៊ូបានមានព្រះបន្ទូលថាៈ " ពេលអញ្ជើញភ្ញៀវហូបបាយ សូមកុំអញ្ជើញតែមិត្តសម្លាញ់ ឬអ្នកធំ ដែលគេនឹងអញ្ជើញអ្នកវិញ តែសូមអញ្ជើញអ្នកក្រីក្រដែលគេអញ្ជើញយើងវិញមិនបាន"។មានព្រះបន្ទូលជាច្រើនដែលបំភ្លឺឲ្យយើងជាព្រះសហគមន៍ ត្រូវធ្វើកិច្ចការដើម្បីបម្រើអ្នកក្រីក្រ ដោយយើងបម្រើគ្នាទៅវិញទៅមក ជួយគ្នាទៅវិញទៅមក ទីពឹងលើគ្នាទៅវិញទៅមក ក្នុងព្រះសហគមន៍របស់យើង។









ព្រះសហគមន៍គ្មានធនធាន តែបម្រើអ្នកក្រីក្រ៖ យើងមានគំនិតពីរ គឺទីមួយ ត្រូវអប់រំគ្រីស្តបរិស័ទឲ្យរស់នៅដូច ព្រះយេស៊ូ ដែលនាំមកនូវដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ដូច្នេះត្រូវមានសិក្ខាសាលាដើម្បីអប់រំយុវជនពីតួនាទីរបស់ពួកគេ ត្រូវអប់រំដល់គណៈកម្មការ និងគ្រូអប់រំជំនឿ... ត្រូវមានសំណាក់ធម៌ជាប្រចាំ មានពិធីតាំងព្រះកាយ និងអ្នកបម្រើព្រះ សហគមន៍ត្រូវធ្វើជាគម្រូដល់គ្រីស្តបរិស័ទ។ ទីពីរ ព្រះសហគមន៍ត្រូវតែយកចិត្តទុកដាក់បម្រើអ្នកក្រីក្រ និងអ្នកកើតទុក្ខ ត្រូវបម្រើអ្នកដែលគ្មានទីពឹង ត្រូវពង្រីកគណៈកម្មការសង្គហៈ ត្រូវអប់រំឲ្យយុវជន និងចាស់ៗឲ្យសហការគ្នា បង្កើតមូលនិធិមេត្តាករុណា កម្រិតភូមិភាគ ដើម្បីយើងអាចប្រមូលថវិការនៅក្នុងភូមិភាគទាំងមូល យកទៅជួយតាមកន្លែងផ្សេងៗ ដែលយើងត្រូវការ។ ត្រូវឲ្យមានទិវាតមអាហារ ដើម្បីគ្រីស្តបរិស័ទសន្សំថវិការជួយអ្នកក្រីក្រដោយសេចក្តីស្រឡាញ់ និងជំនឿ។ ពេលយើងធ្វើកិច្ចការទាំងនោះបានដោយរលូន ពេលនោះព្រះសហគមន៍របស់យើង នឹងទៅជាព្រះសហគមន៍ក្រីក្រ ដែលជួយអ្នកក្រីក្រ ដោយដឹងថា យើងម្នាក់ៗជាអ្នកកសាង។ អាម៉ែន!

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១១/០៩/២០១៣ពេលព្រឹក

**ពាក្យប្រស្នាអំពីអ្នកស្រុកសាម៉ារីម្នាក់មានចិត្តសប្បុរស**( លូកា១០, ៣០-៣៥ )

៣០ព្រះយេស៊ូមានព្រះបន្ទូលថា៖ មានបុរសម្នាក់ធ្វើដំណើរចុះ
ពីក្រុងយេរូសាឡឹម ឆ្ពោះទៅក្រុងយេរីខូ។ គាត់ធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់
ពួកចោរ វាប្លន់គាត់ថែមទាំងវាយដំគាត់ឲ្យរបួសជាទម្ងន់ រួចនាំគ្នារត់បាត់
អស់ទៅ ទុកគាត់ចោលនៅស្តូកស្តឹងបាត់ស្មារតីមិនដឹងខ្លួន។ ៣១ពេលនោះ
មានបូជាចារ្យ " មួយរូប ធ្វើដំណើរចុះតាមផ្លូវនោះ។ គាត់ឃើញបុរសនោះ
ក៏ដើរ វាងហួសទៅ។ ៣២មានម្នាក់ពីក្រុមលេវី " ដើរមកដល់កន្លែងនោះដែរ។
គាត់ឃើញបុរសនោះ ក៏ដើរវាងហួសទៅ។ ៣៣គាប់ជួនជាមានអ្នកស្រុកសា
ម៉ារីម្នាក់ ធ្វើដំណើរមកតាមផ្លូវនោះដែរ គាត់ឃើញបុរសនោះ គាត់មានចិ
ត្តអាណិតអាសូរពន់ពេកណាស់។ ៣៤គាត់ចូលទៅជិតអ្នករបួស យកប្រេង
និងស្រាចាក់ពីលើមុខរបួស រុំរបួសឲ្យ រួចគាត់លើកអ្នករបួសដាក់លើជំនិះ
របស់គាត់នាំទៅផ្ទះសំណាក់ ហើយថែទាំអ្នករបួសនោះ។ ៣៥ស្អែកឡើង
គាត់យកប្រាក់ប្រគល់ឲ្យម្ចាស់ផ្ទះសំណាក់ទាំងផ្តាំថា"សូមថែទាំបុរសនេះផង
ប្រសិនបើអ្នកចំណាយលើសពីប្រាក់នេះ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងជូន
បង្គ្រប់"។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១១/០៩/២០១៣ពេលព្រឹក

## សុភមង្គល និង អពមង្គល

( លូកា៦, ២០-២៣ ម៉ាថាយ ៥, ១-១២ )

[20]ព្រះយេស៊ូងើបព្រះភ័ក្ត្រ ទតមើលសាវ័ករបស់ព្រះអង្គ ហើយ
មានព្រះបន្ទូលថា៖ អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ! អ្នកមានសុភមង្គល
ហើយ ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់។ [21]អ្នករា
ល់គ្នាដែលកំពុងតែស្រេកឃ្លានអើយ! អ្នកមានសុភមង្គលហើយដ្បិតអ្នក
រាល់គ្នានឹងបានឆ្អែត។ អ្នករាល់គ្នាដែលកំពុងតែយំសោកអើយ! អ្នកមាន
សុភមង្គលហើយនដ្បិតអ្នករាល់គ្នានឹងបានត្រេកអរ។ [22]ប្រសិនបើមានគ
ស្អប់លែងរាប់រកអ្នករាល់គ្នា ប្រសិនបើគេត្មះតិះដៀលបង្ខូចឈ្មោះអ្នករាល់
គ្នាព្រោះតែបុត្រមនុស្ស អ្នករាល់គ្នាមានសុភមង្គលហើយ។ [23] នៅគ្រា
នោះចូរមានអំណរសប្បាយឡើងដ្បិតអ្នករាល់គ្នាទទួលរង្វាន់យ៉ាងធំនៅស្ថាន
បរមសុខ។ កាលពីជំនាន់មុន បុព្វបុរសរបស់គេក៏បានប្រព្រឹត្ត បំពោះពួក
ព្យាការីដូច្នោះដែរ។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១១/០៩/២០១៣ពេលព្រឹក

## អ្នកមានម្នាក់ចង់បានជីវិតអស់កល្បជានិច្ច

( លូកា១៨,១៨-១៥ ម៉ាថាយ ១៩, ១៦-៣០ ម៉ាកុស ១០, ១៧-៣១ )

១៨មាននាម៉ឺនម្នាក់ទូលសួរ ព្រះយេស៊ូថា៖ លោកគ្រូដ៏សប្បុរស
អើយ! តើខ្ញុំត្រូវធ្វើអ្វីដើម្បីឲ្យបានទទួលជីវិតអស់កល្បជានិច្ច ទុកជាមត៌ក?។
១៩ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ ហេតុអ្វីបានជាលោកថា ខ្ញុំសប្បុរស
ដូច្នេះ? ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ គ្មាននរណាម្នាក់សប្បុរសឡើយ។
២០លោកស្គាល់វិន័យ*ស្រាប់ហើយថា "កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់
មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំនិយាយកុហកធ្វើឲ្យគេមានទោស ចូរគោរព
មាតាបិតា"។ ២១បុរសនោះទូលព្រះយេស៊ូថា "ខ្ញុំបានប្រតិបត្តិតាមវិន័យទាំង
នេះតាំងតែពីក្មេងមក"។ ២២ព្រះយេស៊ូឮដូច្នេះទ្រង់មានព្រះបន្ទូលថា៖ នៅ
សល់កិច្ចការមួយទៀតដែលលោកមិនទាន់ធ្វើ គឺត្រូវយកអ្វីៗទាំងអស់ដែល
លោកមានទៅលក់ ហើយចែកឲ្យជនក្រីក្រ។ ធ្វើដូច្នេះលោកនឹងបានសម្បត្តិ
សួគ៌ រួចសឹមអញ្ជើញមកតាមខ្ញុំចុះ។ ២៣ពេលនាម៉ឺននោះឮដូច្នេះ គាត់ព្រួយ
ចិត្តយ៉ាងខ្លាំង ដ្បិតគាត់ជាអ្នកមានស្ដុកស្ដម្ភ។ ២៤កាលព្រះយេស៊ូឃើញ
គាត់ព្រួយចិត្ត ព្រះអង្គមានព្រះបន្ទូលថា៖ អ្នកមានពិបាកនឹងចូលទៅក្នុង
ព្រះរាជ្យ* ព្រះជាម្ចាស់ណាស់២៥សត្វអូដ្ឋចូលតាមប្រហោងម្ជុលងាយជាង
អ្នកមានចូលក្នុងព្រះរាជ្យព្រះជាម្ចាស់ទៅទៀត។



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម

## ១១/០៩/២០១៣ (រសៀល)

ជម្រាបសួរបងប្អូនជាទីស្រឡាញ់!

យើងខ្ញុំសូមអរព្រះគុណព្រះបិតា សម្រាប់ពេលវេលាពេញមួយអាទិត្យនេះ ដែលព្រះអង្គប្រទានឲ្យយើង។ សូមព្រះ អង្គជួយឲ្យយើងខ្ញុំបន្តយកចិត្តទុកដាក់នៅក្នុងការអធិដ្ឋាន និងបង្កើតទំនាក់ទំនងជាមួយព្រះអង្គដែលជាជីវិតរបស់យើងខ្ញុំ។

"ពេលនោះភរិយារបស់លោកសេបេដេ បាននាំកូនទាំងពីរចូលមកគាល់ក្រាបទាបព្រះបាទចង់ទូលសុំអ្វីមួយ ព្រះយេស៊ូមានព្រះបន្ទូលសួរគាត់ថា អ្នកចង់បានអ្វី? នាងទូលព្រះអង្គវិញថា ដល់ពេលព្រះអង្គគ្រងរាជ្យ សូមឲ្យកូនរបស់ខ្ញុំម្ចាស់ បានអង្គុយអមព្រះអង្គផង គឺម្នាក់នៅខាងស្តាំ ម្នាក់នៅខាងឆ្វេង។ ព្រះយេស៊ូមានព្រះបន្ទូលបតទៅនាងវិញថា អ្នកមិនដឹងខ្លួនទូលសុំអ្វីឡើយ តើអ្នកទាំងពីរអាចទទួលពែងដែលខ្ញុំត្រូវទទួលនោះបានឬទេ?។ លោកយ៉ាកុប និងលោក យ៉ូហានបានទូលថា យើងខ្ញុំអាចទទួលបាន។ ព្រះអង្គមានព្រះបន្ទូលទៅអ្នកទាំងពីរថាអ្នកអាចទទួលពែងរបស់ខ្ញុំបានមែនតែចំណេកឯការអង្គុយនៅតាមខ្ញុំនោះខ្ញុំមិនអាចសម្រេចបានឡើយ ព្រោះកន្លែងនោះ បម្រុងទុកសម្រាប់អស់អ្នកដែលព្រះបិតារបស់ខ្ញុំ បានសម្រេចឲ្យប៉ុណ្ណោះ។ អាម៉ែន។"

ប្រធានបទនៅពេលរសៀលនេះ គឺៈ " ព្រះសហគមន៍សន្ទនា " ដែលជួយឲ្យយើងរួមជាមួយគ្នាកសាងព្រះសហ គមន៍របស់យើង។ ព្រឹកមិញយើងបានរិះគិតអំពី " ព្រះសហគមន៍ក្រីក្រ តែបម្រើអ្នកក្រីក្រ" គឺព្រះសហគមន៍របស់យើងត្រូវការនៅជាមួយអ្នកក្រីក្រ ដែលតម្រូវឲ្យព្រះសហគមន៍ កែប្រែចិត្តគំនិតដើម្បីទៅជាព្រះសហគមន៍ក្រីក្រ បម្រើអ្នកក្រីក្រ។ តាមការពិត ព្រះសហគមន៍របស់យើង ជាព្រះសហគមន៍ដ៏វិសុទ្ធ ដោយសារជាព្រះសហគមន៍របស់ព្រះជាម្ចាស់ ក៏ប៉ុន្តែ ព្រះសហគមន៍គឺជាយើងម្នាក់ៗ ដែលយើងម្នាក់ៗមិនទាន់វិសុទ្ធដ៏កំពូលនោះទេ ដូច្នេះពេលដែលមនុស្សឯទៀតៗ និងពិភពលោកសម្លឹងមកយើងគេមិនឃើញព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ទេ តែគេឃើញយើងម្នាក់វិញៗ គេឃើញនូវអ្វីៗដែលយើងបានធ្វើទាំងល្អ និងមិនល្អដែរ។ នេះជាបញ្ហាដែលយើងត្រូវប្រយ័ត្ន ដោយដឹងខ្លួនថា ប្រសិនបើអ្នកដទៃមើលឃើញយើងប្រព្រឹត្តខុស នោះគេមុខជាមិនចូលចិត្តនឹងព្រះសហគមន៍ទេ។ ដូច្នេះយើងម្នាក់ៗ ត្រូវតែកែប្រែចិត្តគំនិត ដើម្បី ឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមណ៍ដ៏វិសុទ្ធថែមទៀត។

ព្រឹកមិញនេះ យើងបានចាក់សរសរគ្រឹះមួយ គឺ " ព្រះសហគមន៍ក្រីក្រ បម្រើអ្នកក្រីក្រ "។ មានសរសរគ្រឹះមួយទៀត គឺៈ " ព្រះសហគមន៍សន្ទនា " នេះជាមូលដ្ឋានមួយសំខាន់ណាស់ ដើម្បីឲ្យយើងកសាងព្រះសហគមន៍របស់ព្រះយេស៊ូ យ៉ាងពិតប្រាកដមែន។ មុនយើងនិយាយអំពីព្រះសហគមន៍សូមឲ្យយើងនឹកឃើញដល់ព្រះយេស៊ូ នោះយើងនឹងអាចនឹក ឃើញអំពីរបៀបដែលយើងត្រូវបង្កើតព្រះសហគន៍។

តាមអត្ថបទគម្ពីរ យើងបានឃើញថា ព្រះយេស៊ូបានបង្កើតការ សន្ទនាជាមួយអ្នកដទៃយ៉ាងច្រើន។ របៀបដែលព្រះយេស៊ូសន្ទនាជាមួយគេ គឺដើម្បីឲ្យគេបង្ហាញពីសេចក្តីត្រូវការដ៏ពិតប្រាកដ ដែលមាននៅក្នុងចិត្តផ្ទាល់របស់គេ។ ខ្ញុំសូមលើកឧទាហរណ៍ពីរ ទីមួយ គឺការសន្ទនាជាមួយស្ត្រីសាសន៍សាម៉ារី និងទីពីរជាមួយលោកនីកូដេម។

យើងឃើញថា ក្នុងការសន្ទនា ព្រះយេស៊ូមិនប្រកាស មិនទេសនាទេ ព្រះយេស៊ូគ្រាន់តែសួរសំណួរដែលទាក់ទង នឹងការរស់នៅផ្ទាល់របស់ស្ត្រីសាម៉ារីនោះ។ ព្រះយេស៊ូចាប់ផ្តើមពីពាក្យធម្មតាទៅ គឺ " ខ្ញុំស្រេកទឹក" ក្រោយមកព្រះអង្គសួរ អំពីប្តីរបស់គាត់ ហើយសន្ទនាអំពីទឹក រហូតដល់ទឹកនោះជាទឹកដែលមានជីវិតអស់កល្បជានិច្ច។ បន្ទាប់មកទៀត ព្រះអង្គបង្ហាញថា គឺព្រះអង្គផ្ទាល់ដែលជាទឹកផ្តល់ជីវិតអស់កល្បជានិច្ចនោះ។ របៀបដែលព្រះយេស៊ូទាក់ទងជាមួយគេមិនមែន ជាទេសនាមួយ គឺព្រះអង្គបង្កើតការសន្ទនាដោយមានសំណួរចម្លើយទៅវិញទៅមក។ តាមពិត ព្រះយេស៊ូប្លែកពីយើង ដោយសារព្រះអង្គឈ្វេងយល់ចិត្តមនុស្ស ហេតុដូច្នេះហើយ បានជានៅពេលសន្ទនា ណែនាំឲ្យស្ត្រីសាសន៍សាម៉ារីនោះ ធ្វល់ជាខ្លាំងព្រោះនាងមិនដែលជួប ឬ ស្គាល់ព្រះអង្គពីមុនមកសោះ ហេតុអីក៏ព្រះអង្គដឹងថានាងមានប្តីច្រើនដូច្នេះ។

ទោះបីព្រះ យេស៊ូឈ្វេងយល់អំពីសេចក្តីត្រូវការរបស់មនុស្សអស់ហើយ ប៉ុន្តែព្រះអង្គត្រូវតែដើរជាមួយមនុស្ស ដើម្បីឲ្យមនុស្សបន្តិចម្តងៗ អាចរកឃើញដោយផ្ទាល់ខ្លួន នូវអ្វីដែលគេទន្ទឹងរង់ចាំយ៉ាងពិតប្រាកដនោះ។ ស្ត្រីសាសន៍សាម៉ារី ដែលទៅដងទឹកកាល មុនដំបូងនាងគ្មានគំនិតថាចង់បានទឹកអស់កល្បជានិច្ចពីព្រះយេស៊ូទេ ប៉ុន្តែនៅក្នុងទំនាក់ទំនង ដែលព្រះយេស៊ូបានបង្កើត ជាមួយគាត់ ណែនាំឲ្យគាត់រកឃើញថាជីវិតរបស់គាត់មិនសប្បាយទេ។ មូលហេតុដែលគាត់ទៅដងទឹកនៅម៉ោង ១២ ដោយសារជាពេលដែលក្តៅណាស់ គ្មានមនុស្សទៅដងទឹកទេ គាត់មិនចង់ជួបនឹងនរណាទេ ជីវិតរបស់គាត់មិនសប្បាយទេ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលប៉ះពាល់ដល់ជម្រៅនៃការពិបាករបស់គាត់ ណែនាំឲ្យគាត់រកឃើញសេចក្តីត្រូវការដ៏ពិតប្រាកដរបស់ខ្លួន គឺជីវិតថ្មី។ បន្ទាប់មកគាត់លែងខ្មាស លែងខ្លាចហើយ គាត់រត់ទៅភូមិដើម្បីប្រកាសប្រាប់អ្នកភូមិថា ឥឡូវ នេះគាត់រកឃើញព្រះមេស្ស៊ីហើយ។

និយាយអំពីលោកនីកូដេមដែលជាមនុស្សឆ្លាតពូកែម្នាក់ ពេលគាត់បានជួបជាមួយព្រះយេស៊ូ គាត់ក៏ចាប់ផ្តើមមានទំនាក់ទំនងល្អជាមួយព្រះអង្គរហូតដល់មានឱកាសសួរទៅព្រះអង្គថាតើធ្វើដូចម្តេចទើបគាត់អាចកើតសាជាថ្មី?។ ព្រះ យេស៊ូបំភ្លឺគាត់បន្តិចម្តងៗ តាមរបៀបដែលគាត់បាននិយាយ ណែនាំឲ្យគាត់ចូលបន្តិចម្តងៗទៅក្នុងជីវិតផ្ទាល់របស់គាត់ រហូតគាត់អាចរកឃើញសេចក្តីពិត គឺការសន្ទនា ទីមួយ រកឃើញអំពីសេចក្តីត្រូវការដ៏ជ្រៅដែលមាននៅក្នុងដួងចិត្តរបស់ គាត់ និងការសន្ទនា ទីពីរ ព្រះយេស៊ូមានព្រះបន្ទូលយ៉ាងច្រើន អំពីដំណោះស្រាយចំពោះបញ្ហាដែលមនុស្សជួបជាប្រចាំ ដោយមានគោលដៅតែមួយដដែលគឺព្រះអង្គណែនាំឲ្យគាត់រកឃើញសុភមង្គលដ៏ពិតប្រាកដដែលគាត់ត្រូវការ។ ដូច្នេះ នៅក្នុងការសន្ទនាព្រះយេស៊ូតែងជួយឲ្យអ្នកដែលអង្គុយសន្ទនាជាមួយព្រះអង្គ ទីមួយ ឲ្យគេទទួលស្គាល់ថាខ្លួនជានរណា? និងទីពីរ ជួយឲ្យគេ គិតពិចារណាចំពោះសំណួរដែលគេមាន។ យើងអាចនិយាយថា គ្រប់ពេល ព្រះយេស៊ូតែងតែធ្វើឲ្យការ សន្ទនារបស់ព្រះអង្គ ជាមួយអ្នកឯទៀតៗ ទៅជាវេទិកាដែលមនុស្ស និងព្រះជាម្ចាស់អាច ជួបជុំគ្នាគឺយើងជាមនុស្សជួបជុំគ្នា និងជួបជុំជាមួយព្រះជាម្ចាស់។ មានការសន្ទនាមួយទៀតរបស់ព្រះ យេស៊ូគឺជាការអធិដ្ឋាន ជាពេលដែលព្រះអង្គជួប សន្ទនាជាមួយនឹងព្រះបិតា។ ប្រសិនបើយើងមើលយ៉ូហាន ១៧

នោះយើងឃើញពីរបៀបព្រះយេស៊ូអធិដ្ឋាន ដែលបន្តិចម្តងៗ ព្រះអង្គចូលយ៉ាងជ្រៅទៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែលជាព្រះបិតា។ នៅពេលអធិដ្ឋានព្រះយេស៊ូបាន អធិដ្ឋានសម្រាប់ក្រុមសាវ័ក ហើយព្រះអង្គផ្ទាល់តែម្តងដែលទូលសន្ទនាទៅព្រះបិតា។ សន្តីតេរេសានៃទីក្រុងអាវីឡា និង សន្តអ៊ីញ៉ាសគាត់ទាំងពីរនាក់ មានរបៀបណែនាំយើងក្នុងការអធិដ្ឋាន គឺជួយ ឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងការសន្ទនារួមជាមួយព្រះព្រះយេស៊ូ ដូចព្រះអង្គដែលចូលយ៉ាងជ្រៅក្នុងការសន្ទនាជាមួយព្រះ ជាម្ចាស់ យ៉ាងដូច្នោះដែរ។ សន្តយ៉ូហានម៉ារីវីយ៉ាណេ គាត់បានឃើញកសិករម្នាក់ចូលក្នុងព្រះវិហាររាល់ថ្ងៃ អង្គុយអធិដ្ឋាន យូរម៉ោងគាត់សួរទៅកសិករនោះថា៖ " មូលហេតុអ្វីបានជារាល់ថ្ងៃ លោកមកអង្គុយក្នុងព្រះវិហារយ៉ាងយូរម៉ោងដូចនេះ?"កសិករនោះឆ្លើយថា៖"រាល់ពេលនៅទីនេះ ខ្ញុំសម្លឹងមើលព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏សម្លឹងមើលមកខ្ញុំវិញដែរ ហើយយើងសន្ទនាគ្នាទៅវិញទៅមក"។

ពេលយើងអធិដ្ឋានជាក្រុម ដោយយកអត្ថបទគម្ពីរមួយមករិះគិត មានម្នាក់អានហើយយើងនាំគ្នាស្តាប់ និងយើងនៅស្ងៀមស្ងាត់ ៥ នាទី ក្រោយមកម្នាក់ៗនិយាយតែមួយឃ្លាដែលខ្លួនពេញចិត្ត ហើយយើងស្តាប់គ្នាទៅវិញទៅមក យើង បំភ្លឺខ្លះៗអំពីមូលហេតុដែលយើងចូលចិត្តឃ្លានោះ។ នេះណែនាំឲ្យយើងរកឃើញអ្វីដែលថ្មីសម្រាប់ជីវិតរបស់យើង នេះជារបៀបនៃការសន្ទនាម៉្យាង ដោយស្តាប់គ្នាទៅវិញទៅមក និងដោយទទួលនូវសេចក្តីដែលបងប្អូនបាននិយាយ ដោយយក ព្រះគម្ពីរជាមូលដ្ឋានគ្រឹះ ដើម្បីឲ្យយើងទៅមុខ។ មនុស្សយើងត្រូវតែមានការសន្ទនា ត្រូវតែមានទំនាក់ទំនងរវាងគ្នានឹងគ្នា។ ប្រសិនបើគ្មានការសន្ទនាទេយើងក៏មិន អាចមានទំនាក់ទំនងគ្នាបានយ៉ាងពិតប្រាកដដែរ។ សង្គមតូចជាងគេ គឺក្រុមគ្រួសារឪពុកម្តាយជាមួយកូនប្តីជាមួយប្រពន្ធ ដែលត្រូវតែយកពេលវេលាដើម្បីសន្ទនាគ្នាឲ្យដឹងពីគ្នាទៅវិញទៅមក។ យើងឃើញអ្នកធ្វើការងារការទូត គេតែងតែខិតខំឲ្យ មានសន្ទនាគ្នានេះយ៉ាងខ្លាំង។ កន្លងមកសម្តេចប៉ាបក៏បានទេសនាយ៉ាងច្រើនអំពីការសន្ទនា គឺការសន្ទនារវាងសាសនា នឹងសាសនា។ យោងតាមឯកសាររបស់មហាសន្និបាតវ៉ាទីកង់ទីពីរ ព្រះសហគមន៍កាតូលិកបានផ្តើមការសន្ទនានេះតាំងពី ៥០ ឆ្នាំមកហើយ គឺព្រះសហគមន៍ទទួលស្គាល់ថាមានសេចក្តីពិតនៅក្នុងសាសនាដទៃដែរ ប៉ុន្តែយើងរកឃើញសេចក្តីពិតដ៏ពេញលក្ខណៈនៅក្នុងព្រះគ្រីស្ត។ ការសន្ទនារបស់ព្រះសហគមន៍ មានពីរចំណុចគឺ៖ ទីមួយ៖ " សន្ទនាផ្ទៃក្នុងព្រះសហគមន៍" គឺជារឿងផ្ទៃក្នុងនៅក្នុងព្រះសហគមន៍របស់យើង ដែលយើងត្រូវរៀបចំឲ្យ មានកន្លែងនិយាយគ្នា។ យើងត្រូវការមានទីប្រឹក្សាយ៉ាងពិតប្រាកដ ដើម្បីយើងសម្រេចចិត្តរួមជាមួយគ្នាចំពោះកិច្ចការផ្សេងៗ។ យើងត្រូវប្រុងប្រយ័ត្នអំពីរបៀបដែលយើងដឹកនាំការប្រជុំ នៅតាមព្រះសហគមន៍នីមួយៗ ត្រូវឲ្យមានចាស់ៗនិងយុវជនដែរ ហើយឲ្យយើងស្តាប់គ្នាទៅវិញទៅមក និង ត្រូវគិតជាមួយគ្នា ថាតើយើងត្រូវធ្វើអ្វីខ្លះ?។ នៅពេលលោកអ៊ីវ និងលោកអេមីល បង្កើតព្រះសហគមន៍សាជាថ្មីនៅប្រទេសកម្ពុជា នោះលោកបានរៀបចំគណៈកម្មការផ្សេងៗ មានគណៈ កម្មការថែរក្សាអប់រំជំនឿ គណៈកម្មការថែរក្សាធម៌មេត្តាករុណា និងគណៈកម្មការថែរក្សាពិធីបុណ្យ ហើយលោកបង្រួម ឲ្យទៅជាគណៈកម្មាធិការមួយដើម្បីរិះគិតយ៉ាងពិតប្រាកដ អំពីរបៀបដែលយើងថែរក្សាអប់រំជំនឿ ថែរក្សាធម៌មេត្តាករុណា ថែរក្សារៀបចំពិធីបុណ្យរួមជាមួយគ្នា។សព្វថ្ងៃគណៈកម្មការព្រះសហគមន៍ជាច្រើននៅខ្សោយ មានតែប៉ុន្មានព្រះសហគមន៍ប៉ុណ្ណោះដែលបានថែរក្សាពិតមែន។ ពេលយើងមានគណៈកម្មាធិការ មានទីប្រឹក្សានោះសំខាន់ណាស់ សូមឲ្យយើងយកចិត្ត

ទុកដាក់ថែរក្សារបៀបចាត់ចែងបម្រើព្រះសហគមន៍តាម របៀបដូចនេះតទៅទៀត ដើម្បីឲ្យគ្រីស្តបរិស័ទមានសម្លេង ឲ្យគ្រីស្តបរិស័ទមានគំនិតជួយគ្នាទៅវិញទៅមក ដោយមានមនុស្សគ្រប់វ័យចូលរួម ដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍ដែលចេះសន្ទនាកិច្ចការផ្ទៃក្នុងជាមួយគ្នា។

ដើម្បីថែរក្សាការសន្ទនានៅក្នុងផ្ទៃក្នុងនៃព្រះសហគមន៍ នោះសម្តេចប៉ាប បានបង្កើតក្រុមទីប្រឹក្សាថ្មីមួយដែលមាន លោកកាឌីណាល់មកពីទ្វីបទាំង ៥ និងមានបន្ថែមកាឌីណាល់ពីរ បីនាក់ទៀត សម្រាប់រិះគិតថាតើត្រូវធ្វើដូចម្តេចដើម្បីឲ្យ យើងរួមជាមួយគ្នាក្នុងការកសាងព្រះសហគមន៍ និងឲ្យយើងថែរក្សាកិច្ចការផ្ទៃក្នុងនៅក្នុងបុរីវ៉ាទីកង់ដែរ។ លោកកាឌី ណាល់ដែលមកពីទ្វីបទាំងប្រាំបានបញ្ចេញសម្លេង បញ្ចេញយោបល់ពីព្រះសហគមន៍នីមួយៗហើយលោកស្តាប់គ្នាទៅវិញទៅមក។លោកអភិបាលទាំងបីនៅប្រទេសកម្ពុជាយើងក៏បានរួមគ្នារិះគិតអំពីព្រះសហគមន៍តាមលក្ខណៈនេះដែរ។ ព្រះសហគមន៍របស់យើង បានខិតខំជិត ៥០ ឆ្នាំហើយ ដើម្បីឲ្យយើងសន្ទនាគ្នានៅក្នុងព្រះសហគមន៍។ ទោះបី យើងខ្វះធនធានមនុស្ស ប៉ុន្តែយើងត្រូវតែជំរុញអ្នកដែលមិនពូកែសោះ ឲ្យគេចូលរួមឲ្យគេយល់ថា មិនមែនតែលោកឪពុក ដែលត្រូវទទួលខុសត្រូវទាំងអស់ គឺឲ្យយើងសហការគ្នា ដោយឲ្យយើងសន្ទនា និង រិះគិតជាមួយគ្នាដូចព្រះយេស៊ូដែរ ។ ទីពីរ សព្វថ្ងៃព្រះសហគមន៍ក៏មានការសន្ទនាជាមួយពិភពលោកទៅវិញទៅមកដែរ ដោយទុកគ្នាជាបងប្អូន ប៉ុន្តែ មិនទាន់បានពេញលក្ខណៈតាមបច្ចេកទេសប៉ុន្មានទេ ប៉ុន្តែការសន្ទនានោះបានជ្រៅជាងមុន ដោយមនុស្សចេះរួបរួមគ្នាជាសហគមន៍។ ប្រសិនបើយើងមើលកាលពី ៥០ ឆ្នាំមុនដែលឥតមានទូរស័ព្ទដៃ ឥតមានទូរទស្សន៍តាមផ្ទះ នោះយើងឃើញថា ទំនាក់ទំនងនៃការសន្ទនាមិនបានពឹងផ្អែកលើតែបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែដោយពឹងផ្អែកលើការជួបជុំគ្នាជាសហគមន៍។ ប្រសិនបើមនុស្សមិនជួបជុំគ្នាជាសហគមន៍ទេ នោះទំនាក់ទំនងរបស់យើងមានបញ្ហាហើយ។ រួបរួមគ្នាជាសហគមន៍ ណែនាំបុគ្គលឲ្យមានទំនាក់ទំនងជាមួយគ្នា នេះជាអ្វីដែលព្រះសហគមន៍ចង់ថែរក្សា និងដែលយើងរស់នៅនា បច្ចុប្បន្នកាលនេះ ត្រូវរិះគិតថាតើយើងត្រូវធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍ ទៅជាកន្លែងមួយដែលជួបជុំគ្នា ដែលទទួលស្វាគមន៍ទាំងគ្រីស្តបរិស័ទ ទាំងមិនមែនគ្រីស្តបរិស័ទ ដើម្បីបង្កើតទៅជាសហគមន៍ ដែលសន្ទនាគ្នាអំពីប្រធានបទផ្សេងៗ តាមការត្រូវការរបស់យើង។ ខ្ញុំចង់បង្កើតក្រុមមួយ ដែលជារៀងរាល់ឆ្នាំ មាននិស្សិតកាតូលិក និង និស្សិតមិនមែនកាតូលិកជួបជុំគ្នារិះគិតអំពី ប្រធានបទមួយ ឬតាមប្រធានបទផ្សេងក៏បាន ឧទាហរណ៍ អំពីក្រុមគ្រួសារ ឲ្យគេទាំងអស់គ្នាគិតអំពីក្រុមគ្រួសារតាម ប្រវត្តិសាស្រ្ត ដែលមាននៅក្នុងប្រទេសកម្ពុជាយើង និងក្រោយមកក្រុមគ្រួសារតាមសង្គមបច្ចុប្បន្ននេះ និង ក្រុមគ្រួសារតាម ឥទ្ធិពលនៃសេដ្ឋកិច្ចនៅប្រទេសកម្ពុជា...។ ធ្វើរបៀបនេះនឹងជួយឲ្យយើងរិះគិត ជួយឲ្យយើងសន្ទនាគ្នា ដែលនាំឲ្យគេចាប់ អារម្មណ៍ថា ព្រះសហគមន៍របស់យើងទៅជាទីតាំងមួយជួយឲ្យមានការរិះគិត ដែលទាំងគ្រីស្តបរិស័ទ ទាំងមិនមែនជាគ្រីស្ត បរិស័ទរីកចម្រើនឡើងរួមជាមួយគ្នា។

ព្រះសហគមន៍បានរំឭកយើងថា ព្រះជាម្ចាស់បានត្រាស់ហៅមនុស្សឲ្យមានលក្ខណៈជាសង្គម៖ ទីមួយ យើងជា ក្រុមគ្រួសារមួយ ដែលមានព្រះជាម្ចាស់ជាព្រះបិតាបង្កើតមនុស្សទាំងអស់។ ព្រះអង្គប្រទានឲ្យប្រជាជាតិនានាកើតចេញ មកពីមនុស្សតែម្នាក់ ហើយឲ្យគេរស់នៅពាសពេញលើផែនដីទាំងមូល។ ព្រះ

សហគមន៍ត្រូវបានបង្កើតឡើងសម្រាប់គ្រីស្ត បរិស័ទផង និងសម្រាប់ទាក់ទងជាមួយបងប្អូនឯទៀតៗផង។ ដូច្នេះ យើងជាមហាគ្រួសារតែមួយដែលព្រះជាម្ចាស់បាន បង្កើត។ ទីពីរ ធម៌វិន័យរបស់យើងមានតែមួយ គឺស្រឡាញ់ព្រះជាម្ចាស់ និង ស្រឡាញ់អ្នកដទៃ ដែលជាវិន័យគ្រឹះ ឲ្យយើង ត្រូវតែអនុវត្តនៅក្នុងការសន្ទនា។ សេចក្តីស្រឡាញ់ ណែនាំឲ្យការប្រតិបត្តិតាមវិន័យបានពេញលក្ខណៈ។ ទីបី គឺដូចព្រះយេស៊ូ និងព្រះបិតាជាធ្លុងតែមួយនិងព្រះអង្គជួយគ្នាទៅវិញទៅមកដោយមិនរកប្រយោជន៍ផ្ទាល់ខ្លួនព្រះអង្គសោះ។ព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតមនុស្ស ដើម្បីជាប្រយោជន៍សម្រាប់មនុស្ស ព្រះអង្គខុសប្លែកពីសត្វលោក ឯទៀតៗទាំងអស់។ ដូច្នេះ យើងត្រូវការរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ដោយយើងសុខចិត្តមិនរកតែប្រយោជន៍ផ្ទាល់ខ្លួន ឡើយ នេះជាអ្វីដែលព្រះសហគមន៍ចង់ជួយបំភ្លឺនៅក្នុងការសន្ទនា។ ដើម្បីអាចសន្ទនាជាមួយគ្នាបាននោះយើងត្រូវតែគោរពនិងស្រឡាញ់អ្នកដែលបានគិតនិងបានប្រព្រឹត្តតាមរបៀបប្លែកពីយើង នៅក្នុងវិស័យសង្គម ក្នុងវិស័យនយោបាយ ឬក្នុងវិស័យសាសនាជាដើម។ ព្រះសហគមន៍ សូមឲ្យយើងថែរក្សាការសន្ទនា ដោយឲ្យយើងគោរព និង ស្រឡាញ់អស់អ្នកដែលគិត និង ប្រព្រឹត្តតាមរបៀបប្លែកពីយើង។ ប្រសិនបើ យើងមិនធ្វើដូចនេះ ណែនាំឲ្យមានសង្គ្រាម។ ប៉ុន្តែប្រសិនបើយើងខិតខំយល់ចិត្តគំនិតរបស់គេ ខិតខំយល់អំពីទស្សនៈរបស់គេពីខាងក្នុង កាន់តែជ្រៅទៅៗ ដោយចិត្តគោរព និងចិត្តស្រឡាញ់ នោះយើងនឹងអាចសន្ទនាជាមួយគេកាន់តែស្រួលដែរ ដោយដឹងថា យើងជាក្រុមគ្រួសារតែមួយ។ ដោយយកធម៌មេត្តាករុណាជាវិន័យដើម្បីដឹកនាំយើង នោះយើងមុខជាសុខ ចិត្តលះបង់បោលប្រយោជន៍ផ្ទាល់ខ្លួន និង យើងមុខជាគោរពគំនិតផ្សេងៗដែលប្លែកពីយើង ដោយខិតខំយល់ចិត្តគ្នានៅក្នុងសេចក្តីស្រឡាញ់។

គ្រឹះដ៏សំខាន់ពីរដើម្បីយើងរស់នៅយ៉ាងត្រឹមត្រូវនៅក្នុងសង្គមគឺទីមួយមេត្តាករុណានិងទីពីរសេចក្តីពិតដែលត្រូវតែប្រព្រឹត្តទៅជាមួយគ្នាគ្រប់ពេលវេលា។ឯចំណុចចុងក្រោយគឺសូមឲ្យយើងលើកលែងទោស។ តាមសេចក្តីប្រៀនប្រដៅរបស់ព្រះគ្រីស្តព្រះអង្គសូមឲ្យយើងអង្វរព្រះជាម្ចាស់ជាព្រះបិតាលើកលែងទោសឲ្យអស់អ្នកដែលបានធ្វើបាបយើង ព្រះអង្គបានលាតត្រដាងវិន័យនៃសេចក្តីស្រឡាញ់ក្នុងសម្ព័ន្ធមេត្រីថ្មី រហូតដល់ឲ្យយើងស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួនទៀតផង។ ដូច្នេះ យើងត្រូវតែលើកលែងទោស ឲ្យខ្មាំងសត្រូវរបស់យើង តាមសេចក្តីប្រៀនប្រដៅរបស់ព្រះគ្រីស្ត ប្រសិនបើយើង មិនចូលនៅក្នុងការលើកលែងទោសទេ ការសន្ទនារបស់យើងក៏ចប់ដែរ។ សូមឲ្យយើងខិតខំមើលរបៀបរបស់ព្រះយេស៊ូ ដើម្បីឲ្យយើងអាចមើលឃើញថា ការសន្ទនារវាងព្រះសហគមន៍នឹង ពិភពលោក និង សង្គម គឺជាអ្វីដែលយើងអាចអនុវត្តបាននៅក្នុងការរស់នៅរបស់យើងដោយដឹងថាមនុស្សទាំងអស់ជាក្រុមគ្រួសារតែមួយ។ចូរឲ្យយើងមានសេចក្តីស្រឡាញ់ ចូរឲ្យយើងលះបង់ប្រយោជន៍ខ្លួនឯង ចូរឲ្យយើងចេះគោរពមនុស្ស ដែលមានគំនិតប្លែកពីយើង រហូតដល់យើងអាចលើកលែងទោសឲ្យគេបាន។ នេះជារបៀបដែលយើងត្រូវធ្វើតាមគំរូរបស់ ព្រះយេស៊ូដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាកន្លែងឲ្យយើងអាចសន្ទនាគ្នាយ៉ាងពិតប្រាកដ។ ថ្ងៃនេះយើង បានឃើញគ្រឹះពីរដ៏សំខាន់ គឺ "ព្រះសហគមន៍ក្រីក្រជួយអ្នកក្រីក្រ" និង " ព្រះសហគមន៍ខិតខំសន្ទនាក្នុងផ្ទៃក្នុង និងជាមួយអ្នកដទៃ"។

អាម៉ែន។

## អត្ថបទព្រះគម្ពីរ
## សម្រាប់ថ្ងៃទី១១/០៩/២០១៣ពេលរសៀល

**សំណូមពររបស់ម្ដាយលោកយ៉ាកុប និងលោកយ៉ូហាន**
(ម៉ាថាយ២០, ២០-២៣ កុស ១០, ៣៥-៤៥ លូកា ២២, ២៤-២៧)

[២០]ពេលនោះ ភរិយារបស់លោកសេបេដេបាននាំកូនទាំងពីរ ចូល
មកគាត់ក្រាបទៀបព្រះបាទាព្រះយេស៊ូ ចង់ទូលសុំអ្វីមួយ។ [២១]ព្រះអង្គមាន
ព្រះបន្ទូលសួរគាត់ថា៖ "អ្នកចង់បានអ្វី?"។ គាត់ទូលព្រះអង្គវិញថា៖ "ដល់
ពេលព្រះអង្គគ្រងរាជ្យ សូមឲ្យកូនរបស់ខ្ញុំ ម្នាស់បានអង្គុយអមព្រះអង្គផង
គឺម្នាក់នៅខាងស្ដាំម្នាក់នៅខាងឆ្វេង "។ [២២]ព្រះយេស៊ូមានព្រះបន្ទូលតប
ថា៖"អ្នកមិនដឹងថាខ្លួនសុំអ្វីឡើយតើអ្នកទាំងពីរអាចទទួលពែងជដែលខ្ញុំត្រូវ
ទទួលនោះបានឬទេ?"។ លោកយ៉ាកុបនិងលោកយ៉ូហានទូលថា៖ " យើង
ខ្ញុំអាចទទួលបាន"។ [២៣]ព្រះអង្គមានព្រះបន្ទូលទៅអ្នកទាំងពីរថា៖ "អ្នកនឹង
ទទួលពែងរបស់ខ្ញុំបានមែន បំណែកឯអង្គុយនៅខាងស្ដាំឬខាងឆ្វេងខ្ញុំនោះ
ខ្ញុំមិនអាចសម្រេចឲ្យឡើយ ព្រោះកន្លែងនោះបម្រុងទុកសម្រាប់ តែអស់អ្នក
ដែលព្រះបិតារបស់ខ្ញុំ បានសម្រេចឲ្យប៉ុណ្ណោះ"។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១១/០៩/២០១៣ពេលរសៀល

## ព្រះយេស៊ូសន្ទនាជាមួយស្ត្រីសាសន៍សាម៉ារីម្នាក់

(យ៉ូហាន៤, ៥-១៥)

៥ព្រះអង្គបានយាងមកដល់ភូមិមួយ របស់ជនជាតិសាម៉ារី ឈ្មោះ
ភូមិស៊ីខា នៅជិតចំការដែលលោកយ៉ាកុបបានចែកឲ្យលោកយ៉ូសែប ជាកូន។
៦នៅទីនោះមានអណ្ដូងទឹកមួយ ឈ្មោះ"អណ្ដូងលោកយ៉ាកុប"។ ព្រះយេស៊ូ
អស់កម្លាំងក្នុងការធ្វើដំណើរក៏គង់នៅមាត់អណ្ដូង ពេលនោះ ប្រហែលជាថ្ងៃ
ត្រង់។ ៧មានស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹក ព្រះយេស៊ូមានព្រះបន្ទូល
ទៅនាងថា៖"ខ្ញុំសុំទឹកទទួលទានបន្តិច"។ ៨(សាវ័កនាំគ្នាទៅរកទិញស្បៀង
អាហារនៅឯភូមិ)។ ៩ស្ត្រីសាម៉ារីទូលព្រះអង្គថា៖ "លោកជាសាសន៍យូដា
ម្ដេចក៏លោកមកសុំទឹកនាងខ្ញុំ ជាស្ត្រីសាសន៍សាម៉ារីពិសាដូច្នេះ?" (ដ្បិត
សាសន៍យូដានិងសាសន៍សាម៉ារីមិនត្រូវគ្នាទេ)។ ១០ព្រះយេស៊ូ មានព្រះ
បន្ទូលតបទៅនាងថា៖"ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជា
ម្ចាស់ និងស្គាល់អ្នកដែលនិយាយទៅកាន់នាងថា "ខ្ញុំសុំទឹកទទួលទានបន្តិច"
នោះនាងមុខជាសុំទឹកពីលោកវិញពុំខាន ហើយលោកនឹងឲ្យទឹកដល់នាង
គឺជាទឹកដែលផ្ដល់ជីវិត"។ ១១នាងទូលព្រះអង្គថា៖"លោកម្ចាស់! លោក គ្មាន
អ្វីដងទឹកសោះ រីឯអណ្ដូងសោតក៏ជ្រៅទៀតផង តើលោកបានទឹកដែលផ្ដល់
ជីវិតនោះពីណាមក?។ ១២តើលោកមានឋានៈធំជាងលោកយ៉ាកុប ជាបុព្វ
បុរស *របស់យើង ដែលបានទុកអណ្ដូងនេះឲ្យយើងឬ?។ លោកយ៉ា កុបនិង
កូនចៅរបស់លោកបានពិសាទឹកអណ្ដូងនេះ ហើយសត្វរបស់លោកក៏បាន
ផឹកទឹកអណ្ដូងនេះដែរ "។ ១៣ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ " អស់
អ្នកដែលពិសាទឹកនេះនៅតែស្រេកតទៅមុខទៀត ១៤រីឯអ្នកដែល ពិសាទឹកខ្ញុំ
ឲ្យនោះនឹងមិនស្រេកទៀតសោះឡើយដ្បិតទឹកខ្ញុំឲ្យនឹងបានទៅជាប្រភពទឹក
ដែលផុសឡើងផ្ដល់ជីវិតអស់កល្បជានិច្ច"។ ១៥ស្ត្រីនោះ ទូលព្រះអង្គថា៖
"លោកម្ចាស់!សូមមេត្តាផ្ដល់ទឹកនោះមកនាងខ្ញុំផងកុំឲ្យនាងខ្ញុំស្រេកនិងកុំឲ្យ
រវល់មកដងទឹកអណ្ដូងនេះទៀត"។



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម

## ១២/០៩/២០១៣ (ព្រឹក)

ជម្រាបសួរលោកឪពុក!

បងប្អូនទាំងអស់គ្នា!ថ្ងៃនេះជាថ្ងៃទីបួននៃសិក្ខាសាលារបស់យើង។ខ្ញុំសង្ឃឹមថាយើងម្នាក់ៗកាន់តែជិតស្និទ្ធ ឡើងនឹងព្រះជាម្ចាស់ យើងសប្បាយនឹងនៅទីនេះ ដូចកាលដែលព្រះយេស៊ូបានរើសសាវ័កបី នាក់ឡើងលើភ្នំតាបោរ នៅពេលនោះបន្តិចម្តងៗ ពួកសាវ័កមិនចង់ទៅណាទេ គេចង់ស្នាក់នៅទីនោះ ដោយសារពេលនោះ គេបានឃើញព្រះយេស៊ូបង្ហាញឋានៈព្រះអង្គ ជាព្រះបុត្រា របស់ព្រះជាម្ចាស់។

ថ្ងៃនេះ ជាពេលវេលាមួយដែលយើងឡើងលើភ្នំតាបោរជាមួយព្រះយេស៊ូ ហើយយើងអង្គុយមើលព្រះអង្គដោយមិន ចង់ត្រឡប់ទៅផ្ទះវិញទេ។ ដូច្នេះថ្ងៃនេះ យើងកំពុងចូលនៅក្នុងទំនាក់ទំនងជាមួយព្រះយេស៊ូថែមទៀត ដោយរិះគិតអំពីព្រះសហគមន៍ ដែលយើងបានចាក់សរសេរគ្រឹះពីម្សិលមិញចំនួនពីរគឺ "ព្រះសហគមន៍ជាមួយអ្នកក្រីក្រ និងព្រះសហគមន៍សន្ធនា"។ ថ្ងៃនេះយើងបន្តចាក់សរសេរគ្រឹះពីរទៀតគឺ " ព្រះសហគមន៍ស្វាគមន៍ និង ព្រះសហគមន៍លើកលែងទោស "។ ពេលយើងបិទភ្នែកស្តាប់អត្ថបទគម្ពីរ យើងមានអារម្មណ៍ថា ព្រះយេស៊ូកំពុងមានព្រះបន្ទូលមកយើងដោយផ្ទាល់ ដែរ ហើយអត្ថបទនេះ ក៏ជួយឲ្យយើងយល់យ៉ាងច្បាស់អំពីរបៀបដែលព្រះយេស៊ូអញ្ជើញសាវ័ករបស់ព្រះអង្គពីដើម និងក៏ធ្វើឲ្យយើងមានអារម្មណ៍ថា យើងក៏កំពុងនៅទីនោះដែរ។ តើយើងនៅទីនោះជាលោកសាខេ? ឬជាអ្នកដែលរិះគន់ព្រះ យេស៊ូ? ឬជាអ្នកបាបកំពុងអង្គុយបរិភោគអាហារនៅផ្ទះលោកសាខេ? ។ "ព្រះសហគមន៍ស្វាគមន៍"

ចំណុចទីមួយ ព្រះសហគមន៍ជាកន្លែងដើម្បីទទួលស្វាគមន៍ និង ព្រះសហគមន៍មាន ឥរិយាបថដើម្បីស្វាគមន៍។ ពេលយើងនិយាយអំពីការស្វាគមន៍ នោះយើងត្រូវមើលទៅព្រះយេស៊ូដែលស្វាគមន៍គេ។ ព្រះយេស៊ូស្វាគមន៍គេនៅផ្ទះរបស់គេ គឺជាព្រះយេស៊ូ ដែលអញ្ជើញលោកសាខេដើម្បីទៅផ្ទះរបស់លោកសាខេ។ ដូចយើងបាន ឃើញប៉ុន្មានដង ព្រះយេស៊ូចេញទៅស្វាគមន៍គេនៅតាមផ្ទះរបស់គេ ឧទាហរណ៍ពេលមួយនោះ ព្រះអង្គសោយអាហារ នៅផ្ទះធម្មាចារ្យនៃគណៈផារីស៊ីម្នាក់ ពេលនោះ មានស្ត្រីម្នាក់ឈ្មោះម៉ារីម៉ាដាឡា បានមកលាងព្រះបាទារបស់ព្រះអង្គ ជាមួយនឹងទឹកក្រអូបដ៏មានតម្លៃ ហើយយកសក់របស់គាត់មកជូតសម្អាតទៀតផង។ តាមគំរូនេះ ណែនាំឲ្យយើងនឹកឃើញ ដល់ព្រះសហគមន៍របស់យើង ដែលត្រូវទៅជាព្រះសហគមន៍មួយដែលចេញទៅដើម្បីស្វាគមន៍ ដើម្បីអញ្ជើញភ្ញៀវ គឺអញ្ជើញបងប្អូនឯទៀតៗ និងដែលជាព្រះសហគមន៍មានគេអញ្ជើញឲ្យទៅដល់ផ្ទះគេដែរ គឺទៅដល់ផ្ទះរបស់គេ ដើម្បីបង្កើតទំនាក់ទំនងជាមួយគេ។

កាលនៅពីក្មេង មានលោកបូជាចារ្យម្នាក់ដែលទទួលខុសត្រូវលើព្រះសហគមន៍នៅភូមិខ្ញុំ រាល់ថ្ងៃគាត់បានចេញ ទៅតាមផ្ទះរបស់អ្នកភូមិដែលគាត់មិនស្គាល់ នៅពេលពួកគេចេញពីធ្វើការ។ ពេលជួបពួកគេ

គាត់មានប្រសាសន៍ថាខ្ញុំជាបូជាចារ្យទទួលខុសត្រូវនៅទីនេះខ្ញុំសូមមកលេងនឹងអ្នករាល់គ្នា...។នេះជារបៀបមួយដ៏ល្អ ដោយសារយើងមិនទៅសួរសុខ ទុក្ខតែគ្រីស្ដបរិស័ទប៉ុណ្ណោះទេ តែយើងត្រូវទៅសួរសុខទុក្ខដល់ផ្ទះបងប្អូនទាំងអស់ ដែលមិនមែនជាគ្រីស្ដបរិស័ទដែរ គឺយើងត្រូវធ្វើដូចព្រះយេស៊ូ ដោយយើងត្រូវចេញទៅស្វាគមន៍គេនៅក្នុងផ្ទះរបស់គេ និងទៅផ្ទះគេដើម្បីអញ្ជើញគេឲ្យមក កន្លែងយើងដែរ។

ចំណុចទីពីរ គឺព្រះយេស៊ូយាងទៅកន្លែងណាដែលមានមនុស្សនៅ។ព្រះយេស៊ូមិនតែបង្រៀន នៅតាមផ្លូវនៅលើភ្នំទេ តែច្រើនផង ព្រះអង្គទៅបង្រៀននៅក្នុងធម្មសាលា ជាកន្លែងដែលគេជួបជុំគ្នាដើម្បីអធិដ្ឋាន ស្ដាប់គម្ពីរ ស្ដាប់ធម្មាចារ្យ ពន្យល់គម្ពីរសម្ពន្ធមេត្រីចាស់។ ដូច្នេះសូមឲ្យព្រះសហគមន៍របស់យើងហ៊ានចេញទៅរកកន្លែងដែលមានមនុស្សរស់នៅដែរ ដើម្បីឲ្យព្រះសហគមន៍យើងមានវត្តមាននៅទីនោះ។ ពេលចូលរួមក្នុងកម្មវិធីផ្សេងៗជាមួយគេ សូមឲ្យគ្រីស្ដបរិស័ទ យើងចេះស្ដាប់គេ ហើយឲ្យយើងបង្កើតទំនាក់ទំនងជាមួយគេ ដ្បិតអីព្រះសហគមន៍របស់យើងមិនបិទទ្វារទេ។

ចំណុចទីបី ព្រះយេស៊ូមិនទាក់ទងតែនឹងមនុស្សល្អដើម្បីបំពេញចិត្តអ្នកដែលរិះគន់ព្រះអង្គទេ។ កាលព្រះយេស៊ូ យាងទៅតាមទីកន្លែងនានា ជួនកាលមហាជនដែលដើរតាមព្រះអង្គគេអន់ចិត្តនឹងព្រះអង្គ ដោយឃើញថា ព្រះអង្គយាង ទៅរួមតុអាហារជាមួយលេវី (ម៉ាថាយ) រួមតុអាហារនៅផ្ទះលោកសាខេ ដែលជាអ្នកបាប...។ ព្រះយេស៊ូយាងទៅគ្រប់ទីកន្លែង ដែលមានសេចក្ដីត្រូវការ ព្រះអង្គមិនរើសមនុស្ស ដែលព្រះអង្គត្រូវទៅសួរសុខទុក្ខទេ។ ព្រះយេស៊ូអង្គុយរួមតុអាហារជាមួយអ្នកបាប ព្រះអង្គសន្ទនាជាមួយស្ត្រីសាសន៍សាម៉ារី ជាមួយនាងម៉ារីម៉ាដាឡាជាស្ត្រីពេស្យា គឺព្រះអង្គនៅជាមួយមនុស្សទាំងអស់ ដែលមានសេចក្ដីត្រូវការនោះបណ្ដាលឲ្យពួកធម្មាចារ្យរិះគន់ព្រះអង្គ។លោកសាខាជាអ្នកមានទ្រព្យសម្បត្តិណាស់ប៉ុន្តែគាត់ក៏ជាអ្នកក្រដែរ ដោយសារគាត់ជាអ្នកមានបាប នេះជាមូលហេតុ ដែលយើងត្រូវនៅជាមួយរដ្ឋអំណាចដែរ ដើម្បីឲ្យយើងបានបង្ហាញសញ្ញាមួយឲ្យគេឃើញ ឲ្យគេទទួលស្គាល់យើង ដោយសារគេក៏ទទួលការត្រាស់ហៅដែរ។ យើងមិនត្រូវខ្លាចអ្វីទេ យើងត្រូវតែបង្កើតទំនាក់ទំនងគ្រប់ទីកន្លែង ដូចព្រះយេស៊ូ ដែលយាងទៅគ្រប់ទីកន្លែងបង្កើតទំនាក់ទំនងដែរ ប៉ុន្តែសូមឲ្យយើងការពារថែរក្សាគុណធម៌ទាំងបីរបស់យើង គឺជំនឿ សេចក្ដីស្រឡាញ់ និង សេចក្ដីសង្ឃឹម ដែលជាតម្លៃ នៃជីវិតរបស់យើង។

ចំណុចទីបួន មុនព្រះយេស៊ូសោយទិវង្គត ព្រះអង្គបានសុំឲ្យក្រុមគ្រីស្ដទូតរៀបចំបន្ទប់មួយយ៉ាងស្អាត ដើម្បីធ្វើពិធី ជប់លៀង។ មានន័យថា ព្រះយេស៊ូចេះរៀបចំកន្លែងយ៉ាងស្អាត ដើម្បីឲ្យអ្នកចូលរួមទាំងអស់មានភាពកក់ក្ដៅ ដោយមាន អារម្មណ៍ថា ព្រះអង្គស្វាគមន៍គេ។ ដូច្នេះចំពោះយើង ដែលនិយាយថាព្រះសហគមន៍ជាទីតាំងដើម្បីទទួលស្វាគមន៍គេ នោះព្រះសហគមន៍យើងក៏ត្រូវតែជាកន្លែងមួយដែលយើងបានរៀបចំ ដែលយើងបានសម្អាតឲ្យមានអនាម័យល្អ ឲ្យមាន បរិយាកាសស្រស់ស្រាយដើម្បីយើងស្វាគមន៍គេដែរ។

*អំពីកាយវិការរបស់អ្នកស្វាគមន៍គេ ពិសេសកាយវិការរបស់អ្នកដឹកនាំព្រះសហគមន៍ដែលជាគង្វាល គឺ៖*

ទីមួយ " ព្រះយេស៊ូមិនវិនិច្ឆ័យនរណាទេ "។ នៅចំពោះមុខស្ត្រីម្នាក់ ដែលគេកំពុងវិនិច្ឆ័យពីអំពីបាបរបស់នាង ពេលនោះ ព្រះយេស៊ូគ្រាន់តែគូរនៅលើដីខ្សាច់ ហើយព្រះអង្គមានព្រះបន្ទូលទៅពួកគេថា៖ " ប្រសិនបើនរណាម្នាក់មិន ដែលធ្វើអំពើបាបសោះ សូមគប់នាងនឹងដុំថ្មទៅ"។ ពេលនោះគ្មាននរណាម្នាក់គប់ដុំថ្មលើនាងទេ ដោយសារគេនឹកឃើញ បាបរបស់គេដែរ។ ដូច្នេះ ព្រះសហគមន៍ក៏មិនត្រូវវិនិច្ឆ័យនរណាដែរ ចូរយើងទទួលគេជាមុនសិន នេះជារបៀបរបស់ព្រះ យេស៊ូ។

ទីពីរ " ព្រះយេស៊ូមានព្រះហឫទ័យអាណិតមេត្តា"។ ពេញមួយព្រឹក ព្រះយេស៊ូបានបង្រៀន បណ្ដាជនប្រមាណ ៥០០០ នាក់ ពេលនោះព្រះអង្គអាណិតអាសូរគេខ្លាំងណាស់ ដោយសារព្រះអង្គទតឃើញអំពីសេចក្ដីត្រូវការរបស់គេ គឺគេ ឃ្លានអាហារយ៉ាងខ្លាំង ។ ចូរឲ្យយើងដូចព្រះយេស៊ូដែលចេះមើលអំពីទុក្ខលំបាករបស់គេ។ ចូរឲ្យយើងចេះចូលនៅក្នុង អារម្មណ៍របស់គេ ដូចព្រះយេស៊ូដែលមិនគ្រាន់តែមានព្រះបន្ទូល ប៉ុន្តែព្រះអង្គអាណិតអាសូរគេពិតប្រាកដមែន រហូតដល់ ព្រះអង្គទ្រង់ព្រះកន្សែងពីរដង ម្ដងដោយព្រះអង្គអាណិតអាសូរលោកឡាសា និងម្ដងទៀតដោយសារព្រះអង្គស្រណោះ ក្រុងយេរូសាឡឹម ទាំងមានព្រះបន្ទូលថា ៖ " ឱទីក្រុងយេរូសាឡឹមអើយ !"។

ទីបី " ព្រះយេស៊ូស្វាគមន៍គេដោយសេចក្ដីស្រឡាញ់ " គឺនៅក្នុងការស្វាគមន៍មានបង្កប់នូវសេចក្ដីស្រឡាញ់។ តាម (មក ១០,២២) ពេលបុរសម្នាក់ដើរចេញទៅ ព្រះយេស៊ូបានទតមើលគាត់ដោយព្រះហឫទ័យស្រឡាញ់ គឺព្រះយេស៊ូមាន ព្រះហឫទ័យស្រឡាញ់។

ទីបួន "ព្រះយេស៊ូមានកាយវិការដើម្បីលើកទឹកចិត្តគេ"។ នៅពេលម្ដាយក្មេករបស់លោកសិលាឈឺ ព្រះយេស៊ូបាន យាងទៅចាប់ដៃរបស់គាត់ឲ្យក្រោកឡើង។ ចំណែកឯកូនស្រីរបស់លោកយ៉ៃរ៉ូសវិញ ព្រះយេស៊ូបានលាព្រះហស្ដដាក់លើក្បាលនាង។ព្រះយេស៊ូធ្វើកាយវិការផ្សេងៗដើម្បីលើកទឹកចិត្តគេ ជួនកាលព្រះអង្គមិនប្រើពាក្យសម្ដីអ្វីទាំងអស់ គឺព្រះអង្គប្រើតែកាយវិការប៉ុណ្ណោះ ទុកជាសញ្ញានៃការលើកទឹកចិត្ត។ ទីប្រាំ " ព្រះយេស៊ូជ្រើសរើសយកជីវិតគ្រប់ពេលវេលា " ព្រះអង្គមិនជ្រើសរើសយកធម៌វិន័យជាអាទិភាពទេ។ ព្រះ យេស៊ូសួរគេថា តើការសំខាន់ គឺយើងត្រូវគោរពថ្ងៃសប្ប័ទ ឬ ត្រូវការឲ្យមនុស្សរស់ឡើងវិញ ? ។

ទីប្រាំមួយ " ព្រះយេស៊ូមិនខ្លាចគេរំខានព្រះអង្គទេ "។ ច្រើនដង ព្រះយេស៊ូបានជិះទូកទៅរកកន្លែងស្ងាត់ ប៉ុន្តែពេល បណ្ដាជនឃើញព្រះអង្គចុះទូក គេក៏រកផ្លូវផ្សេងទៀត ដើម្បីទៅដល់ទីដៅនោះមុនព្រះអង្គ។ ពេលយាងទៅដល់ឃើញ មនុស្សម្នាច្រើនដូច្នេះ ព្រះអង្គមិនគេចវេសពីគេទេ ព្រះអង្គទេសនាប្រៀនប្រដៅគេផង និងព្យាបាលគេផង។ នៅក្នុង ចំណោមមហាជនរាប់ពាន់នាក់ដែលដើរតាមព្រះយេស៊ូមានស្ត្រីម្នាក់ដែលធ្លាក់ឈាមយូរឆ្នាំហើយ គាត់ទៅប៉ះព្រះពស្ត្រព្រះ យេស៊ូពីក្រោយ ហើយបានជា។

ទីប្រាំពីរ"ព្រះយេស៊ូជប់លៀង"។សញ្ញាសម្គាល់ទីមួយគឺក្នុងពិធីជប់លៀងមង្គលការនៅភូមិកាណាពេលនោះ ព្រះយេស៊ូប្រទានស្រាធ្វាញ់ដល់គេ។ ព្រះយេស៊ូមិនចង់ឲ្យព្រះសហគមន៍របស់យើងទៅជាកន្លែងមួយពិបាកចិត្ត ប៉ុន្តែចង់ ឲ្យយើងមានអំណរសប្បាយ ដូចពិធីជប់លៀងមួយដែលមានស្រាធ្វាញ់ ដែលមិនចង្អៀតចង្អល់ចំពោះភ្ញៀវដែលចូលរួម ទោះបីយើងអញ្ជើញគេតែ ២០០ នាក់ ហើយគេមកចូលរួមរហូតដល់ ២៥០ នាក់ក៏ដោយ កុំឲ្យយើងដេញគេទៅវិញអី។

ដូច្នេះ ចំណុចទាំងប្រាំពីរដែលខ្ញុំបានបង្ហាញនេះ គឺជាគំរូរបស់ព្រះយេស៊ូ ដែលណែនាំយើងជាគង្វាល ជាអ្នកបម្រើ ព្រះសហគមន៍ ត្រូវប្រព្រឹត្តតាមក្នុងការស្វាគមន៍គេ ដែលមានពីរចំណុចធំៗគឺ " ការស្វាគមន៍តាមទីតាំង និងការស្វាគមន៍តាមកាយវិការ"។ យើងជានិស្សិតទេវវិទ្យាល័យ ជាកូនសិស្សរបស់លោកអភិបាល យើងមិនទាន់ជាបូជាចារ្យទេ ប៉ុន្តែយើង បានរស់នៅ និង យើងកំពុងតែចូលរួមនៅក្នុងក្រុមបូជាចារ្យហើយ យើងមិនមែនជានិស្សិតធម្មតាទេ។ យើងសូមទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គជួយបំភ្លឺឲ្យព្រះសហគមន៍របស់យើង ទៅជាកន្លែងមួយដែលបំភ្លឺ គេ ដោយចេះបង្ហាញអំពីរបៀបស្វាគមន៍ដូចព្រះយេស៊ូដល់គេដែរ។ អាម៉ែន។

## អត្ថបទព្រះគម្ពីរ
## សម្រាប់ថ្ងៃទី១២/០៩/២០១៣ពេលព្រឹក
### ព្រះយេស៊ូ និង លោកសាខេ

(លូកា១៩, ១-១០)

[១]ព្រះយេស៊ូមកដល់ក្រុងយេរីខូ ហើយយាងកាត់ទីក្រុង។ [២]មាន
បុរសម្នាក់ ឈ្មោះសាខេជាមេលើអ្នកទារពន្ធ* គាត់មានទ្រព្យសម្បត្តិយ៉ាង
ច្រើន។ [៣]គាត់ចង់ឃើញព្រះយេស៊ូ មានភិនភាគយ៉ាងណា ប៉ុន្តែលដោយ
មានមនុស្សច្រើនពេក ហើយដោយគាត់មានមាឌតូចទៀតផងនោះ គាត់មើល
ព្រះអង្គមិនឃើញទេ។ [៤]គាត់រត់ទៅខាងមុខ ឡើងដើមឈើមួយដើម ចាំមើល
ព្រះយេស៊ូ ព្រោះព្រះអង្គត្រូវយាងកាត់តាមនោះ។ [៥]កាលព្រះយេស៊ូយាង
មកដល់ព្រះអង្គងើបព្រះភ័ក្ត្រឡើង ហើយមានព្រះបន្ទូលទៅគាត់ថា៖"លោក
សាខេអើយ! សូមអញ្ជើញចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះខ្ញុំត្រូវស្នាក់នៅផ្ទះ
លោក"។ [៦]លោកសាខេក៏ចុះមកជាប្រញាប់ ហើយទទួលព្រះយេស៊ូដោយ
អំណរ។[៧]កាលមនុស្សទាំងអស់ឃើញដូច្នោះគេរអ៊ូរទាំថា៖"មើល៍!លោកនេះ
ទៅស្នាក់នៅផ្ទះមនុស្សបាប!"។ [៨]លោកសាខេក្រោកឈរឡើង ទូលព្រះ
អម្ចាស់ថា៖ "បពិត្រព្រះអម្ចាស់! ទូលបង្គំនឹងចែកទ្រព្យសម្បត្តិរបស់ទូលបង្គំ
ចំនួនពាក់កណ្ដាល ដល់មនុស្សក្រីក្រ ហើយប្រសិនបើទូលបង្គំទារពន្ធពីអ្នក
ណាហួសកំរិត ទូលបង្គំនឹងសងអ្នកនោះវិញ មួយជាបួន"។ [៩]ព្រះយេស៊ូមាន
ព្រះបន្ទូលទៅគាត់ថា៖ "ថ្ងៃនេះការសង្គ្រោះបានមកដល់ផ្ទះនេះហើយ ដ្បិត
បុរសនេះជាពូជពង្សរបស់លោកអប្រាហាំដែរ។ [១០]បុត្រមនុស្សបានមក ដើម្បី
ស្វែងរក និង សង្គ្រោះមនុស្សដែលវិនាសបាត់បង់"។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១១/០៩/២០១៣ពេលរសៀល

## ព្រះយេស៊ូប្រទាននំប៉័ងឲ្យមនុស្សប្រាំពាន់នាក់

( លូកា៩, ១០-១៧ មថ, ១៤, ១៣-២១ មក, ៦, ៣០-៤៤
យហ, ៦, ១-១៤ )

១០ គ្រីស្តទូត *នាំគ្នាវិលត្រឡប់មកវិញ រៀបរាប់ទូលព្រះយេស៊ូ នូវ
គ្រប់កិច្ចការទាំងអស់ដែលគេបានធ្វើ។ ព្រះអង្គនាំគេចេញដាច់ឡែកពីមហា
ជនតម្រង់ទៅភូមិមួយឈ្មោះបេតសៃដា ១១តែមហាជនដឹងក៏នាំគ្នាទៅតាម
ព្រះអង្គ។ ព្រះយេស៊ូទទួលពួកគេ ហើយមានព្រះបន្ទូល អំពីព្រះរាជ្យ *របស់
ព្រះជាម្ចាស់ ឲ្យគេស្តាប់ ព្រមទាំងប្រោសអ្នកជំងឺឲ្យបានជាផង។ ១២ដល់ថ្ងៃ
ជិតលិច សាវ័កទាំងដប់ពីររូបចូលទៅទូលព្រះអង្គថា៖ " សូមព្រះអង្គប្រាប់ឲ្យ
បណ្តាជនចេញទៅរកម្ហូបអាហារ រកកន្លែងស្នាក់តាមផ្ទះ តាមភូមិជិតៗនេះ
ទៅព្រោះទីនេះស្ងាត់ណាស់"។១៣ព្រះយេស៊ូមានព្រះបន្ទូលតបវិញថា៖"ចូរ
អ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ"។ ពួកសាវ័កទូលព្រះអង្គថា៖
"យើងខ្ញុំមាននំប៉័ងតែប្រាំដុំ និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ ធ្វើម្តេចនឹងគ្រាន់
មានតែទៅទិញអាហារ សម្រាប់ប្រជាជនទាំងនេះ!"។ ១៤នៅទីនោះមាន
មនុស្សប្រុសប្រមាណប្រាំពាន់នាក់។ ព្រះយេស៊ូ មានព្រះបន្ទូលទៅកាន់
សាវ័កថា៖ " ចូរអ្នករាល់គ្នាប្រាប់គេឲ្យអង្គុយចុះជាក្រុមៗ ក្នុងមួយក្រុមហា
សិបនាក់"។ ១៥ពួកសាវ័កក៏ធ្វើតាម គឺប្រាប់គេឲ្យអង្គុយចុះទាំង អស់គ្នា។
១៦ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ទ្រង់ងើប
ព្រះភ័ក្ត្រឡើងលើ សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានឲ្យសាវ័ក
ដើម្បីឲ្យគេចែកបណ្តាជនបរិភោគ។ ១៧គេបានបរិភោគឆ្អែតគ្រប់ៗគ្នា រួប
ប្រមូលនំប៉័ងដែលនៅសល់ បានពេញដប់ពីរល្អី។



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម
## ១២/០៩/២០១៣ (រសៀល)

ជម្រាបសួរលោកឪពុក! បងប្អូនទាំងអស់គ្នា!

ពេលរសៀលនេះ ខ្ញុំនឹងបញ្ចូលគ្នាអំពី "ការលើកលែងទោស និង ការអធិដ្ឋាន"។ កាលពីព្រឹកមិញ ខ្ញុំបាននិយាយ ច្រើនអំពីរបៀបដែលព្រះយេស៊ូបានស្វាគមន៍។ ប៉ុន្តែអ្វីដែលខ្ញុំចង់បង្ហាញគឺ " ការស្វាគមន៍ និង លើកលែងទោស"ដែលជា សរសរគ្រឹះពីរភ្ជាប់គ្នារបស់ព្រះសហគមន៍យើង។ ដូចយើងបានឃើញស្រាប់ ព្រះយេស៊ូបានហៅលោកសាខេទៅជប់លៀង នៅផ្ទះលោកសាខេ និងក្រោយមកព្រះអង្គណែនាំឲ្យលោកសាខេប្រែចិត្តគំនិតតែម្តង។ ពេលលោកសាខេជួបជាមួយព្រះយេស៊ូ នោះណែនាំឲ្យគាត់ដឹងថា ជីវិតរបស់គាត់មិនល្អទេ គាត់ក៏ប្រែចិត្តគំនិត ដោយសងអ្វីៗទាំងអស់ដែលគាត់បានយកពីគេ ទៅឲ្យគេវិញ ការណ៍នេះបញ្ជាក់ថា គាត់បានទទួលការលើកលែងទោសពីព្រះជាម្ចាស់ហើយ។ ដូច្នេះ ដោយសារតែបានជួបនឹងព្រះយេស៊ូ នោះលោកសាខេបានទទួលការលើកលែងទោស គឺទទួលជីវិតថ្មី។

ពេលនេះ ខ្ញុំសូមឲ្យយើងចាប់អារម្មណ៍អំពីរបៀបដែលព្រះជាម្ចាស់លើកលែងទោសឲ្យយើង ទៅជារបៀបដែល យើងជាព្រះសហគមន៍ ត្រូវការបង្ហាញការលើកលែងទោសដល់បងប្អូនទាំងអស់ ដែលមកជួបយើង។ ក្នុង (លក ១៥) មានពាក្យប្រស្នាបី នៅក្នុងប្រស្នានីមួយៗ យើងរកឃើញអំពីរបៀបដែលព្រះជាម្ចាស់លើកលែងទោស ដែលណែនាំឲ្យយើង យល់អំពីរបៀបដែលព្រះសហគមន៍ ត្រូវបង្ហាញអំពីការលើកលែងទោសរបស់ព្រះជាម្ចាស់ នៅពេលយើងស្វាគមន៍គេ គឺដោយយើងត្រូវរាក់ទាក់គេ។ យើងមិនធ្វើ ដូចគណៈផារីស៊ី និង បូជាចារ្យដែលរអ៊ូរទាំ ដោយសារគេឃើញព្រះយេស៊ូនៅជាមួយមនុស្សបាប ឃើញព្រះអង្គរាក់ទាក់នឹងមនុស្សទាំងអស់ដោយមិនរើសមុខនោះទេ។

ប្រស្នាទីមួយយើងឃើញពីរបៀបនៃការលើកលែងទោសតាមរបៀបរបស់"គង្វាលម្នាក់"។ជាធម្មតាមនុស្សទូទៅ តែងគិតថា គង្វាលម្នាក់ដែលនៅក្នុងហ្វូងសត្វរបស់ខ្លួន ពេលណាមានសត្វមួយក្បាលបាត់ នោះគាត់មិនតាមរកទេ ព្រោះអ្វីដែលសំខាន់ គឺគាត់ត្រូវនៅជាមួយសត្វមួយហ្វូងនោះវិញ។ ប៉ុន្តែនៅក្នុងប្រស្នានេះ របៀបស្វែងរកចៀមដែលបាត់របស់ គង្វាលនោះសំខាន់ណាស់ គឺបង្ហាញយើងអំពីការលើកលែងទោសរបស់ព្រះជាម្ចាស់ចំពោះយើង និងបង្ហាញអំពីការទទួល ស្គាល់តម្លៃរបស់មនុស្ស គឺមនុស្សម្នាក់ៗមានតម្លៃណាស់។ បើមានមនុស្សម្នាក់ដែលបាត់បង់ជីវិត ដែលវង្វេងផ្លូវ នោះឲ្យយើងសុខចិត្តបោល ៩៩ នាក់មួយភ្លែតសិន ដើម្បីទៅរកម្នាក់នោះ។ ការលើកលែងទោសរបស់គង្វាលបង្ហាញថា ទីមួយ គឺមនុស្សម្នាក់ៗមានតម្លៃ និង ទីពីរ គឺព្រះជាម្ចាស់ដើរតាមរកយើង និង ស្វែងយល់ពីយើងគ្រប់ពេល។

ព្រះជាម្ចាស់រកឃើញយើងគ្រប់ពេលវេលា រកឃើញតាំងពីថ្ងៃដែលមនុស្សយើងបានធ្វើអំពើបាបនៅសួនអេដែន ដែលពេលនោះ គេបានលាក់ខ្លួនដោយសារគេខ្មាស។ តែទោះបីគេលាក់ខ្លួនក៏ដោយ ក៏ព្រះ

ជាម្ចាស់បានស្រែកសួរទៅគេជាសំណួរ ដែលព្រះអង្គបានសួរតាំងពីដើមរៀងមករហូតដល់សព្វថ្ងៃដែរគឺ " តើអ្នកនៅឯណា?"។ សព្វថ្ងៃ អ្នកដែលត្រូវសួរសំណួរនេះ គឺជាតួនាទីរបស់យើងម្នាក់ៗ និងជាតួនាទីរបស់ព្រះសហគមន៍ទាំងមូល ដែលត្រូវសួរទៅអ្នកដែលលាក់ខ្លួន អ្នកដែលវង្វេងផ្លូវ និងអ្នកដែលមិនដឹងទៅណាមកណា។ តួនាទីរបស់យើង ត្រូវធ្វើដូចម្តេចឲ្យពួកគេបានស្តាប់ឮសំណួរនេះ " តើអ្នកនៅឯណា?" ដើម្បីឲ្យគេដឹងថា យើងបានចាប់អារម្មណ៍ដល់ពួកគេ ដើម្បីឲ្យពួកគេទទួលស្គាល់ថា គេមានតម្លៃ។ ច្រើនដងអ្នកមានបាបតែងគិតថា ជីវិតគេគ្មានតម្លៃទេ គ្មានអ្នកណាដែលចង់រាប់អានគេទេ...។

ដោយហេតុនេះហើយ បានជា " ការស្វាគមន៍ និង ការលើកលែងទោស" ជាប់គ្នាមែនទែនសម្រាប់ព្រះសហគមន៍របស់យើង។ យើងស្វាគមន៍គេ ដោយសារជីវិតរបស់គេមានតម្លៃដូចមនុស្សដទៃ ដោយសារយើងជាតំណាងរបស់ព្រះជាម្ចាស់ដែលស្រឡាញ់គេដែលដើរតាមរកគេ និង សួរគេថា "តើអ្នកនៅឯណា?"។ មុនដំបូង សំណួរនេះ ប្រហែលជាគេអាច គិតថា យើងរំខានគេ តែក្រោយមក សំណួរនេះនឹងណែនាំឲ្យគេមានជីវិតថ្មី ដោយសារគេនឹងដឹងថា ព្រះយេស៊ូមិនវិនិច្ឆ័យ គេទេ។ គ្រប់ពេល ព្រះយេស៊ូជ្រើសរើសជីវិត ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរគេ និង ណែនាំឲ្យជីវិតរបស់គេ ទៅជា ជីវិតថ្មីវិញ។

ប្រស្នាទីពីរ ជារបៀបនៃការលើកលែងទោសតាមរបៀប "ទឹកចិត្តម្តាយ" ដោយនិទានអំពីស្ត្រីម្នាក់ដែលបាត់លុយ។ ដោយសារនៅក្នុងផ្ទះងងឹត ស្ត្រីនោះបានអុជចង្កៀងមួយឲ្យភ្លឺ រួចហើយគាត់ចាប់ផ្តើមរកគ្រប់ទីកន្លែងដោយយកចិត្តទុកដាក់ ដើម្បីរកឲ្យឃើញលុយដែលបាត់នោះ។ នេះជារបៀបមួយទៀត ដែលបង្ហាញថា ព្រះជាម្ចាស់ស្វែងរកមនុស្សដោយ មានព្រះហឫទ័យស្រឡាញ់ដូចម្តាយម្នាក់ដែលស្រឡាញ់កូនខិតខំរកលុយឲ្យកូនទៅរៀន ខិតខំរៀបចំផ្ទះឲ្យស្អាត ខិតខំថែ រក្សាកូនដោយអស់ពីសមត្ថភាព។

ប្រស្នាទីបី នៅពេលឃើញកូនមកពីចម្ងាយ ឪពុកម្នាក់បានរត់ទៅស្វាគមន៍កូន។ នេះបង្ហាញអំពីការលើកលែង ទោសរបស់ព្រះជាម្ចាស់ តាមរបៀប " ទឹកចិត្តឪពុក " ដែលស្វាគមន៍កូនរបស់ខ្លួន ដែលបាត់ដោយរត់ទៅទទួលកូន។ យើងជាព្រះសហគមន៍ ត្រូវតែដូចជាឪពុកដែលរត់ទៅរកកូនដែរយើងមិនរង់ចាំឲ្យគេមករកយើងទេ។ ពាក្យដែលគេប្រើនៅក្នុង ភាសាក្រិកបានបង្ហាញថា ឪពុកស្វាគមន៍កូនដោយអស់ពីខាងក្នុងពោះរបស់គាត់ ក្រោយមកគាត់ធ្វើជប់លៀងមួយដើម្បី ស្វាគមន៍កូន។ របៀបដែលឪពុក លើកលែងទោសឲ្យកូន ណែនាំឲ្យកូនបាត់ការភ័យព្រួយ និង ណែនាំឲ្យកូនទទួលជីវិតថ្មី យ៉ាងពិតប្រាកដវិញ។

ចំពោះយើងជាមនុស្សបាប ពេលណាឃើញរបៀបដែលព្រះសហគមន៍ទទួលយើងដោយស្មោះនោះណែនាំឲ្យ យើងលែងខ្មាសគេ ដោយយើងដឹងថា យើងទទួលការលើកលែងទោស ទទួលអំណរសប្បាយទទួលជីវិតថ្មី និងសេចក្តី ស្រឡាញ់យ៉ាងខ្លាំងពីលោកឪពុក។ ដូច្នេះការស្វាគមន៍របស់ព្រះសហគមន៍ គឺភ្ជាប់ទៅនឹងការលើកលែងទោស តាមបីរបៀប គឺរបៀប "គង្វាល" របៀប "ទឹកចិត្តម្តាយ" និង របៀប "ទឹកចិត្តឪពុក" ដែលទាំងអស់នេះ ជារបៀបរបស់ព្រះជាម្ចាស់ ដែលស្វែងរកមនុស្សបាប មនុស្សដែលអស់សង្ឃឹម ដើម្បីឲ្យគេចាប់ផ្តើមមានជីវិតសាជាថ្មី។

សរុបសេចក្តីទៅ ទីមួយ សម្រាប់ព្រះសហគមន៍របស់យើង គឺសម្រាប់យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ យើងក៏ជាអ្នកមានបាបដែរ ប៉ុន្តែយើងបានទទួលការលើកលែងទោសពីព្រះជាម្ចាស់។ ព្រះសហគមន៍យើង ជាព្រះសហគមន៍ដ៏វិសុទ្ធ ប៉ុន្តែយើងម្នាក់ៗជាអ្នកមានបាបដែលបានទទួលការលើកលែងទោសពីព្រះជាម្ចាស់។ ប្រសិនបើយើងម្នាក់ៗជាគ្រីស្តបរិស័ទ មិនស្គាល់អំពីបាបរបស់ខ្លួនទេ មានន័យថា យើងឥតមានបទពិសោធន៍អំពីការលើកលែងទោសទេ។ ដូច្នេះ តើធ្វើដូចម្តេច ឲ្យព្រះសហគមន៍ទៅជាកន្លែងមួយ

ដែលស្វាគមន៍មនុស្សទាំងអស់ ឲ្យគេមានបទពិសោធន៍អំពីការលើកលែងទោសបាន? ។ ដូច្នេះសម្រាប់យើងដែលជាព្រះសហគមន៍ យើងត្រូវការមានបទពិសោធន៍អំពីការលើកលែងទោសនេះ ដើម្បីឲ្យយើងទៅជាមនុស្សម្នាក់ដែលអាចលើកលែងទោស និង អាចណែនាំឲ្យអ្នកដទៃបានទទួលការលើកលែងទោសនេះដែរ។

តាម (១ធម ១,១៥-១៦) មានចែងថា៖ "ពាក្យនេះគួរឲ្យជឿ ហើយសមនឹងទទួលយកទាំងស្រុង គឺថាព្រះគ្រីស្តយេស៊ូបានយាងមកក្នុងពិភពលោក ដើម្បីសង្គ្រោះមនុស្សបាបដូចរូបខ្ញុំនេះជាអាទិ៍។ ព្រះជាម្ចាស់ទ្រង់មានព្រះហឫទ័យ មេត្តាករុណាចំពោះខ្ញុំដូច្នេះ ដើម្បីឲ្យព្រះគ្រីស្តយេស៊ូសម្តែងព្រះហឫទ័យអត់ធ្មត់គ្រប់ជំពូកដល់រូបខ្ញុំមុនគេ និងឲ្យខ្ញុំធ្វើជាគម្រូដល់អស់អ្នកដែលជឿលើព្រះអង្គ ឲ្យទទួលជីវិតអស់កល្បជានិច្ច"។នេះជាសេចក្តីដែលលោកប៉ូលទទួលសារភាព គឺ គាត់ទទួលស្គាល់អំពើបាបរបស់គាត់។លោកប៉ូលបានទទួលការលើកលែងទោសពីព្រះយេស៊ូផ្ទាល់ នៅពេលគាត់បានជួបព្រះអង្គ ហើយគាត់អាចចែកបទពិសោធន៍នេះជាមួយនឹងបងប្អូនឯទៀតៗបាន។ ចំពោះយើង ប្រសិនបើយើងមិនដែល មានអារម្មណ៍ដូចលោកប៉ូល ឬដូចកូនពៅ ដែលបានទទួលស្គាល់អំពើបាបរបស់ខ្លួន និងដែលមានបទពិសោធន៍ពិតប្រាកដអំពីការលើកលែងទោសពីព្រះជាម្ចាស់ តាមរយៈអគ្គសញ្ញាលើកលែងទោសដែលយើងបានទទួលទេ តើធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាកន្លែងមួយសម្រាប់លើកលែងទោសឲ្យគេបាន?។ តែបើយើងដូចលោកប៉ូល ឬដូចកូនពៅ ឬដូចប៉ុន្មាននាក់ទៀត ដែលមានបទពិសោធន៍អំពីការលើកលែងទោសពីព្រះជាម្ចាស់ នោះយើងនឹងទៅជា មនុស្សថ្មី ដែលអាចនឹងទទួលស្វាគមន៍អ្នកដទៃដែលជាអ្នកមានបាប ជាមនុស្សតូចតាចដូចយើងបាន។ ដូច្នេះដើម្បីឲ្យព្រះ សហគមន៍ ទៅជាកន្លែងមួយឲ្យមនុស្សទាំងអស់អាចមកទទួលការលើកលែងទោស និងទទួលជីវិតថ្មីបាន នោះត្រូវតែ យើងម្នាក់ៗដែលជាព្រះសហគមន៍មានការពិសោធពីការលើកលែងទោសជាមុនសិន។ សម្រាប់និស្សិតទេវវិទ្យាល័យ អនាគតជាបូជាចារ្យគ្រប់ពេលវេលា ត្រូវតែមានបទពិសោធន៍អំពីការលើកលែងទោសនេះ។

ទីពីរ សម្រាប់សង្គមរបស់យើង ដោយសារយើងបានទទួលការលើកលែងទោស ដូច្នេះព្រះសហគមន៍របស់យើង ត្រូវទៅជាសញ្ញាសម្គាល់អំពីការលើកលែងទោសសម្រាប់សង្គមរបស់យើងដែរ។ពាក្យលើកលែងទោសជាពាក្យថ្មី ដែលឥតមាននៅក្នុងវប្បធម៌ពុទ្ធសាសនាទេ នៅក្នុងវប្បធម៌ពុទ្ធសាសនាមានចែងអំពីបាប និងបុណ្យ។ សម្រាប់យើង គឺមិនធ្វើបុណ្យសងបាប ដែលយើងបានធ្វើនោះទេ ដោយសារថាការលើកលែងទោសមានន័យថា នៅពេលខ្ញុំទទួលស្គាល់អំពើបាបរបស់ខ្ញុំ នៅពេលខ្ញុំទៅសូមព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំដោយអស់ពីក្នុងដួងចិត្តនោះ ខ្ញុំនឹងបានទទួលការលើកលែងទោស១០០%ពីព្រះអង្គ។ យើងជាព្រះសហគមន៍ ត្រូវធ្វើជាសាក្សីអំពីការលើកលែងទោសនេះនៅក្នុងសង្គម និង សូមឲ្យយើងអធិដ្ឋានដើម្បីបន្តិចម្តងៗ ឲ្យគេអាចទទួលបានសេចក្តីនេះ។

ប្រសិនបើព្រះសហគមន៍របស់យើងទៅជាកន្លែងមួយ ដែលមនុស្សទាំងអស់នៅក្នុងសង្គមមានអារម្មណ៍ថា ជា កន្លែងដែលយើងទទួលស្វាគមន៍គេ ស្រឡាញ់គេពិតមែន យើងមិនវិនិច្ឆ័យគេ យើងមិនបណ្តេញគេ នោះបន្តិចម្តងៗការ លើកលែងទោសនេះ អាចនឹងមានអត្ថន័យសម្រាប់ពួកគេ។ ការស្វាគមន៍ ជាជំហានទីមួយនៃការលើកលែងទោស ដើម្បី ឲ្យគេមានបទពិសោធន៍បន្តិចម្តងៗ អំពីការលើកលែងទោសរបស់ព្រះសហគមន៍យើង។សេចក្តីនេះណែនាំឲ្យយើងចូល នៅក្នុងព្រះសហគមន៍ដែលអធិដ្ឋាន

ដែលមានប្រាំចំណុចគឺ៖

ចំណុចទីមួយ អ្វីដែលណែនាំឲ្យមនុស្សទាំងអស់មានសេចក្ដីសង្ឃឹមមកលើព្រះសហគមន៍របស់យើង គឺដោយសារ ព្រះសហគមន៍ជាកន្លែងមួយដែលយើងជួបនឹងព្រះជាម្ចាស់។ យើងអាចជួបព្រះជាម្ចាស់តាមរយៈជួយអ្នកក្រីក្រ តាមរយៈការស្វាគមន៍ តាមរយៈការលើកលែងទោស ប៉ុន្តែការអធិដ្ឋានរបស់យើងពិតជាអាទិភាពពិតមែន ដែលយើងជួបនឹងព្រះជា ម្ចាស់របស់យើង។ នេះជាមូលហេតុ ដែលយើងត្រូវតែមានព្រះវិហារដែលស្អាតល្អម ដើម្បីឲ្យយើងយល់ថា យើងចេញពី លោកីយ៍នេះ ហើយយើងចូលនៅក្នុងទីសក្ការៈដែលយើងអាចជួបជាមួយព្រះជាម្ចាស់បាន។

នៅក្នុងសម្ព័ន្ធមេត្រីចាស់ពេលជនជាតិអ៊ីស្រាអែលធ្វើដំណើរគេតែងតែបោះជំរំនិង គេបោះតង់មួយដែលគេហៅ ថាព្រះពន្លា ដើម្បីគេជួបជាមួយព្រះជាម្ចាស់។ លោកម៉ូសេចូលក្នុងព្រះពន្លាដើម្បីជួបជាមួយព្រះជាម្ចាស់។ ចំពោះយើង គួរឲ្យមានកន្លែងគួរសមមួយ ដែលមានទូដាក់ព្រះកាយ ជាវត្តមានរបស់ព្រះយេស៊ូដែលមានព្រះជន្មនៅក្នុងព្រះកាយ គួរឲ្យ មានឈើឆ្កាង។ តាមព្រះវិហារនីមួយៗ ប្រសិនបើមិនចាក់សោរល្អជាងដើម្បីឲ្យគ្រីស្តបរិស័ទពីមួយថ្ងៃទៅមួយថ្ងៃ អាចចេញ ចូលដោយស្រួលដើម្បីអធិដ្ឋាន។ ព្រះវិហារត្រូវតែជាកន្លែងមួយដែលយើងអាចជួបព្រះជាម្ចាស់បាន។

ចំណុចទីពីរ ព្រះសហគមន៍ជាកន្លែងដែលយើងរំឭកអំពីព្រះយេស៊ូបូជាព្រះជន្ម។ ការថ្វាយអភិបូជាជារៀងរាល់ថ្ងៃ របស់យើងជាបូជាចារ្យ និងអនាគតជាបូជាចារ្យ ជាការសំខាន់ណាស់ ព្រោះមានន័យថាជារៀងរាល់ថ្ងៃ យើងបានចូលរួម ក្នុងសក្ការបូជារបស់ព្រះយេស៊ូ ដែលបូជាព្រះជន្មសម្រាប់មនុស្សលោកក្នុងពេលបច្ចុប្បន្ននេះដែរ។ ពិតមែនតែយើងនឹក រឭកអំពីអ្វី ដែលព្រះយេស៊ូធ្វើកាលពី ២០០០ ឆ្នាំមុន ប៉ុន្តែថ្ងៃនេះ ព្រះយេស៊ូបានបូជាព្រះជន្មសម្រាប់ខ្ញុំ ថ្ងៃនេះ ព្រះយេស៊ូបានបូជាព្រះជន្មសម្រាប់មនុស្សលោក។ ប្រសិនបើយើងជាព្រះសហគមន៍មិនចូលរួមក្នុងសក្ការបូជានេះទេ តើនរណាគេ នឹងធ្វើ?។

ចំណុចទីបី ព្រះសហគមន៍ទៅជាកន្លែងមួយ ដើម្បីទទួលជីវិតពីព្រះជាម្ចាស់តាមរយៈអគ្គសញ្ញានានា គឺគ្រីស្តបរិស័ទ ទទួលជីវិតពីព្រះជាម្ចាស់តែម្តង។

ចំណុចទីបួន តាម (កឡ ៣,១៥-១៦) " ចូរឲ្យយើងអរព្រះគុណព្រះជាម្ចាស់ជានិច្ច ចូរច្រៀងអរព្រះគុណព្រះអង្គក្នុងចិត្ត ដោយប្រើទំនុកតម្កើងបទសរសើរ បទចម្រៀងមកពីព្រះវិញ្ញាណ"។ ព្រះសហគមន៍ ត្រូវទៅជាកន្លែងដែលយើង អរព្រះគុណព្រះជាម្ចាស់ជានិច្ច ព្រោះនៅក្នុងពិភពលោក គ្មានកន្លែងណាទៀតក្រៅពីព្រះសហគមន៍ទេ។ សព្វថ្ងៃ មនុស្ស យើងមិនចេះមើលឃើញអ្វីដែលល្អ អ្វីដែលណែនាំឲ្យយើងមានអំណរសប្បាយទេ ដូច្នេះព្រះសហគមន៍ ត្រូវទៅជាកន្លែង មួយដែលបង្រៀន ដែលណែនាំមនុស្ស ដែលបើកភ្នែកមនុស្សឲ្យមើលឃើញអ្វីដែលស្អាតនៅក្នុងពិភពលោកយើង។ ព្រះ សហគមន៍ ត្រូវទៅជាកន្លែងមួយដែលណែនាំឲ្យយើងចេះអរព្រះគុណព្រះជាម្ចាស់អរព្រះគុណព្រះជាម្ចាស់នូវអ្វីដែលយើងបានទទួល។

ក្នុងមួយថ្ងៃៗ ឲ្យយើងរកឃើញចំណុចទាំងប៉ុន្មានដែលល្អស្អាតៗ ដើម្បីឲ្យជីវិតរបស់យើងមានកម្លាំងអាចទទួលនូវអ្វីដែលពិបាកបាន។ចូរឲ្យយើងយកពេលវេលាដើម្បីអរព្រះគុណព្រះជាម្ចាស់នៅក្នុងការអធិដ្ឋានរបស់ព្រះ សហគមន៍យើង។

ចំណុចទីប្រាំ ព្រះយេស៊ូគ្រីស្ត បានណែនាំឲ្យយើងឲ្យចេះទូលសន្ទនាទៅព្រះបិតាតាមរយៈធម៌ឱព្រះបិតា។ ដូច្នេះ ធម៌ឱព្រះបិតា ក៏ទៅជាធម៌មួយដែលបិញ្ចឹមជីវិតរបស់ព្រះសហគមន៍ និងបិញ្ចឹមគ្រប់សកម្មភាពដែលយើងមាន។ពេលយើងពិនិត្យមើលធម៌ឱព្រះបិតានោះយើងអាចមើលឃើញមានប្រាំចំណុច

ដូចតទៅ៖

១/ពេលយើងសូត្រថា "ឱព្រះបិតាអើយ" ពេលនោះរំឭកថា ខ្ញុំជាបុត្រធីតារបស់ព្រះជាម្ចាស់។ ពេលយើងចូលរួមអធិដ្ឋានជាមួយក្រុមផ្សេងៗ ហើយយើងសូត្រថា "ឱព្រះបិតាយើងខ្ញុំ" ពេលនោះណែនាំឲ្យយើងចូលនៅក្នុងទំនាក់ទំនងថ្មីជាមួយព្រះជាម្ចាស់ គឺយើងទាំងអស់គ្នាជាបុត្រធីតារបស់ព្រះជាម្ចាស់។ យើងមានឋានៈស្មើគ្នា យើងមានតម្លៃដូចគ្នា ទោះបីយើងជាអ្នកបាប ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់យើងស្មើៗគ្នា ដោយសារយើងជាបុត្រធីតារបស់ព្រះអង្គដូចគ្នា។

២/ "សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់" ឃ្លានេះ គឺសរុបគោលដៅនៃបេសកកម្មរបស់ព្រះសហគមន៍យើង ដែលប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។

៣/ "សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ" ឃ្លានេះសរុបសកម្មភាពជាស្នាដៃរបស់យើង ដែលបង្ហាញអំពីធម៌មេត្តាករុណាដល់មនុស្សដែលកំពុងខ្វះខាត។ ព្រះសហគមន៍ មានគោលដៅធ្វើឲ្យមនុស្សលោកមានអាហារជារៀងរាល់ថ្ងៃយ៉ាងពិតប្រាកដមែន។ អាហារមានន័យថា គ្រប់សេចក្តីត្រូវការរបស់មនុស្សដែលព្រះយេស៊ូប្រទានឲ្យយើង។

៤/ "សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសចំពោះយើងខ្ញុំ" ឃ្លានេះជាមធ្យោបាយក្នុងការបំពេញបេសកកម្មរបស់យើង។ ពេលអត់មានការលើកលែងទោស អត់មានការស្វាគមន៍ ពេលនោះក៏អត់មានព្រះសហគមន៍ដែរ។

៥/ "សូមកុំបណ្តោយឲ្យយើងខ្ញុំចាញ់ការល្បួង"។ ការល្បួងជាឧបសគ្គដែលយើងត្រូវតែជួបនៅក្នុងបេសកកម្ម របស់យើង។ ការល្បួងណែនាំឲ្យយើងស្វាគមន៍មិនបាន ណែនាំឲ្យយើងប្រកាសព្រះបន្ទូលមិនបាន ណែនាំឲ្យយើងលើកលែងទោសឲ្យគេមិនបានទេ។

ដូច្នេះនៅពេលយើងអធិដ្ឋានធម៌ "ឱព្រះបិតា" ចូរឲ្យយើងយកពេលវេលាអធិដ្ឋានឲ្យបានយូរបន្តិចឲ្យយើងសូត្រមួយៗ ដើម្បីមានឱកាសនឹកឃើញអត្ថន័យក្នុងពាក្យនីមួយៗនោះ និងដើម្បីឲ្យយើងរកឃើញជីវិតថ្មីដែលមានកប់នៅក្នុងពាក្យទាំងនោះ ទុកសម្រាប់ជាជីវិតរបស់ព្រះសហគមន៍យើងទាំងមូល៕

អាម៉ែន!

## អត្ថបទព្រះគម្ពីរ
## សម្រាប់ថ្ងៃទី១២/០៩/២០១៣ពេលរសៀល

### ប្រស្នាអំពីចៀមដែលបាត់ហើយរកឃើញវិញ

( លូកា ១៥ ម៉ាថាយ ១៨, ១២-១៤ )

១មានអ្នកទារពន្ធ* និងមនុស្សបាបទាំងអស់នាំគ្នាចូលមកជិតព្រះ
យេស៊ូ ស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ។ ២ពួកខាងគណៈផារីស៊ី*និងពួកធម្មា
ចារ្យ*រអ៊ូរទាំថា៖ " មើល៍! អ្នកនេះរាក់ទាក់នឹងមនុស្សបាប ព្រមទាំងបរិភោគ
ជាមួយគេផង!"។ ៣ព្រះយេស៊ូមានព្រះបន្ទូលទៅគេ ជាប្រស្នានេះថា៖ ៤"ក្នុង
បំណោមអ្នករាល់គ្នា ឧបមាថាមានម្នាក់មានចៀមមួយរយក្បាល បើគាត់បាត់
ចៀមមួយ គាត់មុខជាទុកចៀមកៅសិបប្រាំបួនចោលនៅទីវាល ហើយទៅ
តាមរកចៀមដែលបាត់នោះ រហូតទាល់តែបានឃើញវិញ។ ៥កាលរកឃើញ
ហើយគាត់ត្រេកអរណាស់ គាត់ក៏លើកចៀមដាក់លើក ៦ត្រឡប់មកផ្ទះវិញ
ហៅមិត្តភក្តិ និងអ្នកជិតខាងប្រាប់ថា "សូមជួយអរសប្បាយជាមួយខ្ញុំផង ដ្បិត
ចៀមរបស់ខ្ញុំដែលបាត់ទៅនោះ ឥឡូវនេះខ្ញុំរកឃើញវិញហើយ"។ ៧ខ្ញុំសុំប្រាប់
អ្នករាល់គ្នាថា ព្រះជាម្ចាស់នៅស្ថានបរមសុខ មានអំណរសប្បាយ ដោយមាន
មនុស្សបាបតែម្នាក់ កែប្រែចិត្តគំនិតខ្លាំងជាង ព្រះអង្គសប្បាយនឹងមនុស្ស
សុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការកែប្រែចិត្តគំនិត"។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១២/០៩/២០១៣ពេលរសៀល

## ប្រស្នាអំពីប្រាក់ដួងដែលបាត់ហើយរកឃើញវិញ

[៨]"ម្យ៉ាងទៀត ឧបមាថាស្ត្រីម្នាក់មានប្រាក់ដប់ដួង *ហើយបាត់មួយ
ដួងគាត់មុខជាអុជចង្កៀងបោសផ្ទះ  រកប្រាក់នោះគ្រប់កៀនកោះរហូតទាល់
តែបានឃើញវិញ។ [៩]លុះរកឃើញហើយ គាត់ក៏ហៅមិត្តភក្តិ និងអ្នកជិតខាង
ប្រាប់ថា "សូមជួយអរសប្បាយជាមួយខ្ញុំផង ដ្បិតប្រាក់ដួង *ដែលខ្ញុំបាត់នោះ
ឥឡូវនេះខ្ញុំរកឃើញវិញហើយ"។ [១០]ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ទេវទូត *របស់
ព្រះជាម្ចាស់នឹងមានអំណរសប្បាយជាខ្លាំង  ដោយមានមនុស្សបាបតែម្នាក់
កែប្រែចិត្តគំនិត"។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១២/០៩/២០១៣ពេលរសៀល

## ប្រស្នាអំពីកូនពៅដែលបាត់ហើយរកឃើញវិញ

១១ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ " មានបុរសមួយរូបមានកូន
ប្រុសពីរនាក់។ ១២កូនពៅនិយាយទៅឪពុកថា " លោកឪពុក! សូមចែក
កេរមត៌កឲ្យកូនមក"។ ឪពុកក៏ចែកមត៌កឲ្យកូន។ ១៣ប៉ុន្មានថ្ងៃក្រោយមក កូន
ពៅប្រមូលទ្រព្យសម្បត្តិ រួចចាកចេញទៅស្រុកឆ្ងាយ។ នៅស្រុកនោះកូនពៅ
បានខ្ជះខ្ជាយ បង្ហិនទ្រព្យសម្បត្តិរបស់ខ្លួនអស់ទៅ។ ១៤ពេលចាយវាយទ្រព្យ
សម្បត្តិអស់ហើយ ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់
ផ្ដើមខ្វះខាត។ ១៥គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ គេប្រើគាត់ឲ្យមើលជ្រូក
តាមស្រែចំការ។១៦គាត់ចង់បម្ពេតក្រពះនឹងចំណីដែលគេដាក់ឲ្យជ្រូកស៊ីនោះ
ណាស់តែគ្មានអ្នកណាឲ្យបរិភោគឡើយ។១៧ពេលនោះកូនពៅភ្ញាក់ខ្លួនហើយ
រិះគិតក្នុងចិត្តថា "អ្នកបម្រើរបស់ឪពុកអញសុទ្ធតែមានម្ហូបអាហារបរិភោគហូរ
ហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់។ ១៨អញត្រូវតែ
វិលត្រឡប់ទៅរកឪពុកអញវិញ ហើយជម្រាបគាត់ថា លោកឪពុកកូនបាន
ប្រព្រឹត្តអំពើបាប ខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្ត
អំពើបាបខុសនឹងលោកឪពុកដែរ។ ១៩មិនគួរឲ្យលោកឪពុករាប់ខ្ញុំនេះជាកូន
ទៀតទេ សូមលោកឪពុកចាត់ទុកកូនជាអ្នកបម្រើចុះ"។ ២០លុះគិតដូច្នោះ
ហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ
គាត់មានចិត្តអាណិតអាសូរក្រៃលែង ក៏រត់ទៅទទួលកូន ហើយឱបថើបទៀត
ផង។ ២១កូនពៅជម្រាបឪពុកថា៖ "លោកឪពុក កូនបានប្រព្រឹត្តអំពើបាប

ខុសនឹងព្រះហប្ញទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹង
លោកឪពុកដែរ មិនគួរឲ្យលោកឪពុករាប់ខ្ញុំនេះ ជាកូនទៀតទេ"។ ២២ឪពុក
ប្រាប់ពួកអ្នកបម្រើថា "ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុត មកពាក់ឲ្យកូន
ខ្ញុំជាប្រញាប់ហើយយកចិញ្ចៀន និងស្បែកជើងមកពាក់ឲ្យផង។ ២៣ចូរយក
កូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឲ្យសប្បាយចុះ ២៤ដ្បិត
កូនខ្ញុំនេះបានស្លាប់ទៅហើយ តែឥឡូវរស់ឡើងវិញ វាវង្វេងបាត់តែឥឡូវនេះ
ខ្ញុំរកឃើញវិញហើយ"។ គេនាំគ្នាជប់លៀងយ៉ាងសប្បាយ។ ២៥ពេលនោះ
កូនច្បងនៅឯចំការ។ កាលគាត់ត្រឡប់មកជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និង
ចម្រៀងរបាំ ២៦គាត់ហៅអ្នកបម្រើម្នាក់មកសួរថាមានការអ្វីកើតឡើង។ ២៧អ្នក
បម្រើឆ្លើយថា "ប្អូនលោកត្រឡប់មកវិញហើយ។ ឪពុករបស់លោកឲ្យគេកាប់
កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រឡប់មកវិញ
ដោយសុខសាន្ត"។ ២៨កូនច្បងខឹងណាស់ មិនព្រមចូលផ្ទះទេឪពុកចេញមក
អង្វរឲ្យចូល។ ២៩កូនច្បងនិយាយទៅឪពុកថា "ខ្ញុំបាននៅបម្រើលោកជាច្រើន
ឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុស នឹងបង្គាប់របស់លោកត្រង់ណាឡើយ តែ
លោកមិនដែលឲ្យកូនពពែ ដើម្បីឲ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែ
សោះ សូម្បីតែមួយក៏មិនដែលផង។ ៣០ពេលកូនលោកត្រឡប់មកវិញ លោក
បានកាប់កូនគោបំប៉នទទួលវា មើល៍វានេះ បានបំផ្លាញទ្រព្យសម្បត្តិលោក
ទាំងអស់ជាមួយស្រីញី"។ ៣១ឪពុកនិយាយទៅកូនថា"កូនអើយ ឯងនៅជា
មួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់
កូនដែរ។ ៣២យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់
ទៅនោះ ឥឡូវនេះរស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥឡូវនេះយើង
រកឃើញវិញហើយ"។



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម

### ១៣/០៩/២០១៣ (ព្រឹក)

ជម្រាបសួរលោកឪពុក! បងប្អូនទាំងអស់គ្នា!

ការសំណាក់ធម៌របស់យើងមកដល់ថ្ងៃចុងក្រោយហើយ។ នេះជាពេលវេលា ដែលយើងរិះគិតអំពីព្រះសហគមន៍ និងអំពីការត្រាស់ហៅ។ ជាធម្មតា ដើម្បីឲ្យព្រះសហគមន៍អាចបំពេញបេសកម្ម បំពេញតួនាទីរបស់ខ្លួនបាន នោះយើងត្រូវមានអ្នកដែលធ្វើការ គឺអ្នកបម្រើ។ ព្រឹកនេះ យើងនិយាយខ្លះៗ អំពីការត្រាស់ហៅ និងពេលរសៀលយើងនឹងនិយាយអំពី ព្រះសហគមន៍នៅក្នុងសង្គម រួចហើយយើងនឹងអធិដ្ឋានរួមគ្នា។ ពេលនេះយើងមានអត្ថបទពីរ ចេញពីសន្តៈលូកា ដែលទាក់ទងនឹងការត្រាស់ហៅ។

អត្ថបទទីមួយ គឺព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកសិលា រួចព្រះអង្គសុំឲ្យគាត់ចេញទូកទៅឆ្ងាយពីច្រាំងបន្តិច។ គួរឲ្យយើងចាប់អារម្មណ៍ដល់ពាក្យ " ទូក " និងអំពី " របៀបរបស់ព្រះយេស៊ូ " ដែលយើងធ្លាប់បាននិយាយហើយ។ ពេលនេះមិនមែនជាលោកសិលាទេដែលយាងព្រះយេស៊ូឲ្យចុះទូក គឺព្រះយេស៊ូទេ ដែលយាងចុះទូករបស់គាត់។ ទូកប្រៀប បីដូចជាផ្ទះរបស់លោកសិលាម៉្យាង ព្រោះថា ទូកជាឧបករណ៍ដែលគាត់ប្រើរហូតដើម្បីធ្វើការងារ។ អ្នកនេសាទអត់មានទូក ពួកគេមិនអាចធ្វើការអ្វីបានទេ ដូច្នេះទូកជាជីវិតរបស់គេ។ ពេលនេះយើងបានឃើញម្តងទៀតអំពីរបៀបរបស់ព្រះយេស៊ូ គឺទីមួយ ព្រះអង្គមិនរង់ចាំឲ្យលោកសិលាយាងព្រះអង្គទេ។ប្រសិនបើយើងនិយាយអំពីនិមិត្តរូបរបស់ព្រះសហគមន៍ នោះគឺ៖

១/ " ព្រះសហគមន៍ប្រៀបដូចជាទូក "។ ទូកជាឧបករណ៍សម្រាប់អ្នកនេសាទត្រីធ្វើការងាររបស់គេ ដូច្នេះមានន័យ ថា ព្រះសហគមន៍ជាកន្លែងដែលគ្រីស្តបរិស័ទធ្វើការងាររបស់ខ្លួន ដែលចាប់អារម្មណ៍នឹងការរស់នៅរបស់មនុស្សឯទៀតៗ។ពេលនេះព្រះយេស៊ូមិនយាងទៅធម្មសាលាដើម្បីត្រាស់ហៅសាវ័កទេប៉ុន្តែព្រះអង្គជ្រើសរើសយកទូកដែលជាឧបករណ៍របស់អ្នកនេសាទក្នុងការចាប់ត្រី ដើម្បីត្រាស់ហៅសាវ័ក។ដូច្នេះមានន័យថា ព្រះសហគមន៍ក៏ត្រូវតែយកចិត្តទុកដាក់នឹងការ រស់នៅរបស់មនុស្សម្នាក់ៗដែរ គឺព្រះសហគមន៍ត្រូវការដឹង និងត្រូវការស្គាល់គេម្នាក់ៗ។ សព្វថ្ងៃ តើយើងស្គាល់ឈ្មោះ គ្រីស្តបរិស័ទនៅក្នុងព្រះសហគមន៍របស់យើង បានប៉ុន្មាននាក់? ស្គាល់ឈ្មោះមានន័យថា ស្គាល់ខ្លះៗអំពីការរស់នៅរបស់គេ។ មនុស្សយើងម្នាក់ៗមានព្រំដែន យើងមិនដូចព្រះយេស៊ូដែលស្គាល់យើងម្នាក់ៗតាំងពីដើមរៀងមកនោះទេ។ ពេលនេះព្រះយេស៊ូយាងចេញទៅគង់នៅក្នុងទូករបស់លោកសិលា ព្រះអង្គមិនរង់ចាំឲ្យលោកសិលាយាងព្រះអង្គទេ គឺព្រះអង្គយាង ចុះទៅគង់នៅក្នុងទូករបស់គាត់វិញ។ ព្រះសហគមន៍របស់យើងក៏ត្រូវតែដូច្នោះដែរ គឺត្រូវចេញទៅដើម្បីទៅដល់កន្លែងដែល គេរស់នៅ ទោះបីគេមិនអញ្ជើញឲ្យយើងទៅក៏ដោយ។

២/"ព្រះយេស៊ូបង្រៀនគេ"គឺព្រះអង្គគង់នៅក្នុងទូកហើយបង្រៀនបណ្តាជន។ដូច្នេះព្រះសហគមន៍

ក៏មានតួ នាទីបង្រៀនគេដែរ គឺព្រះសហគមន៍អប់រំគេឲ្យស្គាល់ព្រះជាម្ចាស់ដែលស្រឡាញ់គេ និងឲ្យគេស្គាល់ អំពីសេចក្ដីត្រូវការដ៏ ពិតប្រាកដនៃជីវិតរបស់គេ មុនព្រះសហគមន៍ត្រាស់ហៅគេ និងមុនព្រះសហគមន៍ ប្រគល់មុខងារបម្រើដល់គេ។ ដោយ សារហេតុនេះហើយ បានជាយើងបង្កើតសាលាអប់រំជំនឿសម្រាប់ គ្រីស្តបរិស័ទ ដើម្បីឲ្យគេរឹងមាំខាងជំនឿ និង ឲ្យគេបាន ដឹងនូវអ្វីៗដែលគេមិនទាន់បានដឹង។ យើងក៏មានរៀប ចំសន្និបាតផ្សេងៗទៀតដែរ ជួនកាលយើងបង្កើតកម្មវិធីតែមួយម៉ោង ឬ ពីរម៉ោងប៉ុណ្ណោះដើម្បីអប់រំយុវជន យុវនារី។ យើងមានទេវវិទ្យាល័យជាកន្លែងអប់រំ និង ពិនិត្យមើលយ៉ាងពិសេស អំពីការ ត្រាស់ហៅ មុននឹងឲ្យ គេទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ។ ទាំងអស់នេះជាតួនាទីរបស់ព្រះសហគមន៍របស់យើង។

៣/ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់លោកសិលាថា " ចូរបង្ហួសទូកទៅកន្លែងទឹកជ្រៅ " នេះមាន អត្ថន័យពីរយ៉ាង ដ៏សំខាន់គឺ ទី១ ព្រះសហគមន៍ត្រូវតែចូលយ៉ាងជ្រៅនៅក្នុងដួងចិត្ត ក្នុងអារម្មណ៍ និងក្នុង វិញ្ញាណរបស់មនុស្សលោក។ ដូច្នេះព្រះសហគមន៍ត្រូវតែមានបច្ចេកទេសយ៉ាងខ្ពស់អំពីចិត្តគំនិត របស់ មនុស្ស។ បូជាចារ្យទាំងអស់ត្រូវតែជា " បណ្ឌិត " ខាងចិត្តមនុស្ស ដូចសម្ដេចប៉ាបប៉ូលទី ៦ មានប្រសាសន៍ថា " ព្រះសហគមន៍ត្រូវមានបច្ចេកទេសខ្ពស់បំផុត នៅក្នុងការ យល់ដឹងពីចិត្តគំនិតរបស់មនុស្ស"។ ពេលនៅ ទេវវិទ្យាល័យជាឱកាសឲ្យយើងយល់ដឹង ដើម្បីចូលយ៉ាងជ្រៅនៅក្នុងចិត្ត គំនិតផ្ទាល់ខ្លួន និងក្នុងចិត្ត គំនិត របស់មនុស្សលោក។ ពិតមែនយើងត្រូវការប្រើទាំងចំណេះដឹងផង និងយើងត្រូវការបន្ថែម ចិត្តវិជ្ជាខ្លះៗ ដែរ។ តើយើងចាប់អារម្មណ៍នឹងការរស់នៅរបស់គេឬអត់? ប្រសិនបើយើងមិនយល់អំពីចិត្តគំនិតរបស់មនុស្សម្នាក់ ដែលយើងកំពុងមើល ដែលយើងកំពុងនិយាយជាមួយ នោះយើងមិនអាចចូលយ៉ាងជ្រៅក្នុងចិត្តរបស់គេ បានទេ។ តាមពិត ព្រះសហគមន៍របស់យើង ជាព្រះសហគមន៍ដែលគ្មានព្រំដែន ជាព្រះសហគមន៍ដែល ត្រូវទៅគ្រប់ទីកន្លែង...។ ទី២ " ទឹកជ្រៅ " ក៏មានន័យថា ព្រះយេស៊ូអញ្ជើញយើងឲ្យទុកចិត្តលើព្រះអង្គដែរ ព្រោះថាលោកសិលាក្ដី ឬយើងសព្វថ្ងៃក្ដី យើងតែងតែខ្លាចកន្លែងដែលមានទឹកជ្រៅ។ ពេលព្រះយេស៊ូសូម ឲ្យទៅទឹកជ្រៅ គឺព្រះអង្គណែនាំឲ្យយើងទុកចិត្តលើព្រះ អង្គព្រះអង្គណែនាំកុំឲ្យយើងខ្លាចកន្លែង ដែលយើង មិនស្គាល់កន្លែង ដែលយើងមិនដែលទៅ កន្លែងដែលយើងខ្លាចកន្លែង ដែលយើងគិតថា អត់មាន សុវត្ថិភាព...។ ព្រះសហគមន៍មិនត្រូវការឲ្យយើងទៅកន្លែងដែលមានសុវត្ថិភាព ប៉ុន្តែ ឲ្យយើងរស់នៅដោយ មានអារម្មណ៍សុវត្ថិភាពវិញ។ សម្ដេចប៉ាបបានមានប្រសាសន៍ថា " ទោះបីព្រះសហគមន៍ធ្លាប់ធ្វើកិច្ចការ ដដែលៗ ប៉ុន្តែមិនមានន័យថា យើងមិនអាចដូរបានទេ។ ព្រះសហគមន៍ត្រូវការ ដូររហូតព្រះសហគមន៍ ត្រូវការថ្មីរហូត់ "។

៤/ លោកសិលាមានប្រសាសន៍ថា " បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យ របស់លោកគ្រូ "។ បន្ទាប់មកលោកសិលាបានធ្វើតាមបង្គាប់របស់ព្រះយេស៊ូ។ លោកសិលាមាន ប្រសាសន៍ បន្ថែមថា " ឱព្រះអម្ចាស់អើយ សូមយាងឲ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប។ ដូច្នេះលោក សិលាបានធ្វើតាមអ្វីដែលព្រះយេស៊ូបានបង្គាប់ទៅ គាត់ ប៉ុន្តែគាត់ទទួលស្គាល់ថា ខ្លួនគាត់ជាមនុស្សទន់ ខ្សោយមិនរឹងមាំទេ។ ដូចគ្នាដែរ ព្រះសហគមន៍ក៏បានត្រាស់ហៅ មនុស្សបាប មនុស្សទន់ខ្សោយ ឲ្យទៅជា មនុស្សដែលមានកម្លាំងដ៏អស្ចារ្យវិញ។ ប្រសិនបើយើងពិនិត្យមើលអំពីការត្រាស់ ហៅកន្លងមក ទាំងលោក អេសាយ លោកអាប្រាហាំ នាងម៉ារី លោកប៉ូល ជាដើម...ពួកគាត់ក៏មនុស្សមានបាបដែរ។

៥/ព្រះយេស៊ូមានព្រះបន្ទូលថា " កុំខ្លាចអី " គឺព្រះអង្គផ្តល់កម្លាំងឲ្យយើង។ ព្រះយេស៊ូទទួលស្គាល់

ថា លោកសិលាជាអ្នកមានបាប ប៉ុន្តែព្រះអង្គបំភ្លឺឲ្យគាត់មានសមត្ថភាពអាចបំពេញកិច្ចការបាន នេះគឺដោយសារព្រះយេស៊ូផ្ទាល់បាន ត្រាស់ហៅគាត់។ ដូចគ្នានេះដែរ ព្រះសហគមន៍ក៏ត្រូវតែទទួលស្គាល់នឹងផ្តល់កម្លាំងឲ្យអស់អ្នកដែលព្រះសហគមន៍បាន តាស្រែហៅគេ។ ពាក្យ "កុំខ្លាចអី" ណែនាំឲ្យយើង មានកម្លាំងយ៉ាងខ្លាំង ពាក្យនេះចេញមកពីព្រះឱស្ឋរបស់ព្រះយេស៊ូផ្ទាល់ និង ចេញមកពីព្រះសហគមន៍ដែរ។

៦/ ព្រះយេស៊ូមានព្រះបន្ទូលថា "ពីពេលនេះតទៅ អ្នកនឹងនេសាទមនុស្សវិញ" នេះជាបេសកកម្មដែលព្រះយេស៊ូ ប្រទានឲ្យយើងជាព្រះសហគមន៍ ទៅជាអ្នកបម្រើមនុស្សលោក។ សម្តេចប៉ាបយ៉ូហានប៉ូលទី ២ បានសរសេរអំពីរបៀប ដែលព្រះសហគមន៍អប់រំថា "ព្រះសហគមន៍ត្រូវតែអប់រំគេឲ្យទៅមនុស្សដ៏ពេញលក្ខណៈ" មានន័យថា គ្រប់វិស័យដែលប៉ះពាល់នឹងមនុស្ស និង ចិត្ត វិញ្ញាណ នយោបាយ សង្គមកិច្ចសេដ្ឋកិច្ច គឺព្រះសហគមន៍ត្រូវតែអប់រំ។ ពេលដែលព្រះយេស៊ូ ប្រាប់លោកសិលាឲ្យនេសាទមនុស្ស មានន័យថា គឺព្រះសហគមន៍ជាអ្នកបម្រើមនុស្សនៅក្នុងគ្រប់វិស័យ។ មនុស្សម្នាក់ៗ មិនមែនសំដៅតែខួរក្បាលមួយបេះដូងមួយ ឬរូបកាយមួយរបស់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែមនុស្សម្នាក់ៗ ក៏ត្រូវតែស្ថិតនៅក្នុងទំនាក់ទំនងសង្គមដែរ គឺមានទំនាក់ទំនងជាមួយនយោបាយ ជាមួយសេដ្ឋកិច្ច ជាមួយចិត្តផ្ទាល់ខ្លួន ជាមួយប្រាជ្ញារបស់ខ្លួនដែរ។ នៅសាលាកាតូលិក យើងអប់រំគេឲ្យចូលនៅក្នុងទំនាក់ទំនងទាំងអស់នេះ យើងមិនអប់រំឲ្យគេមានតែចំណេះដឹងទេ តែយើងអប់រំគេលើគ្រប់វិស័យ ដែលទាក់ទងនឹងមនុស្ស និង សង្គម ដើម្បីកសាងចិត្តគំនិតរបស់គេ។ យើងជាព្រះសហគមន៍ ត្រូវតែជា "បណ្ឌិតជាន់ខ្ពស់" ក្នុងការស្គាល់មនុស្សលោក ដើម្បីអប់រំដឹកនាំនិង បម្រើមនុស្សលោក ដោយដឹងថា មនុស្សម្នាក់ៗមិនសំដៅតែរូបកាយមួយ ឬខួរក្បាលមួយទេ ប៉ុន្តែជាខួរក្បាលផង ជារូបកាយផង និងជាចិត្តផងដែរ ហើយទាំងអស់នេះ មានទាក់ទងក្នុងគ្រប់វិស័យរបស់មនុស្សផង។ មានអត្ថបទមួយទៀត ចែងអំពីព្រះយេស៊ូជ្រើសរើស សាវ័ក ៧២ នាក់ គឺមានន័យថា សព្វថ្ងៃព្រះអង្គក៏ត្រាស់ហៅឲ្យយើងបំពេញបេសកកម្មដែរ ដែលមាន ៧ ចំណុច គឺ៖

ចំណុចទី១ មុនព្រះយេស៊ូត្រាស់ហៅគេ ព្រះអង្គមានព្រះបន្ទូលថា "ហេតុនេះចូរអង្វរម្ចាស់ស្រែឲ្យបាត់អ្នកច្រូតមក ក្នុងស្រែរបស់លោក"។ សព្វថ្ងៃព្រះសហគមន៍មានតួនាទីជាអ្នកត្រាស់ហៅ មុនពេលព្រះសហគមន៍ចាត់គេឲ្យទៅ នោះព្រះ សហគមន៍ត្រូវតែបន្តការអធិដ្ឋានរបស់ខ្លួន អង្វរសូមព្រះជាម្ចាស់ប្រទានអ្នកច្រូតមកក្នុងស្រែរបស់ព្រះអង្គថែមទៀត ដ្បិតមានស្រែច្រើន តែមានអ្នកច្រូតតិចពេក។ ម្យ៉ាងទៀតពេលសាបព្រោះ វាស្រួលជាងពេលយើងច្រូតកាត់ ដូច្នេះយើងត្រូវការអ្នកច្រូតដើម្បីអប់រំគេ អំពីការច្រូតកាត់ ។ជាក់ស្តែងដូចខ្ញុំ និងលោកគ្រូជៀងនៅចម្ការទៀង យើងបានសាបព្រោះ ៦ កន្លែង ដូច្នេះយើងត្រូវការអ្នកច្រូតច្រើនណាស់។ ដោយសារហេតុនេះហើយ បានជាយើងអធិដ្ឋានហើយអធិដ្ឋានទៀត ដើម្បីឲ្យ គ្រីស្តបរិស័ទយល់ថាគេមានតួនាទីជាអ្នកច្រូតកាត់នៅក្នុងស្រែរបស់ព្រះជាម្ចាស់។

ចំណុចទី២ ព្រះយេស៊ូមានព្រះបន្ទូលថា "ខ្ញុំចាត់អ្នករាល់គ្នាទៅ ដូចឲ្យកូនចៀមទៅនៅកណ្តាលហ្វូងចចក"។ ព្រះយេស៊ូមិនលាក់ការពិតថា អ្នកប្រកាសដំណឹងល្អ អ្នកដែលដើរតាមព្រះអង្គ នឹងត្រូវជួបឧបសគ្គដ៏ច្រើន និងត្រូវលីឈើឆ្កាងនោះទេ។ ក្នុងធម្មទេសនាទីមួយរបស់សម្តេចប៉ាប នៅពេលលោកទទួលតួនាទីជាអភិបាលទីក្រុងរ៉ូម លោកបានមាន ប្រសាសន៍ទៅដល់លោកអភិបាល លោកកាឌីណាល់ និង ដល់បូជាចារ្យទាំងពិភពលោកទាំងមូល និង ដល់ខ្លួនលោក ផ្ទាល់ថា "ប្រសិនបើយើងជាសាវ័ករបស់ព្រះយេស៊ូមិនសុខចិត្តលីឈើឆ្កាង នោះយើងមិនមែនជាសាវ័កពិតប្រាកដរបស់ព្រះយេស៊ូទេ។ ជាដំបូងគឺយើង ជួបឧបសគ្គ ជួបបញ្ហា និងជួបទុក្ខលំបាកជាច្រើន បើសិនយើងមិនជួបឧបសគ្គទេ មានន័យថា យើងនៅជាប់

នឹងលោកីយ៍យ៉ាងខ្លាំងហើយ "។ ដូច្នេះ ព្រះសហគមន៍ត្រូវតែយល់ថា ការដើរតាមព្រះយេស៊ូ មិនមែនជារឿងមួយដែលស្រួលទេ។

ចំណុចទី៣ ព្រះយេស៊ូមានព្រះបន្ទូលថា " កុំយកថង់ប្រាក់ ថង់យាម ឬ ស្បែកជើង និង អ្វីៗទៅជាមួយឡើយ "។ ព្រះបន្ទូលនេះចង់បង្ហាញថា ព្រះសហគមន៍ត្រូវតែមានរបៀបរស់នៅយ៉ាងសាមញ្ញ ត្រូវធ្វើដូចម្ដេចដើម្បីឲ្យទាំងអ្នកក្រ ទាំង អ្នកមាន គេមានអារម្មណ៍ថា យើងស្វាគមន៍គេ។

ចំណុចទី៤ នៅពេលចូលក្នុងរបងផ្ទះគេ ត្រូវពោលថា " សូមព្រះជាម្ចាស់ប្រទានសេចក្ដីសុខសាន្តដល់មនុស្សនៅ ក្នុងផ្ទះនេះ "។ ព្រះសហគមន៍ត្រូវធ្វើកិច្ចការនេះមុនគេបង្អស់ ព្រោះកិច្ចការនេះបង្ហាញថា យើងគឺជាសាក្សីនៃសេចក្ដីសុខសាន្ត យើងជាអ្នករៀបចំផ្លូវថ្វាយព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គយាងមកបាន។ ព្រះយេស៊ូចាត់គេឲ្យទៅតាមភូមិ តាមឃុំដែល ព្រះអង្គបម្រុងនឹងយាងទៅ គឺព្រះអង្គចាត់គេឲ្យទៅមុន។ ព្រះសហគមន៍មានតួនាទី ដូចលោកយ៉ូហានបាទីស្ដ ដែលបង្ហាញផ្លូវ ដែលរៀបចំផ្លូវ ឲ្យគេទៅជួបព្រះយេស៊ូនៅក្នុងជីវិតរបស់គេម្នាក់ៗ។ដូច្នេះមុនអ្វីៗទាំងអស់គឺឲ្យគេមានសេចក្ដីសុខសាន្តបើសិនក្នុងជីវិតគ្មានសេចក្ដីសុខសាន្តទេ នោះគេមិនអាចទទួលព្រះយេស៊ូនៅក្នុងជីវិតរបស់គេបានទេ។ សេចក្ដីសុខសាន្ត សម្រាប់មនុស្សម្នាក់ៗ មានអត្ថន័យផ្សេងៗពីគ្នា នេះជាមូលហេតុដែលយើងត្រូវយល់ចិត្តរបស់គេ។ មនុស្សខ្លះសេចក្ដីសុខ សាន្តគឺមានការងារធ្វើ មនុស្សខ្លះសេចក្ដីសុខសាន្តគឺមានជីប្រើនហិកតា "។ ដូច្នេះ យើងត្រូវការយល់អំពីសេចក្ដីត្រូវការ របស់គេ ដើម្បីឲ្យយើងណែនាំឲ្យគេមានសេចក្ដីសុខសាន្តនៅក្នុងជីវិតរបស់គេពិតមែន។

ចំណុចទី៥ "ចូលទៅស្នាក់នៅផ្ទះនោះ ហើយបរិភោគអាហារដែលគេជូនឲ្យអ្នករាល់នោះទៅចុះ "។ នេះជា របៀបមួយសំខាន់ណាស់ គឺយើងត្រូវការអង្គុយជាមួយគេ នៅជាមួយគេ និងស្ដាប់គេ...។ មិនមែនគេដែលអញ្ជើញព្រះ សហគមន៍ឲ្យទៅនៅជាមួយគេ គឺព្រះសហគមន៍ជាអ្នកទៅនៅជាមួយគេដើររកគេ ធ្វើដំណើរជាមួយគេស្គាល់គេ រស់នៅជាមួយគេ សួរសុខទុក្ខគេ លើកទឹកចិត្តគេ...។

ចំណុចទី៦ " ត្រូវប្រោះអ្នកជំងឺក្នុងភូមិនោះឲ្យបានជា ហើយប្រាប់អ្នកភូមិថាព្រះរាជ្យរបស់ព្រះជាម្ចាស់នៅជិតអ្នករាល់គ្នាហើយ"។ព្រះសហគមន៍ប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរបៀបដែលព្រះយេស៊ូប្រកាសដំណឹង ល្អ គឺព្រះសហគមន៍ត្រូវមានសញ្ញាសម្គាល់ជាក់ស្ដែងឲ្យគេឃើញ ដូចព្រះយេស៊ូដែរ។

ចំណុចទី៧ " ប៉ុន្តែកាលបើអ្នករាល់គ្នាចូលទៅភូមិណាមួយហើយ គេមិនទទួលអ្នករាល់គ្នាទេ នោះអ្នករាល់គ្នាត្រូវ ចេញទៅប្រកាសនៅតាមទីផ្សារទៅ "។ នេះជាចំណុចមួយដ៏សំខាន់ ដោយសារព្រះសហគមន៍ទុកសេរីភាពឲ្យគេ គឺមិនបង្ខំគេឡើយ។ យើងបង្កើតទំនាក់ទំនងជាមួយគេ សន្ទនាជាមួយគេ ស្នាក់នៅជាមួយគេ ប្រសិនបើគេទទួលយើង នោះយើង អាចបន្តរហូតដល់ព្រះយេស៊ូជួបជាមួយគេ។ ព្រះសហគមន៍ទទួលស្គាល់សិទ្ធរបស់មនុស្សម្នាក់ៗគឺម្នាក់ៗមានសិទ្ធិស្ដាប់មានសិទ្ធិស្គាល់ព្រះយេស៊ូប៉ុន្តែគាត់មានសេរីភាពនឹងទទួលព្រះយេស៊ូ ឬមិនទទួល។ យើងបំពេញសិទ្ធិរបស់គេ ដោយឲ្យ គេបានស្ដាប់បានស្គាល់ ព្រះយេស៊ូនិងក្រោយមកម្នាក់ៗមានសេរីភាពផ្ទាល់ខ្លួន។ មានន័យថា កុំឲ្យយើងប្រើយុទ្ធសាស្ត្រ ក្នុងការប្រកាសដំណឹងល្អឡើយ គឺយើងមានតែព្រះយេស៊ូ យើងមានតែដំណឹងល្អ យើងមានតែចិត្តធម៌មេត្តាករុណា ដែលយើងបានទទួលពីព្រះយេស៊ូ ហើយយើងបំពេញតួនាទីរបស់យើងដោយចិត្តស្រឡាញ់ ដោយលើកលែងទោស ដោយសន្ទនា និងដោយស្វាគមន៍ប៉ុណ្ណោះ...។ តាមលូកា ១០,១៧ យើងរកឃើញអំពីរបៀបប្រកាសដំណឹងល្អដូច

តទៅ គឺទីមួយ ព្រះសហគមន៍ត្រាស់ហៅ ទីពីរ ព្រះយេស៊ូចាត់ឲ្យទៅ និង ទីបីការត្រឡប់មកវិញ ដោយអំណរសប្បាយ និង គេធ្វើបាយ ការណ៍ថ្វាយព្រះយេស៊ូរបស់ពួកសាវ័ក។ ទីបញ្ចប់ខ្ញុំបាននិយាយអំពី " ព្រះសហគមន៍ត្រាស់ហៅ ព្រះសហគមន៍ចាត់ឲ្យទៅ និង ព្រះសហគមន៍អញ្ជើញ ឲ្យយើងត្រឡប់មកវិញដើម្បីធ្វើរបាយការណ៍ " គឺមានន័យថា សព្វថ្ងៃព្រះសហគមន៍ត្រាស់ហៅគ្រប់គ្រីស្តបរិស័ទទាំងអស់ ឲ្យបម្រើព្រះសហគមន៍តាមរបៀបដែលព្រះយេស៊ូបានរៀបចំទុកមកសម្រាប់យើង ដែលជាបូជាចារ្យ ជាក្រុមអ្នកបួសជា គ្រីស្តក្រុមគ្រីស្តបរិស័ទដែលផ្ញើជីវិតលើព្រះយេស៊ូតាមរបៀបយ៉ាងពិសេស ជាគ្រីស្តបរិស័ទធម្មតាដែលបម្រើព្រះសហគមន៍ តាមរបៀបរបស់គេផ្ទាល់ដែរ។ ប្រសិនបើយើងចង់កសាងព្រះសហគមន៍នៅកម្ពុជា ដោយសង្ឃឹមតែលើបូជាចារ្យលើអ្នកបួសខ្មែរនោះយើងមិនអាចធ្វើអ្វីបានទេដោយសារយើងមានគ្នាតិចណាស់។ខ្ញុំសង្ឃឹមលើយុវជនយុវនារីយើងទាំងអស់ ឲ្យគេបានស្តាប់ឮសម្លេងត្រាស់ហៅរបស់ព្រះសហគមន៍ ឲ្យគេបម្រើព្រះសហគមន៍តាមរបៀបណាមួយ ឬតាមការត្រាស់ហៅពិសេស គឺឲ្យទៅជាអ្នកបួស និងទទួលការ ត្រាស់ហៅទូទៅ ឲ្យទៅជាគ្រីស្តបរិស័ទគម្រូ ដែលអប់រំកូនៗឲ្យបានល្អ ដោយខិតខំបម្រើព្រះសហគមន៍ ដោយចូលព្រះវិហារយ៉ាងទៀងទាត់ "។ សំខាន់ឲ្យគ្រីស្តបរិស័ទយើងទាំងអស់គ្នាយល់ដឹងថា ព្រះសហគមន៍ត្រាស់ហៅគេ ហើយព្រះសហគមន៍ក៏មានកន្លែងសម្រាប់គេដែរ។ ក្នុងឱកាសនេះ ខ្ញុំសូមអធិដ្ឋានសម្រាប់បុតធីតា ដែលបានស្ម័គ្រចិត្តបម្រើព្រះយេស៊ូអស់មួយជីវិត ដោយបានផ្ញើ ជីវិតទាំងស្រុងលើព្រះអង្គ ៤ ឬ ៥ ឆ្នាំ មកហើយដើម្បីបេញទៅពីរនាក់ៗ បម្រើនៅតាមកន្លែងផ្សេងពីបូជាចារ្យ និងផ្សេងពីបព្វជិតបព្វជិតា។ ខ្ញុំសូមជំរុញយុវជនយុវនារីមួយចំនួន ដែលចង់បម្រើព្រះសហគមន៍អស់មួយជីវិត តែគេមិនទាន់ទំលួម ដើម្បីឲ្យព្រះជាម្ចាស់បេះគេ សូមឲ្យគេមានបទពិសោធ ៤ ឆ្នាំ ៥ ឆ្នាំ ជាមួយព្រះសហគមន៍សិន ជាពិសេសឲ្យគេមានបទពិសោធតាមភូមិ និងដើម្បីឲ្យព្រះយេស៊ូចាក់ឫសយ៉ាងជ្រៅក្នុងចិត្តរបស់គេម្នាក់ដែរ។ អាម៉ែន។

## អត្ថបទព្រះគម្ពីរ
## សម្រាប់ថ្ងៃទី១៣/០៩/២០១៣ពេលព្រឹក

១ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងកេនេសារ៉ែត មានបណ្ដាជន
ជាច្រើនប្រជ្រៀតគ្នា នៅជុំវិញព្រះអង្គ ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជា
ម្ចាស់។ ២ព្រះអង្គទតឃើញទូកពីរចតនៅមាត់ប្រាំង រីឯអ្នកនេសាទនាំគ្នាបុះ
ទៅលាងអួនរបស់គេ។ ៣ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួច
ទ្រង់សុំឲ្យគាត់ចេញទូកទៅឆ្ងាយពីប្រាំងបន្ដិច។ ព្រះអង្គគង់ បង្រៀនបណ្ដា
ជនពីក្នុងទូកនោះ។ ៤លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូល
ទៅកាន់លោកស៊ីម៉ូនថា៖"ចូរបង្ហួសទូកទៅទឹកជ្រៅរួចនាំគ្នាទម្លាក់អួនចុះ"។
៥លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ " លោកគ្រូ! យើងខ្ញុំបានអូសអួន
ពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែបើលោកគ្រូមានប្រសាសន៍ដូច្នេះ
ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ "។ ៦គេក៏ទម្លាក់អួនទៅក្នុងទឹកជាប់
ត្រីយ៉ាងច្រើន ស្ទើរតែធ្លាយអួន។ ៧គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយ
ទៀត ឲ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរ
តែនឹងលិច។ ៨ពេលលោកសិលាឃើញដូច្នោះ គាត់ក្រាបទៀបព្រះបាទាព្រះ
យេស៊ូទូលព្រះអង្គថា៖ " ព្រះអម្ចាស់អើយ សូមយាងឲ្យឆ្ងាយ ពីទូលបង្គំទៅ
ព្រោះទូលបង្គំជាមនុស្សបាប"។ ៩លោក ស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់និង
អស់អ្នកដែលនៅជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រី ច្រើន
យ៉ាងនេះ។ ១០រីឯលោកយ៉ាកុបនិងលោកយ៉ូហាន ជាកូនលោកសេបេដេ ដែល
នេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។ ប៉ុន្តែព្រះយេស៊ូមាន
ព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖"កុំខ្លាចអី!ពីពេលនេះទៅមុខអ្នកនឹងនេសាទ
មនុស្សវិញ "។ ១១ពេលទូកទៅដល់មាត់ប្រាំងវិញ គេបោះបង់របស់របរទាំង
អស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូទៅ។

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១៣/០៩/២០១៣ពេលព្រឹក

## ព្រះយេស៊ូចាត់សាវ័ក ៧២ រូប ទៅផ្សាយដំណឹងល្អ

(លូកា ១០, ១-១៦)

១ក្រោយមក ព្រះអម្ចាស់ជ្រើសយកសាវ័ក* ចិតសិបពីររូបទៀត ហើយចាត់គេពីរៗនាក់ ឲ្យទៅតាម
ភូមិ តាមស្រុកនានា ដែលព្រះអង្គបម្រុងនឹងយាងទៅ។ ២ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ " ស្រូវដែលត្រូវ
ច្រូតមានច្រើនណាស់ តែអ្នកច្រូតមានតិចពេក។ ហេតុនេះ ចូរអង្វរម្ចាស់ស្រែឲ្យចាត់អ្នកច្រូតមកក្នុងស្រែរបស់
លោក។ ៣ចូរនាំគ្នាទៅចុះ! ខ្ញុំចាត់អ្នករាល់គ្នាទៅ ដូចឲ្យកូនចៀមទៅកណ្ដាលហ្វូងចចក។ ៤កុំយកថង់ប្រាក់
ថង់យាមឬ ស្បែក ជើងទៅជាមួយឡើយ ហើយក៏កុំជម្រាបសួរអ្នកណាតាមផ្លូវដែរ។ ៥ពេលអ្នក
រាល់គ្នាចូលទៅក្នុងផ្ទះណាមួយ មុនដំបូងត្រូវពោលថា " សូមព្រះជាម្ចាស់ប្រទានសេចក្ដីសុខសាន្តដល់មនុស្ស
ក្នុងផ្ទះនេះ"។ ៦បើនៅក្នុងផ្ទះនោះ មានមនុស្សណាចូលចិត្តសេចក្ដីសុខសាន្ត នោះគេនឹងបានសុខសាន្តដូច
ពាក្យអ្នករាល់គ្នាជាមិនខាន។ បើគ្មានអ្នកណាចូលចិត្តសេចក្ដីសុខសាន្តទេ សេចក្ដីសុខសាន្ត នឹងវិលត្រឡប់មក
អ្នករាល់គ្នាវិញ។ ៧ចូរស្នាក់នៅផ្ទះនោះ ហើយបរិភោគម្ហូបអាហារ ដែលគេជូនអ្នករាល់គ្នាចុះ ព្រោះអ្នកធ្វើ
ការតែង តែទទួលប្រាក់ឈ្នួល។ មិនត្រូវចេញពីផ្ទះមួយទៅនៅផ្ទះមួយទៀតឡើយ។ ៨បើអ្នករាល់គ្នាចូល
ទៅភូមិណា ហើយមានគេទទួលអ្នករាល់គ្នា ត្រូវបរិភោគម្ហូបអាហារ ដែលគេរៀបជូនចុះ។ ៩ត្រូវប្រោសអ្នក
ជំងឺក្នុងភូមិនោះឲ្យបានជា ហើយប្រាប់អ្នកភូមិថា៖ "ព្រះរាជ្យ*របស់ព្រះជាម្ចាស់ នៅជិតអ្នករាល់គ្នាហើយ"។
១០ប៉ុន្តែកាលបើអ្នករាល់គ្នាចូលទៅភូមិណាមួយ ហើយគេមិនព្រមទទួលអ្នករាល់គ្នាទេ ត្រូវចេញទៅប្រកាស
តាមទីផ្សារថា៖ ១១"សូម្បីតែធូលីដីដែលជាប់ជើង យើងក៏យើងរលាស់ឲ្យអ្នករាល់គ្នាវិញដែរ ប៉ុន្តែសូមជ្រាប
ថាព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ"។១២ខ្ញុំសុំប្រាប់អ្នករាល់គ្នាថានៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យ
ទោស អ្នកក្រុងសូដុមទទួលទោសស្រាលជាងអ្នកភូមិនោះ។ ១៣អ្នកក្រុងខូរ៉ាស៊ីនអើយ! អ្នកត្រូវវេទនាជា
ពុំខាន។ អ្នកក្រុងបេតសៃដាអើយ! អ្នកក៏ត្រូវវេទនាដែរ។ ប្រសិនបើអ្នកក្រុងទីរ៉ូស និងអ្នកក្រុងស៊ីដូនបាន
ឃើញការអស្ចារ្យ ដូចអ្នករាល់គ្នាឃើញនៅទីនេះ ម៉្លេះសមអ្នកក្រុងទាំងនោះនឹងប្រែចិត្តគំនិត ហើយស្លៀក
បាវអង្គុយក្នុងផេះជាមិនខាន។ ១៤ហេតុនេះហើយ បានជានៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក
អ្នកក្រុងទីរ៉ូសនិងអ្នកក្រុងស៊ីដូនទទួលទោស ស្រាលជាងអ្នករាល់គ្នា។ ១៥អ្នកក្រុងកាផានុមអើយ! កុំនឹកស្មាន
ថា អ្នកនឹងបានថ្កើងឡើងដល់ស្ថានសួគ៌ឡើយ អ្នកនឹងធ្លាក់ទៅស្ថាននរកវិញ"។ ១៦ព្រះយេស៊ូមានព្រះបន្ទូល
ទៅសាវ័កទៀតថា៖ "អ្នកណាស្ដាប់អ្នករាល់គ្នា ក៏ដូចជាស្ដាប់ខ្ញុំដែរ។ អ្នកណាបដិសេធមិនទទួលអ្នករាល់គ្នា
ក៏ដូចជាបដិសេធមិនទទួលខ្ញុំដែរ ហើយអ្នកណាមិនទទួលខ្ញុំក៏ដូចជាមិនទទួលព្រះអង្គ ដែលចាត់ខ្ញុំឲ្យមក
នោះដែរ"។

# អត្ថបទព្រះគម្ពីរ
## សម្រាប់ថ្ងៃទី១៣/០៩/២០១៣ពេលព្រឹក

### ពួកសាវ័កវិលត្រឡប់មកវិញ

( លូកា ១០, ១៧-២០ )

១៧ ពួកសាវ័ក *ទាំងចិតសិបពីរូប ត្រឡប់មកវិញទាំងត្រេកអរ
ហើយទូលព្រះអង្គថា ៖"ព្រះអម្ចាស់អើយ ដោយសារព្រះនាមព្រះអង្គ សូម្បីតែ
ខ្មោចក៏ចុះចូលក្រោមអំណាចយើងខ្ញុំដែរ"។ ១៨ព្រះអង្គមានព្រះបន្ទូលទៅគេ
ថា ៖ " ខ្ញុំឃើញមារសាតាំង *ធ្លាក់ចុះពីលើមេឃមក ដូចផ្លេកបន្ទោរ ។ ១៩ខ្ញុំបាន
ឲ្យអ្នករាល់គ្នាមានអំណាចដើរជាន់ពស់ និងខ្យាដំរី ព្រមទាំងបង្ក្រាបឫទ្ធិ
អំណាចគ្រប់យ៉ាងរបស់មារសត្រូវផងគ្មានអ្វីអាចធ្វើទុក្ខអ្នករាល់គ្នាបានឡើយ
២០ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កុំត្រេកអរនឹងឃើញខ្មោចចុះចូលអ្នករាល់
គ្នា គឺត្រូវត្រេកអរដោយអ្នករាល់គ្នាមារឈ្មោះកត់ទុកនៅស្ថានបរមសុខវិញ"។

### ព្រះយេស៊ូមានព្រះហឫទ័យរីករាយ

( លូកា ១០, ២១-២៤ ម៉ាថាយ ១១, ២៥-២៧ និង ១៣, ១៦-១៧ )

២១ ខណៈនោះ ព្រះវិញ្ញាណបានធ្វើឲ្យព្រះយេស៊ូមានព្រះហឫទ័យ
រីករាយយ៉ាងខ្លាំង។ ព្រះអង្គមានព្រះបន្ទូលថា ៖ " បពិត្រព្រះបិតាជា អម្ចាស់
នៃស្ថានបរមសុខ * និងជាអម្ចាស់នៃផែនដី ទូលបង្គំសូមសរសើរ តម្កើងព្រះ
អង្គ ព្រោះទ្រង់បានសម្តែងការទាំងនេះ ឲ្យមនុស្សតូចតាចយល់ តែទ្រង់លាក់
មិនឲ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងយល់ទេ។ មែនហើយ!ព្រះអង្គសព្វព្រះ
ហឫទ័យសម្រេចដូច្នេះ។ ២២ព្រះបិតារបស់ខ្ញុំបានប្រគល់អ្វីៗទាំងអស់មកខ្ញុំ។
គ្មាននរណាស្គាល់ព្រះបុត្រា ក្រៅពីព្រះបិតា ហើយក៏គ្មាននរណាស្គាល់
ព្រះបិតា ក្រៅពីព្រះបុត្រានិងអ្នកដែលព្រះបុត្រាសព្វព្រះហឫទ័យ សម្តែងឲ្យ
ស្គាល់នោះដែរ"។ ២៣ បន្ទាប់មក ព្រះយេស៊ូបែរទៅរកសាវ័ក* ហើយមាន
ព្រះបន្ទូលដាច់ឡែកពីគេថា ៖ " អ្នករាល់គ្នាមានសុភមង្គល *ហើយ ព្រោះអ្នក
រាល់គ្នាបានឃើញហេតុការណ៍ទាំងអស់នេះ! ២៤ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នា
ថា មានព្យាការី និងស្តេចជាច្រើនចង់ឃើញហេតុការណ៍ ដែលអ្នករាល់គ្នា
ឃើញនេះដែរ តែមិនបានឃើញ ហើយគេចង់ឮសេចក្តីដែលអ្នករាល់គ្នាបាន
ឮនេះដែរ តែមិនបានឮសោះ"។



# សំណាក់ធម៌

## ក្រុមនិស្សិតទេវវិទ្យាល័យនៅកំពង់សោម

## ១៣/០៩/២០១៣ (រសៀល)

ជម្រាបសួរលោកឪពុក!

បងប្អូនទាំងអស់គ្នាជាទីស្រឡាញ់!ព្រះយេស៊ូងើបព្រះភ័ក្ត្រទតមើលក្រុមសាវ័ករបស់ព្រះអង្គហើយមានព្រះបន្ទូលថា៖ " អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ អ្នករាល់គ្នាដែលកំពុងតែ ស្រេកឃ្លានអើយ អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នានឹងបានឆ្អែត អ្នករាល់គ្នាដែលកំពុងតែយំសោកអើយ អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នានឹងបានត្រេកអរ"។ បពិត្រព្រះអម្ចាស់ ពេលនេះយើខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានបំភ្លឺយើងខ្ញុំពេញមួយអាទិត្យ ឲ្យយើងខ្ញុំ ស្រឡាញ់ព្រះសហគមន៍របស់យើងថែមទៀត និងឲ្យយើងខ្ញុំមានកម្លាំង ថែមទៀត ដើម្បីឲ្យយើងខ្ញុំរៀបចំខ្លួនបម្រើព្រះសហគមន៍ ដែលយើងរស់នៅ។ យើងខ្ញុំសូមទូលអង្វរព្រះអង្គសម្រាប់ព្រះសហគមន៍ សម្រាប់បងប្អូនយើងខ្ញុំទាំងអស់គ្នា ដែលជាព្រះកាយព្រះគ្រីស្ត និងសម្រាប់បងប្អូនដែលមិនទាន់ស្គាល់ព្រះអង្គ ឲ្យព្រះអង្គជួយឲ្យយើងខ្ញុំធ្វើជាសាវ័ក តាមព្រះហឫទ័យស្រឡាញ់ របស់ព្រះយេស៊ូ ដូចព្រះយេស៊ូមានព្រះបន្ទូលថា ពីពេលនេះតទៅ យើងជាអ្នកនេសាទមនុស្ស។ យើងខ្ញុំសូមទូលអង្វរព្រះអង្គដែលជាគ្រីស្ត និងជាព្រះអម្ចាស់យើងខ្ញុំ។ ពេលនេះជាម៉ោងចុងក្រោយ សម្រាប់ការសំណាក់ធម៌របស់យើង។ នៅពេលយើងនិយាយអំពីព្រះសហគមន៍ និងទំនាក់ទំនងជាមួយសង្គម នោះមានចំណុចបី៖

**ចំណុចទីមួយ** "អត់មានម្ខាងជាព្រះសហគមន៍ និង ម្ខាងទៀតជាសង្គមទេ"។ នៅសតវត្សទី ១៧ ជាសតវត្សនៃពន្លឺ ពេលនោះយើងមានពីរក្រុម គឺម្ខាងជាសង្គម ដែលមានទស្សនវិទូជាតំណាង និងម្ខាងទៀត ជាព្រះសហគមន៍ ដែលការពារថែរក្សាសេចក្តីពិត។ រហូតដល់សតវត្សទី ១៩ ពេលនោះមានលោកដាវីន ដែលហ៊ាននិយាយថា មិនមែនព្រះជាម្ចាស់ដែលបង្កើតមនុស្ស គឺមនុស្សវិវឌ្ឍមកពីសត្វស្វា។ ពេលនោះទំនាក់ទំនងរវាងព្រះសហគមន៍នឹងសង្គម មានសភាពតឹងទៅៗជា និច្ច រហូតដល់សម័យវ៉ាទីកង់ទីពីរ ទើបព្រះសហគមន៍ និងសង្គមធ្វើការសម្រុះសម្រួលគ្នា។ ដូច្នេះ សព្វថ្ងៃយើងអត់មាន ម្ខាងជាព្រះសហគមន៍ដែលល្អ និងម្ខាងទៀតជាសង្គមដែលមិនល្អនោះទេ គឺព្រះសហគមន៍ និងសង្គមធ្វើដំណើររួមជាមួយគ្នា។

**ចំណុចទីពីរ** "ព្រះសហគមន៍លែងគ្រប់គ្រងពិភពលោកទៀតហើយ"។ ពីសតវត្សដើម ពេលស្តេចកុងស្តង់តាំងប្រែ ចិត្តគំនិតទៅជាគ្រីស្តបរិស័ទ នៅឆ្នាំ ៣២៥ ពេលនោះព្រះសហគមន៍ និងរដ្ឋអំណាចផ្តើមទៅជាផ្លូវតែមួយជាមួយគ្នា និងបន្តិចម្តងៗ ព្រះសហគមន៍កាន់តែមានអំណាចទៅ និងទៅជាអ្នកគ្រប់គ្រង និងភ្ជាប់ខ្លួនយ៉ាងខ្លាំងជាមួយរដ្ឋអំណាច។ សព្វថ្ងៃ មានប្រទេសកាតូលិកខ្លះ នៅតែបន្តរបៀបនេះដដែល។

**ចំណុចទីបី** " ព្រះសហគមន៍រស់នៅតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលថាយើងរស់នៅក្នុងលោកីយ៍ តែយើង

មិនមកពីលោកីយ៍ទេ។ នេះជាព្រះបន្ទូលតាមរយៈលោកយ៉ូហាន ជាគំនិតដែលគ្រីស្តបរិស័ទមាន។ គ្រីស្តបរិស័ទជាមនុស្សដូច គេដូចឯង ក៏ប៉ុន្តែយើងមានព្រះយេស៊ូដែលណែនាំយើង។ ព្រះសហគមន៍នៅក្នុងលោកីយ៍ដ៏ពេញលក្ខណៈ ក៏ប៉ុន្តែយើងក៏ មកពីព្រះជាម្ចាស់ដ៏ពិតប្រាកដដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍ត្រូវការធ្វើជាសញ្ញាសម្គាល់អំពីព្រះជាម្ចាស់ នៅ ក្នុងសង្គមដែរគឺ៖

១/ " ត្រូវធ្វើជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់"។ ពេលខ្ញុំនៅឆ្នាំទីមួយក្នុងទេវវិទ្យាល័យមាន ឧបជ្ឈាកម្នាក់និយាយថា យើងមកពីព្រះជាម្ចាស់មកនៅក្នុងពិភពលោកប៉ុន្តែយើងមិនមកពីពិភពលោកទេ។ ពេលនោះគ្មានអ្នក ណាយល់ទេ។ តែក្រោយមក ពេលយើងទទួលការសិក្សា ពេលយើងអធិដ្ឋាន ពេលយើងរស់នៅបន្តិចម្តងៗ ណែនាំឲ្យយើងយល់ពីព្រះសហគមន៍ច្បាស់ទៅៗ រហូតយើងយកពាក្យ នេះទុកជាអត្ថន័យ សម្រាប់ជីវិតនៃព្រះសហគមន៍របស់យើង។

២/ " ព្រះសហគមន៍ត្រូវទៅជាអ្នកការពារថែរក្សាផ្លូវដែលព្រះយេស៊ូបានបង្ហាញ"។ យើងដឹងហើយថា ព្រះសហគមន៍បានបន្តជំនឿតាំងពីដើមរៀងមក ប៉ុន្តែពិភពលោកយើង ក៏ត្រូវការមានកន្លែងមួយ ដែលការពារថែរក្សាតម្លៃនៃជីវិត នៃសីលធម៌ ថែរក្សាទ្រព្យសម្បត្តិដែលព្រះសហគមន៍បានទទួលផ្ទាល់ពីព្រះយេស៊ូឲ្យទៅជាមរតកសម្រាប់ពិភពលោក ដែលមិនអាចនរណាបំផ្លាញបានទេ។ ពីសតវត្សមួយទៅសតវត្សមួយ សីលធម៌សង្គមតែងតែប្រែប្រួល ឧទាហរណ៍សង្គម មិនអនុញ្ញាតឲ្យយើងសម្លាប់កូននៅក្នុងពោះ ប៉ុន្តែនៅឆ្នាំ ១៩៧៤ រដ្ឋសភាបារាំងបានអនុញ្ញាតឲ្យស្ត្រីសម្លាប់កូននៅក្នុងពោះ ។ នេះជាចំណុចដែលទាក់ទងនឹងដើមកំណើតនៃជីវិត និង ទីបញ្ចប់នៃជីវិត និង ជីវិតទូទៅរបស់មនុស្សទាំងអស់នៅ ក្នុងសង្គម ដែលប្រែប្រួលពីសតវត្សមួយទៅសតវត្សមួយ។ នៅក្នុងសង្គមទូទៅ សីលធម៌ និង របៀបដែលយើងយល់ពី តម្លៃនៃជីវិតវាប្រែប្រួល យើងមានរបៀបយល់អំពីសីលធម៌ខុសៗគ្នា។ ដូច្នេះព្រះសហគមន៍ ត្រូវទៅជាកន្លែងមួយ ដែលការពារ និងថែរក្សាគ្រប់ពេលវេលានូវតម្លៃនៃជីវិត ជាទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់ និងក៏ត្រូវការពារថែរក្សាគ្រប់ពេលវេលានូវអ្វីៗទាំងអស់ដែលទាក់ទងនឹងជីវិត។ មានមនុស្សជាច្រើន ដែលគេសប្បាយចិត្តនឹងព្រះសហគមន៍ ដោយគេដឹងថា ព្រះសហគមន៍គឺជាកន្លែងមួយដែលខិតខំគោរពជីវិត តាំងពីដើមរហូតដល់ចុងក្រោយនៃជីវិត និងគោរពអ្វីៗទាំងអស់ ដែលព្រះជាម្ចាស់បានបង្កើតមក។ សព្វថ្ងៃ ក៏មានសង្គមជាច្រើនដែរ ដែលគេមិនចង់រវីរវល់នឹងព្រះសហគមន៍ ប៉ុន្តែយើងជាព្រះសហគមន៍ ត្រូវតែការពារថែរក្សា ឲ្យព្រះសហគមន៍យើងទៅជាកន្លែងមួយយ៉ាងពិសេស ដែលគេអាចរកឃើញតម្លៃនៃជីវិត និងដែលជួយ ឲ្យមនុស្សទាំងអស់មានសេចក្តីសង្ឃឹមតទៅទៀត។

**ចំណុចទីបួន** " ចូរប្រុងប្រៀបខ្លួន ប្រុងស្មារតីគ្រប់ពេលវេលា និងជាពិសេសទុកឲ្យចង្កៀងរបស់អ្នករាល់គ្នានៅឆេះ" (លក ១២,៣៥) នេះជាតួនាទីរបស់ព្រះសហគមន៍។ ក្នុងនេះមានអត្ថន័យពីរ៖ ១/ យើងជាអ្នកអង្គុយ ឬឈរទន្ទឹងរង់ចាំ គឺជាអ្នកចេះមើលសញ្ញាដែលកើតមាននៅក្នុងសង្គម។ ទន្ទឹងរង់ចាំ មិនមែនមានន័យថា យើងនៅស្ងៀមស្ងាត់ទេ ប៉ុន្តែយើងជាព្រះសហគមន៍ត្រូវចេញទៅស្វាគមន៍គេ ចេញទៅរកគេដល់កន្លែងរបស់គេ គឺយើងទន្ទឹងរង់ចាំដោយប្រើស្មារតីរបស់យើងយល់ដឹងពីសេចក្តីត្រូវការរបស់គេ តើគេខ្វះខាតអ្វី? តើគេចង់បានអ្វី? គឺឲ្យយើងភ្ញាក់ស្មារតីគ្រប់ពេលវេលា។២/ឲ្យយើងទៅជាចង្កៀងមួយ។ព្រះសហគមន៍មានចង្កៀងមួយ ពេលមានខ្យល់វាក៏ចង់រលត់ដែរ តែវានៅតែភ្លឺរហូតដល់អស់ប្រេង។ ចង្កៀងនោះ មានពន្លឺល្មមអាចបង្ហាញផ្លូវនៅក្នុងភាពងងឹត។នៅពេលយប់ប្រសិនបើយើងបិទភ្លើង បន្ទប់នេះនឹងងងឹត ប៉ុន្តែបើមាននៅសល់តែចង្កៀងមួយ នោះយើងក៏អាចមើលមុខគ្នាបានដែរ។ ដូច្នេះ ព្រះសហគមន៍យើង ក៏ត្រូវតែរៀប

នេះដែរ មានន័យថា យើងម្នាក់ៗត្រូវធ្វើជាពន្លឺតូចមួយ ដើម្បីឲ្យមនុស្សដែលវង្វេងអាចរកឃើញសេចក្តីសង្ឃឹម មនុស្សដែលនៅក្នុងទីងងឹតអាចរកឃើញផ្លូវ ដោយយើងមិនអួតខ្លួនទេ ព្រោះយើង គ្រាន់តែជាចង្កៀងសាមញ្ញ គ្មានអ្វីអស្ចារ្យទេ។ ប្រសិនបើយើងអួតខ្លួន នោះមានន័យថា ចូលនៅក្នុងចំណុចដែលមានពីរក្រុម គឺមានព្រះសហគមន៍ និងមានសង្គម។

**ចំណុចទីប្រាំ** "ព្រះសហគមន៍ត្រូវតែជាវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោកនេះ ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត"។ មានន័យថា ព្រះសហគមន៍ជាព្រះជាម្ចាស់ដែលមនុស្សលោកអាចមើលឃើញបាន ពេលគេ មើលយើង គេនឹងមើលឃើញព្រះជាម្ចាស់ ពេលគេមើលព្រះសហគមន៍ គេនឹងមើលឃើញ ព្រះកាយព្រះគ្រីស្ត ដោយដឹងថាព្រះយេស៊ូគង់នៅជាមួយយើង គឺយើងមិនគ្រាន់តែដើរតាមព្រះយេស៊ូ ប៉ុន្តែយើងដើរជាមួយព្រះយេស៊ូ។ ព្រះយេស៊ូចាប់ដៃយើងឲ្យធ្វើដំណើរជាមួយព្រះអង្គ ដើម្បីបន្តិចម្តងៗ ឲ្យព្រះសហគមន៍យើងស្វាគមន៍ និងធ្វើដំណើរជាមួយមនុស្សលោកបន្តិចម្តងៗ ដូច្នោះដែរ។

សព្វថ្ងៃ ព្រះសហគមន៍ជាចង្កៀងតូចមួយ។ តើយើងធ្វើដូចម្តេចដើម្បីក្លាយជាចង្កៀងតូចមួយ នៅក្នុងសង្គម?។ សន្តៈលូកា បានចែងថា "អ្នកដែលមានហើយត្រូវវេទនា អ្នកដែលញ៉ាំឆ្អែតត្រូវវេទនា អ្នកដែលត្រេកអរត្រូវវេទនា" លោកមានប្រសាសន៍ដូចនេះ ដោយលោកចង់បង្ហាញថា ប្រសិនបើយើងបិទទ្វារ នៃដួងចិត្តរបស់យើង ដោយគិតថាយើងមាន ហើយយើងឆ្អែតហើយ យើងសប្បាយហើយ យើងល្អមហើយ មិនចាំបាច់មានព្រះជាម្ចាស់ក្នុងដួងចិត្តទេ នោះថ្ងៃណាមួយ យើងមុខជាភ្ញាក់ស្មារតីទាំងពិបាកចិត្ត ដោយសារដឹងថាខ្លួននៅទទេ ដោយខ្លួនអស់កន្លែងសម្រាប់ថ្វាយព្រះជាម្ចាស់ ដោយសារក្នុងខ្លួនពោរពេញទៅដោយអំនួត។ អ្វីទាំងអស់ដែលខ្ញុំបាននិយាយពេញមួយអាទិត្យខ្ញុំសង្ឃឹមថាវាជាទ្វារទីមួយសម្រាប់បន្តការអធិដ្ឋានសូមបើកទ្វារ នៃការអធិដ្ឋាន បើកទ្វារដើម្បីទទួលការអប់រំ និងការរិះគិតផ្ទាល់ខ្លួនថា តើព្រះសហគមន៍ជាអ្វី? ខ្ញុំចង់បានព្រះសហគមន៍ របៀបណា? ខ្ញុំចង់កសាងព្រះសហគមន៍រួមជាមួយបងប្អូនរបៀបណា?។ សូមបើកទ្វារមួយទៀត ដើម្បីអនុវត្តខ្លះៗ ដើម្បី ឲ្យព្រះសហគមន៍របស់យើងនៅកម្ពុជា ទៅជាព្រះសហគមន៍របស់ព្រះយេស៊ូយ៉ាងពិតប្រាកដមែន។ អាម៉ែន៕

# អត្ថបទព្រះគម្ពីរ
# សម្រាប់ថ្ងៃទី១៣/០៩/២០១៣ពេលល្ងាច

## ការប្រុងប្រៀបខ្លួន

( លូកា ១២, ៣៥-៤០ )

៣៥ចូរប្រុងប្រៀបខ្លួនហើយទុកឲ្យចង្កៀងរបស់អ្នករាល់គ្នានៅឆេះ។
៣៦ចូរប្រព្រឹត្តឲ្យបានដូចពួកអ្នកបម្រើ ដែលរង់ចាំម្ចាស់វិលត្រឡប់មកពីជប់
លៀងវិញ គឺនៅពេលមកដល់លោកគោះទ្វារអ្នកបម្រើទៅបើកជូនភ្លាម។ ៣៧
ពេលម្ចាស់ត្រឡប់មកដល់ឃើញអ្នកបម្រើណានៅរង់ចាំលោក អ្នកបម្រើនោះ
មានសុភមង្គលហើយ។ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថាលោកនឹងឲ្យអ្នក
បម្រើអង្គុយបរិភោគ ហើយលោករៀបចំខ្លួនបម្រើគេវិញ។ ៣៨បើលោកវិលមក
វិញនៅពាក់កណ្ដាលអធ្រាត្រ ឬជិតភ្លឺ ហើយឃើញអ្នកបម្រើទាំងនោះនៅរង់
ចាំដូច្នេះ ពួកគេប្រាកដជាមានសុភមង្គល។ ៣៩អ្នករាល់គ្នាដឹងហើយថា បើ
ម្ចាស់ផ្ទះដឹងចោរចូលមកប្លន់ម្ញើរណា គាត់នឹងមិនបណ្ដោយ ឲ្យវាចូលមកក្នុង
ផ្ទះគាត់បានឡើយ។ ៤០រីឯអ្នករាល់គ្នាវិញ ចូរត្រៀមខ្លួនជានិច្ចដ្បិតបុត្រ
មនុស្ស *នឹងមកដល់ នៅវេលាដែលអ្នករាល់គ្នាពុំបានគិត"។



រៀបរៀងដោយ ៖
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភូមិភាគភ្នំពេញ

Catholic Social Communications,C.S.C
#25,St.242,Boeng Prolit,7Makara,Phnom Penh,
Tel:023 224 129 E-mail: csccambodia@gmail.com
www.catholiccambodia.org

Web: www.catholicphnompenh.org
Facebook Page: Catholic Phnom Penh